វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
Working Together for Positive Change

# ការឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រគាំទ្រគ្រួសារកសិករដែលមានដីធ្លីតូចតាចៈ

## តាមរយៈការពិនិត្យមើលឡើងវិញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ការសម្ភាសជាមួយ អ្នកផ្តល់ព័ត៌មានសំខាន់ៗ និងករណីសិក្សា



ភ្នំពេញ កម្ពុជា
ខែតុលា ឆ្នាំ២០១៥

**ការឆ្លុះបញ្ចាំងពីយុទ្ធសាស្រ្តគាំទ្រគ្រួសារកសិករដែលមានដីធ្លីតូចតាច៖**
តាមរយៈការពិនិត្យមើលឡើងវិញនូវផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ
ការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងករណីសិក្សា

កាលបរិច្ឆេទបោះពុម្ពផ្សាយ៖ ខែតុលា ឆ្នាំ២០១៥
បោះពុម្ពផ្សាយដោយ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
ស្រាវជ្រាវដោយ៖ សួន សេង អាម៉ូរី ភីធើរ ឈាង សុខម៉ៅ និងចាយ គាថា
មជ្ឈមណ្ឌលស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កសិកម្ម និងប្រព័ន្ធចិញ្ចឹមជីវិត
រចនាអត្ថបទដោយ៖ លោក ភួន យូ មន្ត្រីព័ត៌មាន និងការបោះពុម្ពផ្សាយ

អាសយដ្ឋាន៖ លេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន
រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ៖ ២២៩៥, រាជធានីភ្នំពេញ-៣
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារ៖ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល៖ ngoforum@ngoforum.org.kh
គេហទំព័រ៖ www.ngoforum.org.kh

**សេចក្តីបញ្ជាក់៖**
ទស្សនៈបង្ហាញក្នុងរបាយកាណ៍នេះសុទ្ធតែជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនបង្ហាញពីទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាទេ។ នៅពេលខ្លឹមសារនៃរបាយការណ៍នេះត្រូវគេដកស្រង់ ឬផលិតសារជាថ្មី ការទទួលស្គាល់ និងការសុំអនុញ្ញាតសិទ្ធិរបស់អ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយនឹងត្រូវគេអោយតម្លៃ។

© **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា, ខែតុលា ឆ្នាំ២០១៥**

# មាតិកា


**បញ្ជីតារាង និង រូបភាព** ........ ii

**បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ** ........ iii

**សេចក្តីថ្លែងអំណរគុណ** ........ v

**សេចក្តីសង្ខេប** ........ vi

**១. សេចក្តីផ្តើម** ........ **១**

**២. យុទ្ធសាស្ត្រ និងវិធីសាស្ត្រ** ........ **១**

**៣. របកគំហើញនៃការសិក្សាស្រាវជ្រាវ** ........ **៣**

៣.១. អាទិភាពគោលនយោបាយ ដើម្បីគាំទ្រការអភិវឌ្ឍកសិកម្មក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) ........ ៣

៣.២. ភាពតានតឹងជាសក្តានុពលទាំងក្នុងការគាំទ្រកសិកម្មខ្នាតធំ និងគ្រួសារកសិករដែលមានដីធ្លីតូចតាច ........ ៦

៣.២.១. គោលនយោបាយគាំទ្រគ្រួសារកសិករដែលមានដីធ្លីតូចតាច ........ ៦

៣.២.២. គោលនយោបាយគាំទ្រអ្នកមានដីធ្លីធំ ........ ៨

៣.២.៣. ផលវិបាកនៃគោលនយោបាយដីសម្បទានសេដ្ឋកិច្ចចំពោះគ្រួសារដែលមានដីធ្លីតូចតាច ..១១

៣.៣. បញ្ហាប្រឈម និងក្តីសង្ឃឹមក្នុងការគាំទ្រគ្រួសារកសិករដែលមានដីធ្លីតូចតាច ........ ១៤

៣.៣.១ ក្របខណ្ឌវិភាគនៃការសិក្សា ........ ១៤

៣.៣.២ តួនាទីតួអង្គពាក់ព័ន្ធសំខាន់ៗដើម្បីគាំទ្រកសិករតូចតាច ........ ១៧

៣.៤. ការគាំទ្រកសិករដែលមានដីធ្លីតូចតាចៈ ករណីសិក្សាអង្គការសេដាក និងអេសអិនវី ........ ២១

៣.៤.១. ការគាំទ្រផលិតកម្ម និងទីផ្សារស្រូវសរីរាង្គដោយអង្គការសេដាក ........ ២១

៣.៤.២. ការគាំទ្រផលិតកម្ម និងទីផ្សារលើដំណាំបន្លែដោយអង្គការសេដាក ........ ២៦

៣.៤.៣. ការគាំទ្រផលិតកម្ម និងទីផ្សារបន្លែសុវត្ថិភាពដោយដៃគូររបស់អង្គការអេសអិនវី ........ ៣២

៣.៤.៤. ការគាំទ្រផលិតកម្ម និងទីផ្សារជំឡូងមី ដោយដៃគូរអង្គការអេសអិនវី ........ ៤១

៣.៥. ការវិភាគ និងចំណេះដឹងដែលទទួលបានពីករណីសិក្សា ........ ៤៦

៣.៥.១. យុទ្ធសាស្ត្រចង្វាក់សាកល និងចង្វាក់ប្រមូលផ្តុំពីមូលដ្ឋាន ........ ៤៦

៣.៥.២. គុណសម្បត្តិ និងគុណវិបត្តិនៃយុទ្ធសាស្ត្រចង្វាក់សាកល និងយុទ្ធសាស្ត្រប្រមូលផ្តុំពីថ្នាក់មូលដ្ឋាន ........ ៥០

៣.៥.៣. ផលិតផលសុវត្ថិភាព (អង្គការដៃគូអេសអិនវី) និងផលិតផលទីផ្សារធម្មជាតិ (សេដាក)... ៥០

៣.៥.៤. គុណសម្បត្តិ និងគុណវិបត្តិ នៃទស្សនៈអាជីវកម្មតាមបែបបរិយាប័ន្ន និងបែបពឹងអាស្រ័យលើ

ខ្លួនឯង ............................................................................................................. ៥១
**៤. សន្និដ្ឋាន និងអនុសាសន៍ ............................................................................... ៥៤**
៤.១. សន្និដ្ឋាន ......................................................................................................... ៥៤
៤.២. អនុសាសន៍ ....................................................................................................... ៥៥
**បញ្ជីឯកសារយោង ............................................................................................ ៥៨**
ឧបសម្ព័ន្ធទី១: បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ........................................................... ៦១
ឧបសម្ព័ន្ធទី២: បញ្ជីសំណួរ សម្រាប់សម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ ..................................... ៦២
ឧបសម្ព័ន្ធទី៣: បញ្ជីសំណួរសម្រាប់ការសម្ភាសជាលក្ខណៈគ្រួសារ ............................................ ៦៩
ឧបសម្ព័ន្ធទី៤: បញ្ជីសំណួរសម្រាប់ការពិភាក្សាក្រុម លើប្រភេទផលិតផលបន្លែ................................ ៧៤
ឧបសម្ព័ន្ធទី៥: បញ្ជីសំណួរសម្រាប់ការពិភាក្សាក្រុម លើប្រភេទផលិតផលស្រូវ................................ ៧៨
ឧបសម្ព័ន្ធទី៦: បញ្ជីសំណួរសម្រាប់ការសម្ភាសជាក្រុម លើប្រភេទផលិតផលដំឡូងមី ......................... ៨២

## បញ្ជីតារាង និង រូបភាព

### បញ្ជីតារាង

តារាងទី 1: ជំហានសំខាន់ៗ ក្នុងការៀបចំសហគមន៍រោងម៉ាស៊ីនកិនស្រូវ........................................ ២៤
តារាងទី 2: ឥទ្ធិពលទៅលើការប្រកបរបរចិញ្ចឹមជីវិត តាមរយៈសហគមន៍រោងម៉ាស៊ីនកិនស្រូវ.............. ២៥
តារាងទី 3: ដំណាក់កាលសំខាន់ៗ ក្នុងការរៀបចំក្រុមអ្នកផលិតបន្លែសរីរាង្គ ....................................២៧
តារាងទី 4: ឥទ្ធិពលលើការប្រកបរបរចិញ្ចឹមជីវិត តាមរយៈក្រុមអ្នកផលិតកសិកម្មសរីរាង្គ.................... ២៩
តារាងទី 5: ដំណាក់កាលនៃវឌ្ឍនភាពសំខាន់ៗ ក្នុងការរៀបចំក្រុមអ្នកផលិតបន្លែ និងសមាគមកសិករ... ៣៥
តារាងទី 6: ឥទ្ធិពលទៅលើការប្រកបរបរចិញ្ចឹមជីវិត តាមរយៈក្រុមអ្នកផលិតបន្លែ និងសមាគមកសិករ... ៣៨
តារាងទី 7: ជំហានសំខាន់ៗ ក្នុងការរៀបចំក្រុមអ្នកផលិតដំឡូងមី.................................................. ៤២
តារាងទី 8: ឥទ្ធិពល ទៅលើការប្រកបរបរចិញ្ចឹមជីវិត តាមរយៈក្រុមអ្នកផលិតដំឡូងមី........................ ៤៤
តារាងទី 9: បញ្ហាប្រឈម និងភាពជោគជ័យ ក្នុងការតភ្ជាប់កសិករទៅកាន់ទីផ្សារនៅក្នុងប្រភេទ
ផលិតផលដែលបានជ្រើសរើស ........................................................................................ ៥២

### បញ្ជីរូបភាព

រូបភាពទី 1: ក្របខណ្ឌការប្រមូលទិន្នន័យ និងសកម្មភាពផ្សេងៗនៃការសិក្សា......................................២
រូបភាពទី 2: ក្របខណ្ឌវិភាគនៃការសិក្សា..................................................................................... ១៦
រូបភាពទី 3: ការបង្ហាញទម្រង់រូបភាពពីយុទ្ធសាស្ត្រទីផ្សារទាំងពីរៈ យុទ្ធសាស្ត្រសាកល (ឆ្វេង) និងយុទ្ធសាស្ត្រ
ការប្រមូលផ្តុំពីមូលដ្ឋាន (ស្តាំ) ............................................................................................ ៤៩

# បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| AC | សហគមន៍កសិកម្ម |
| ADHOC | សមាគមការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា |
| ASSDP | គំពោងអភិវឌ្ឍន៍យុទ្ធសាស្ត្រវិស័យកសិកម្ម |
| CC | បម្រែបម្រួលអាកាសធាតុ |
| CEDAC | មជ្ឈមណ្ឌលសិក្សា និង អភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CENTDOR | មជ្ឈមណ្ឌលស្រាវជ្រាវតំរែតំរង់ទិសការអភិវឌ្ឍលើវិស័យកសិកម្ម និងការចិញ្ចឹមជីវិត |
| CFAP | សហព័ន្ធសមាគមកសិករកម្ពុជានៃអ្នកផលិតកសិកម្ម |
| CIAT | មជ្ឈមណ្ឌលអន្តរជាតិនៃកសិកម្មតំបន់ត្រូពិច |
| CIDSE | កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីអភិវឌ្ឍន៍ និង សាមគ្គីភាព |
| CIRAD | មជ្ឈមណ្ឌលនៃសហគមន៍ស្រាវជ្រាវអន្តរជាតិលើការអភិវឌ្ឍកសិកម្ម |
| CIRD | វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍ជនបទកម្ពុជា |
| CSA | កសិកម្មពឹងផ្អែកលើអាកាសធាតុ |
| DAC | សហគមន៍កសិកម្ម |
| ELC | សម្បទានដីសេដ្ឋកិច្ច |
| EU | សហភាពអ៊ឺរ៉ុប |
| FA | សមាគមកសិករ |
| FAO | អង្គការស្បៀងអាហារ និង កសិកម្ម |
| FC | សមាគមកសិករ |
| FNN | ប្រព័ន្ធកសិកម្ម និង ធម្មជាតិ |
| GAP | ការអនុវត្តកសិកម្មល្អ |
| GDA | អគ្គនាយកដ្ឋានកសិកម្ម |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GIZ | សហគ្រាសសហព័ន្ធយុវជនអាល្លឺម៉ង់ នៃ សហគមអន្តរជាតិ |
| HA | ហិចតា |
| HH | ក្រុមគ្រួសារ |
| ICM | ការគ្រប់គ្រងដំណាំចំរុះ |
| ICS | ប្រពន្ធ័គ្រប់គ្រងផ្ទៃក្នុង |
| IVY | មជ្ឈមណ្ឌលអ្នកស្ម័គ្រចិត្តអន្តរជាតិនៃទីក្រុងយ៉ាមាហ្គាតា |
| KH Riel | រៀល (រូបិយវត្ថុខ្មែរ) |
| Kg | គីឡូក្រាម |
| LICADHO | សហព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស លីកាដូ |
| MFI | ស្ថាប័នមីក្រូហិរញ្ញវត្ថុ |

| | |
|---|---|
| MOC | ក្រសួងពាណិជ្ជកម្ម |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | គំរោងអភិវឌ្ឍន៍យុទ្ធសាស្ត្រថ្នាក់ជាតិ |
| PDA | កសិកម្មថ្នាក់ខេត្ត |
| PGI | ការការពារនូវសញ្ញាណសម្គាល់ភូមិសាស្ត្រ |
| RGC MEF | រាជរដ្ឋាភិបាលកម្ពុជា- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| RGC MoP | រាជរដ្ឋាភិបាលកម្ពុជា- ក្រសួងផែនការ |
| SNV | អង្គការអភិវឌ្ឍន៍ប្រទេសនីឌែឡែន |
| SRI | ការរីកចំរើននៃប្រព័ន្ធស្រូវ |
| TOR | ឯកសារយោង |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| USD | ដុល្លារ (រូបិយវត្ថុអាមេរិក) |
| អត្រាប្តូរប្រាក់: | ១ដុល្លារ = ៩.០០០រៀល |

# សេចក្តីថ្លែងអំណរគុណ

តំណាងឲ្យក្រុមស្រាវជ្រាវរបស់អង្គការសិនដរ យើងសូមថ្លែងអំណរគុណដល់បណ្ឌិត យ៉ងសាំង កុមារ ប្រធានអង្គការសេដាក លោកស្រី ម៉ារីកិ វ៉ានស៊ី ទីប្រឹក្សាកម្មវិធីរបស់អង្គការអេសអិនវី មន្ត្រីជាន់ខ្ពស់របស់អង្គការទាំងពីរ អង្គការដៃគូរបស់អង្គការអេសអិនវីនៅខេត្តស្វាយរៀង និងខេត្តកំពង់ចាម ដែលបានចែករំលែកព័ត៌មានដ៏មានសារៈសំខាន់ ស្តីអំពីភាពជោគជ័យ និងបញ្ហាប្រឈមក្នុងការអនុវត្តគម្រោង និងការសម្របសម្រួល សម្រាប់ដំណើរកិច្ចពិភាក្សាក្រុម និងការសម្ភាសជាលក្ខណៈគ្រួសារ។

យើងក៏សូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រចំពោះមន្ត្រីរដ្ឋាភិបាលនៃអគ្គនាយកដ្ឋានកសិកម្ម និងនាយកដ្ឋានកសិឧស្សាហកម្ម អ្នកគ្រប់គ្រងកម្មវិធីរបស់ទីផ្សារសួនធម្មជាតិ នាយកប្រតិបត្តិវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជនបទកម្ពុជា (CIRD) និងទីប្រឹក្សាកម្មវិធីមកពីអង្គការ អាយហ្វាត/យូអិនឌីភី និងបុគ្គលិកអង្គការជីអាយហ្សេត ដែលបានចំណាយពេលវេលាដ៏មានតម្លៃជាមួយក្រុមការងារ និងផ្តល់នូវព័ត៌មានដ៏មានសារៈសំខាន់ និងការយល់ឃើញរបស់ខ្លួនដល់ក្រុមស្រាវជ្រាវយើងខ្ញុំ។

យើងក៏សូមថ្លែងអំណរគុណផងដែរ ដល់បុគ្គលិកវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា លោក មីសែល ផៅវែល លោកគ្រីស្តុប អូដេនប៊ើក អ្នកស្រី គីម ណៃ និង អ្នកស្រី ស្រី ស៊ីណាត ចំពោះការសម្របសម្រួល និងផ្តល់នូវមតិយោបល់ល្អៗលើការសិក្សារបស់ក្រុមយើងខ្ញុំ។

ជាចុងបញ្ចប់ យើងក៏សូមថ្លែងអំណរគុណដ៏ស្មោះ ចំពោះកសិករដែលបានចំណាយពេលវេលា និងផ្តល់នូវព័ត៌មានចាំបាច់សម្រាប់ការសិក្សានេះផងដែរ។

តំណាងក្រុមស្រាវជ្រាវ៖ សួន សេង

នាយកអង្គការសិនដរ

# សេចក្តីសង្ខេប

ការសិក្សាស្តីអំពី "ការឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រគាំទ្រគ្រួសារកសិករដែលមានដីធ្លីតូចតាច" ត្រូវបានធ្វើឡើងដោយក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្ម និងប្រព័ន្ធចិញ្ចឹមជីវិត (សិនដវ)។ ការសិក្សាត្រូវបានធ្វើឡើងនៅខែមករា រហូតដល់កុម្ភៈ ឆ្នាំ២០១៥។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និងគោលនយោបាយទាក់ទងនឹងការអភិវឌ្ឍកសិកម្មនៅកម្ពុជា ត្រូវបានសិក្សា។ អ្នកផ្តល់ព័ត៌មានសំខាន់ៗនៅថ្នាក់ជាតិ ដែលធ្វើកិច្ចការពាក់ព័ន្ធនឹងវិស័យកសិកម្ម និងក្នុងការគាំទ្រដល់គ្រួសារកសិករដែលមានដីធ្លីតូចតាច ត្រូវបានសម្ភាស។ ករណីសិក្សាស្តីអំពីកសិផល ចំនួន៤ប្រភេទ នៃអង្គការមិនមែនរដ្ឋាភិបាលចំនួន ២ (សេដាក និង អេសអិនវី) ត្រូវបានសិក្សា។ លទ្ធផលនៃការសិក្សានេះ ត្រូវបានប្រើប្រាស់ជាអនុសាសន៍សម្រាប់រដ្ឋាភិបាល និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ទៅលើយុទ្ធសាស្ត្រគាំទ្រគ្រួសារកសិករដែលមានដីធ្លីតូចតាចនៅកម្ពុជា។

គោលបំណងនៃការសិក្សា គឺដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវសំខាន់ៗដូចខាងក្រោម៖

- តើគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានផ្តល់អាទិភាពលើវិស័យកសិកម្មក្នុងកម្រិតណា ចំពោះគ្រួសារកសិករដែលមានដីធ្លីតូចតាច និង ក្រុមហ៊ុនដីសម្បទាន?
- តើរាជរដ្ឋាភិបាលកម្ពុជាមានតួនាទីអ្វីខ្លះ ក្នុងការគាំទ្រដល់គ្រួសារកសិករដែលមានដីធ្លីតូចតាច និងក្រុមហ៊ុនសម្បទានក្នុងប្រទេសកម្ពុជា?
- តើអ្វីជាភាពតានតឹងដែលអាចកើតមាន រវាងការគាំទ្រការពង្រីកគម្រោងកសិកម្មខ្នាតធំ និងការគាំទ្រគ្រួសារកសិករដែលមានដីធ្លីតូចតាច?
- តើមានមេរៀនអ្វីខ្លះ ដែលទទួលបានពីការសិក្សាស្រាវជ្រាវ ដើម្បីប្រើប្រាស់ក្នុងការគាំទ្រដល់គ្រួសារកសិករដែលមានដីធ្លីតូចតាច?
- តើមេរៀនដែលទទួលបានពីករណីសិក្សា អាចយកទៅអនុវត្តឲ្យបានទូលំទូលាយយ៉ាងដូចម្តេច?

**លទ្ធផលនៃការសិក្សាបានបង្ហាញថា៖**

- គោលនយោបាយ បានផ្តល់អាទិភាពជាសំខាន់ចំពោះវិស័យកសិកម្ម ដូចមានរៀបរាប់ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ វិស័យនេះត្រូវបានកំណត់ជាសរសៃស្តម្ភមួយ ក្នុងចំណោមសរសរ ស្តម្ភទាំង៤ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានតួនាទីសំខាន់ ក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ច ជាពិសេស ការចូលរួមអភិវឌ្ឍសេដ្ឋកិច្ច ជនបទ ធានានូវសមភាពនិងសន្តិសុខស្បៀងផងដែរ។

- ទោះយ៉ាងណា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ មិនបានផ្តល់អាទិភាពជាសំខាន់ដោយឡែកណាមួយ ទៅលើកសិកម្មខ្នាតតូច ឬខ្នាតធំឡើយ ប៉ុន្តែផ្តល់នូវគំនិតផ្តួចផ្តើមមួយចំនួន ក្នុងការលើកកម្ពស់វិស័យកសិកម្ម។ គំនិតផ្តួចផ្តើមទាំងនោះ ត្រូវបានជំរុញដោយផ្តោតលើការធ្វើទំនើបកម្ម ក្នុងគោលបំណងផ្លាស់ប្តូរពីការធ្វើកសិកម្មតាមទម្លាប់ មកកសិកម្មតាមបែបបច្ចេកទេសទំនើប ការធ្វើពិពិធកម្មកសិកម្ម តាមរយៈការទទួលយកនូវប្រភេទដំណាំដែលមានតម្លៃទីផ្សារខ្ពស់ ពិសេសសម្រាប់គោលដៅទីផ្សារនាំចេញ និងការធ្វើពាណិជ្ជូបនីយកម្មកសិកម្ម តាមរយៈការលើកកម្ពស់ពាណិជ្ជកម្ម និងការនាំចេញផលិតផលកសិកម្ម។
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ បានផ្តល់ឱកាសច្រើន ដល់អ្នកពាក់ព័ន្ធទាំងឡាយដែលមានមូលធន ដើម្បីចូលរួមទៅក្នុងអន្តរកាលទំនើបកម្ម អ្នកដែលមានលទ្ធភាពទទួលយកនូវបច្ចេកវិទ្យា និងដែលអាចផ្លាស់ប្តូរមកដំណាំទីផ្សារបាន។ យុទ្ធសាស្ត្រដូចគ្នានេះ ក៏បានកត់សម្គាល់នូវផលប្រយោជន៍ចំពោះកសិករ ដែលបានរៀបចំខ្លួន និងសារៈសំខាន់នៃការទទួលបានព័ត៌មាន និងបណ្តាញទីផ្សារផងដែរ។ ទាំងក្រុមហ៊ុនសម្បទាន និងកសិករដែលមានដីធ្លីតូចតាច ដែលស្ថិតក្នុងលំដាប់ខ្ពស់ នឹងទទួលបានផលប្រយោជន៍ពីគំនិតផ្តួចផ្តើមទាំងនេះ ខណៈដែលកសិករខ្នាតតូចជាច្រើនទៀត អាចទទួលបានប្រយោជន៍តិចតួច ឬត្រូវបានទុកឲ្យនៅដាច់ដោយឡែកពីការផ្លាស់ប្តូរទាំងនេះ។
- ដើម្បីគាំទ្រដល់គ្រួសារកសិករដែលមានដីធ្លីតូចតាច គោលនយោបាយ និងច្បាប់មួយចំនួនត្រូវបានរៀបចំដោយរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសាមី។ ទាំងនោះរួមមាន គោលនយោបាយ ពូជស្រូវ និងពូជដំណាំផ្សេងៗ គោលនយោបាយស្តង់ដាកសិកម្មសរីរាង្គកម្ពុជា គោលនយោបាយនាំអង្ករចេញ និងច្បាប់ស្តីពីសហគមន៍កសិកម្មជាដើម។ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានដើរតួនាទីសំខាន់ក្នុងការដឹកនាំគ្រប់គ្រង គាំទ្រ និងធានាថា គោលនយោបាយ និងការប្តេជ្ញាចិត្តទាំងឡាយលើកិច្ចអភិវឌ្ឍន៍កសិកម្មទទួលបានជោគជ័យ ជាមួយគ្នានោះផងដែរ ធានាបាននូវសន្តិសុខ និងសុវត្ថិភាពស្បៀងក្នុងប្រទេសកម្ពុជា។ ទោះយ៉ាងនេះក្តី បញ្ហាប្រឈមសំខាន់ៗជាច្រើន រួមនឹងដំណោះស្រាយ លើផ្នែកផលិតផលស្តង់ដាគុណភាព ធាតុចូលកសិកម្មដែលមានតម្លៃខ្ពស់ គុណភាពគ្រាប់ពូជមិនល្អ និងសមត្ថភាពហិរញ្ញវត្ថុ នៅមិនទាន់បានឆ្លើយតបនៅឡើយ ដែលទាមទារឲ្យមានការយកចិត្តទុកដាក់បន្ថែម ដើម្បីគាំទ្រដល់ក្រុមកសិករដែលមានដីធ្លីតូចតាច ក្នុងបរិបទផ្សេងៗរបស់គាត់។
- ច្បាប់ដីធ្លី ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា បានលើកទឹកចិត្តដល់ការវិនិយោគឯកជនតាមរយៈការផ្តល់ដីរដ្ឋជាសម្បទានខ្នាតធំ។ អនុក្រឹត្យ ឆ្នាំ២០០៥ ស្តីអំពីដីសម្បទានសេដ្ឋកិច្ចត្រូវបានរៀបចំ ដែលគាំទ្របន្ថែមដល់ការអភិវឌ្ឍសម្បទានទ្រង់ទ្រាយធំ។ លើសពីនេះ បទបញ្ជា ០១ និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់អ្នកកាន់កាប់ដីដែលមានស្រាប់ តាមរយៈគោលនយោបាយស្បែកខ្លា ក៏ត្រូវបាន

អនុវត្ត ដើម្បីដោះស្រាយជម្លោះរវាងសហគមន៍ក្នុងតំបន់ និងម្ចាស់ក្រុមហ៊ុនសម្បទានខ្នាតធំក្នុងរង្វង់ដែនសម្បទានផងដែរ។

- អ្នកផ្តល់ព័ត៌មានសំខាន់ថ្នាក់ជាតិ បានគូសបញ្ជាក់នូវយុទ្ធសាស្ត្រសំខាន់ពីរ ដើម្បីគាំទ្រដល់គ្រួសារកសិករដែលមានដីធ្លីតូចតាច នោះគឺតាមរយៈការរៀបចំសហគមន៍កសិកម្ម និងការតភ្ជាប់ផលិផលរបស់កសិករទៅទីផ្សារ។ អ្នកផ្តល់ព័ត៌មានបានសង្កត់ធ្ងន់លើផលិតកម្ម ដើម្បីបំពេញនូវសន្តិសុខស្បៀងក្នុងគ្រួសារជាអាទិភាព មុននឹងភ្ជាប់ពួកគាត់ទៅកាន់ទីផ្សារ។ អ្នកផ្តល់ព័ត៌មានសំខាន់ថ្នាក់ជាតិក៏ទទួលស្គាល់ថា កសិករនៅប្រឈមនឹងបញ្ហាមួយចំនួនក្នុងការចងក្រងគ្នាឲ្យបានល្អ ការផ្គត់ផ្គង់នូវផលិតផលស្តង់ដាគុណភាព ការដោះស្រាយនូវធាតុចូលកសិកម្មដែលមានតម្លៃខ្ពស់ គុណភាពពូជមិនល្អ និងសមត្ថភាពហិរញ្ញវត្ថុដែលនៅមានកម្រិតនៅឡើយ។
- លទ្ធផលដែលបានមកពីការធ្វើករណីសិក្សាលើប្រភេទកសិផលបានបង្ហាញថា មានវិធីសាស្ត្រផ្សេងគ្នាក្នុងការគាំទ្រកសិករដែលមានដីធ្លីតូចតាចដោយផ្អែកលើប្រភេទកសិផលនីមួយៗ និងទស្សនៈរបស់ក្រុមគោលដៅ និងអ្នកអនុវត្តកម្មវិធី។ នៅអង្គការសេដាក ទស្សនៈអភិវឌ្ឍន៍ដើម្បីគាំទ្រដល់គ្រួសារកសិករដែលមានដីធ្លីតូចតាចផ្តោតសំខាន់លើការអភិវឌ្ឍបែបអាស្រ័យលើខ្លួនឯង ខណៈអង្គការអេសអិនវី អនុវត្តនូវយុទ្ធសាស្ត្រពាណិជ្ជកម្មតាមបែបបរិយាប័ន្ន ដោយភាគីពាក់ព័ន្ធ ចូលរួមក្នុងការធ្វើឲ្យប្រសើរឡើង និងថែរក្សានូវរចនាសម្ព័ន្ធអាជីវកម្ម ដើម្បីចែករំលែកនូវផលកម្រៃដែលទទួលបាន។ បច្ចេកវិទ្យាថ្មីៗ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក៏ត្រូវបានអនុវត្តដោយអង្គការទាំងពីរផងដែរ។
- ដើម្បីភ្ជាប់គ្រួសារកសិករដែលមានដីធ្លីតូចតាចទៅទីផ្សារ យុទ្ធសាស្ត្រតាមបែបចង្វាក់សាកល [1] (Global chain) និងបែបប្រមូលផ្តុំពីថ្នាក់មូលដ្ឋាន (Filière) ត្រូវបានយកមកអនុវត្ត។ យុទ្ធសាស្ត្រទាំងពីរនេះ ផ្តល់នូវការយល់ឃើញពីរបៀបនៃការគាំទ្រកសិករដែលមានដីធ្លីតូចតាចនៅកម្រិតផ្សេងៗ នៃការអភិវឌ្ឍអាជីវកម្ម។ យុទ្ធសាស្ត្រតាមបែបប្រមូលផ្តុំពីថ្នាក់មូលដ្ឋាន សមស្របបំផុតចំពោះកសិករខ្នាតតូច ជាពិសេសនៅដំណាក់កាលដំបូង នៅពេលកសិករត្រូវបានភ្ជាប់ទៅទីផ្សារ ខណៈដែលយុទ្ធសាស្ត្រចង្វាក់សាកលមានលក្ខណៈសមស្របបំផុតចំពោះផលិតករខ្នាតធំ និងបន្ទាប់ពីកសិករបានចងក្រងគ្នាជាក្រុម ឬ សហគមន៍រួចរាល់។

[1] យុទ្ធសាស្ត្រចង្វាក់សាកល៖ អ្នកនាំចេញ ចុះកិច្ចសន្យាជាមួយក្រុមហ៊ុនក្នុងស្រុក ដើម្បីផ្គត់ផ្គង់នូវប្រភេទផលិតផល។ ក្រុមហ៊ុនក្នុងស្រុកធ្វើការសម្របសម្រួលជាមួយអ្នកផលិតក្នុងស្រុក ដើម្បីផលិតនូវប្រភេទផលិតផល ឆ្លើយតបតាមតម្រូវការសម្រាប់ការនាំចេញ។ រចនាសម្ព័ន្ធរៀបចំពីលើមកក្រោមនេះ ត្រូវបានគេស្គាល់ថាជាយុទ្ធសាស្ត្រចង្វាក់សាកល (ការពន្យល់លម្អិតបន្ថែម ត្រូវបានបង្ហាញនៅចំណុច ៣.៤.១. យុទ្ធសាស្ត្រចង្វាក់សាកល និងយុទ្ធសាស្ត្រប្រមូលផ្តុំពីថ្នាក់មូលដ្ឋាន)។

- យុទ្ធសាស្ត្រអភិវឌ្ឍន៍បែបអាស្រ័យលើខ្លួនឯង និងយុទ្ធសាស្ត្រអាជីវកម្មបែបបរិយាប័ន្ន ក៏ត្រូវបានយកមកពិភាក្សា។ យុទ្ធសាស្ត្រទាំងពីរនេះ ផ្តល់នូវអត្ថប្រយោជន៍ ដល់គ្រួសារកសិករដែលមានដីធ្លីតូចតាចទៅតាមដំណាក់កាលនៃការអភិវឌ្ឍអាជីវកម្ម។ ភាពខ្លាំង និងភាពខ្សោយក្នុងការអនុវត្តនូវយុទ្ធសាស្ត្រទាំងពីរនេះ ក៏ត្រូវបានបង្ហាញផងដែរ។ ការអភិវឌ្ឍបែបអាស្រ័យលើខ្លួនឯង ជួយកសិករឲ្យគ្រប់គ្រងនូវចង្វាក់ពាណិជ្ជកម្ម ប៉ុន្តែដំណើរការនេះ ទាមទារនូវការប្តេជ្ញាចិត្តរយៈពេលវែង ខណៈដែលយុទ្ធសាស្ត្រអាជីវកម្មបែបបរិយាប័ន្ន ផ្តល់នូវអត្ថប្រយោជន៍ដល់កសិករបន្ទាប់ពីរយៈពេលមួយខ្លី ជាធម្មតា ក្នុងកំឡុងពេលអនុវត្តគម្រោង ប៉ុន្តែអ្នកផលិតមានឱកាសតិចតួចក្នុងការគ្រប់គ្រងចង្វាក់អាជីវកម្មដោយខ្លួនឯងទេ។
- ការសិក្សាក៏បានរកឃើញផងដែរថា បច្ចេកវិទ្យាសមស្របត្រូវបានអនុវត្តនៅកម្រិតគម្រោង ដូចជាបច្ចេកទេសដំណាំស្រូវសរីរាង្គ ផលិតកម្មបន្លែដោយវិធីសន្សំសំចៃទឹក និងការដាំដំណាំបន្លែនៅរដូវប្រាំងជាដើម។ បន្ថែមលើសនេះ វិធីសាស្ត្រអភិវឌ្ឍន៍ផ្សេងៗ ត្រូវបានអនុវត្ត និងមានលក្ខណៈសមស្របតាមដំណាក់កាលផ្សេងៗនៃការអភិវឌ្ឍ៖ វិធីសាស្ត្រអាជីវកម្មបែបបរិយាប័ន្ន និងការអភិវឌ្ឍបែបអាស្រ័យលើខ្លួនឯង។ ទោះយ៉ាងណាក្តី ការតស៊ូមតិ ការផ្សព្វផ្សាយ និងការពិភាក្សាពីគោលនយោបាយ គួរត្រូវបានរៀបចំ ដើម្បីអនុញ្ញាតិដល់ការពង្រីកនូវវិសាលភាពនៃ យុទ្ធសាស្ត្រទាំងនេះប្រកបដោយប្រសិទ្ធភាព។

**អាស្រ័យហេតុនេះ យើងសូមផ្តល់អនុសាសន៍ដូចតទៅ៖**

- រដ្ឋាភិបាលគួរបង្កើនល្បឿនក្នុងការរៀបចំបង្កើតឯកសារក្របខណ្ឌគតិយុត្ត និងសេវាគាំទ្របច្ចេកទេសដើម្បីបង្កើតសហគមន៍កសិកម្មដូចជា៖ សម្ភារៈបណ្តុះបណ្តាល/រៀនសូត្រ (ទី១-ឧបករណ៍ស្តីអំពីការអនុវត្ត និងការគ្រប់គ្រងសហគមន៍កសិកម្ម និងទី២-ឧបករណ៍បណ្តុះបណ្តាលគ្រូបង្គោល)។ តួនាទីកសិករខ្នាតតូចក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គួរត្រូវបានគូសបញ្ជាក់។ យុទ្ធសាស្ត្រទីផ្សារតាមបែបប្រមូលផ្តុំពីថ្នាក់មូលដ្ឋាន គួរត្រូវបានអនុវត្តជាអាទិភាព ដើម្បីចងក្រងក្រុមកសិករផលិតនៅដំណាក់កាលដំបូង។ លើសពីនេះ រដ្ឋាភិបាលក៏គប្បីមានមូលនិធិដើម្បីគាំទ្រដល់សហគមន៍កសិកម្ម និងសហព័ន្ធសហគមន៍កសិកម្មផងដែរ។ មូលនិធិនេះ ក៏គួរអាចទទួលបានដោយសហគមន៍កសិកម្មផ្ទាល់ ដើម្បីឲ្យពួកគេអាចពង្រឹងនិងពង្រីកប្រតិបត្តិការអាជីវកម្មរបស់ពួកគាត់បាន។
- អង្គការមិនមែនរដ្ឋាភិបាល និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា គប្បីរៀបចំនូវវេទិកាសាធារណៈដោយមិនបង្អង់យូរ ដើម្បីចែករំលែកនូវរបកគំហើញនៃការសិក្សានេះ។ យុទ្ធសាស្ត្រតាមបែបប្រមូលផ្តុំពីថ្នាក់មូលដ្ឋាន គួរត្រូវបានទទួលយកមកអនុវត្ត ដើម្បីភ្ជាប់កសិករទៅកាន់ទីផ្សារ។ ទោះយ៉ាងណា ការគាំទ្រកសិករ គប្បីផ្តោតការយកចិត្តទុកដាក់លើផលិតកម្មដែលមានទិសដៅជាចម្បង សម្រាប់បម្រើសេចក្តីត្រូវការក្នុងគ្រួសារជាបឋម ហើយជាបន្តបន្ទាប់ ធ្វើការផ្គត់ផ្គង់មកកាន់ទីផ្សារថ្នាក់តំបន់ទីក្រុង និងទីផ្សារនាំចេញ។ ក្នុងពេលជាមួយគ្នានោះ អង្គការមិនមែនរដ្ឋាភិបាល គប្បីធ្វើការចងក្រង និងផ្សព្វផ្សាយនូវការអនុវត្តកសិកម្មល្អឲ្យបានទូលំទូលាយទៅដល់កសិករ និងខេត្តផ្សេងៗទៀត។

- កសិករគប្បីចងក្រងគ្នាជាក្រុម ឬសហគមន៍ ដើម្បីផលិតនូវប្រភេទផលិតផលផ្សេងៗសម្រាប់ទីផ្សារ។ ទោះយ៉ាងណាក្តី កសិករចាំបាច់ត្រូវផលិតដើម្បីបំពេញសេចក្តីត្រូវការក្នុងគ្រួសាររបស់ខ្លួនជាមុនសិន បន្ទាប់មកធ្វើការផ្គត់ផ្គង់ទៅទីផ្សារក្នុងតំបន់។ កសិករក៏ត្រូវរៀនសូត្រពីលក្ខខណ្ឌតម្រូវការនៃទីផ្សារ ពាក់ព័ន្ធនឹងភាពជាក់លាក់ណាមួយនៃផលិតផល។ ដើម្បីមានលទ្ធភាពទទួលបានមូលនិធិពីខាងក្រៅ សហគមន៍កសិកម្មចាំបាច់ត្រូវយល់ដឹងពីការគ្រប់គ្រងហិរញ្ញវត្ថុ និងរៀបចំនូវយុទ្ធសាស្រ្ត និងផែនការប្រតិបត្តិអាជីវកម្មប្រកបដោយស្តង់ដា។ លើសពីនេះ ការកសាងភាពជោគជ័យរបស់សហគមន៍កសិកម្មនៅកម្រិតមូលដ្ឋានមានសារៈសំខាន់បំផុត។ ការប្រាស្រ័យទាក់ទង និងភាពជាអ្នកដឹកនាំក៏មានសារៈសំខាន់ផងដែរសម្រាប់សហគមន៍កសិកម្ម។

# ១. សេចក្តីផ្តើម

ចាប់តាំងពីអាណត្តិទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលបានកំណត់គោលដៅធានានូវកំណើនសេដ្ឋកិច្ចកម្រិតខ្ពស់ ដើម្បីក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ប៉ុន្តែក៏ធានានូវការរីកលូតលាស់ប្រកបដោយចីរភាព និងបរិយាប័ន្នផងដែរ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាឯកសារចម្បង ដើម្បីដឹកនាំនូវគំនិតផ្តួចផ្តើមនេះ។ ការអភិវឌ្ឍកសិកម្ម រួមទាំងភាពចាំបាច់នៃកំណែទម្រង់ដីធ្លី ការធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងដីធ្លី និងការបង្កើនផលិតភាពកសិកម្ម គឺជាធាតុចាំបាច់នៅក្នុងយុទ្ធសាស្ត្រនេះ។ ដើម្បីបង្កើននូវសន្តិសុខស្បៀង ការលើកកម្ពស់ផលិតភាពកសិកម្ម និងការកាត់បន្ថយភាពក្រីក្រ ដោយបង្កើនប្រាក់ចំណូលដល់កសិករតាមរយៈការបង្កើនតម្លៃបន្ថែមលើផលិតផលកសិកម្ម ការវិនិយោគលើកសិកម្មទាំងក្នុងទ្រង់ទាយតូច និងធំ គឺជាទិសដៅនៃយុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍ជាតិ។ ស្ថិតក្នុងបរិការនេះ យើងយល់ថា ការសិក្សាដែលត្រូវបានស្នើឡើងដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលនៃកម្ពុជានៅពេលនេះ នឹងបង្កើតនូវរបកគំហើញសំដៅរួមចំណែកដល់កិច្ចពិភាក្សា និងពិគ្រោះយោបល់លើបញ្ហានេះ។

មជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្ម និងប្រព័ន្ធចិញ្ចឹមជីវិត (សិនដរ) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ សិនដរ មានគោលបំណងក្នុងការចូលរួមចំណែកក្នុងកិច្ចពិគ្រោះយោបល់ស្តីពីជីវភាពរស់នៅនៅជនបទ និងបញ្ហាប្រឈមក្នុងការប្រកបរបរចិញ្ចឹមជីវិត ទៅភាគីពាក់ព័ន្ធទាំងឡាយ ដើម្បីធ្វើការសម្រេចចិត្តបានប្រសើរជាងមុន។ សិនដរ យល់ស្របជាមួយនឹងគោលបំណង និងសំណួរស្រាវជ្រាវ ដូចមានបញ្ជាក់នៅក្នុងឯកសារស្តីពីការងារ និងការទទួលខុសត្រូវ។

**គោលបំណង៖** ធ្វើការសិក្សាពីអាទិភាពទាំងឡាយ ដែលគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានផ្តល់ឲ្យគ្រួសារកសិករដែលមានដីធ្លីតូចតាច និងក្រុមហ៊ុនដីសម្បទានខ្នាតធំ និងធ្វើការប្រៀបធៀបពីគុណសម្បត្តិ និងគុណវិបត្តិនៃយុទ្ធសាស្ត្រទាំងពីរនេះ ចំពោះកិច្ចអភិវឌ្ឍន៍កសិកម្ម ដោយយោងលើករណីសិក្សាចំនួនពីរ ក្នុងការគាំទ្រដល់គ្រួសារកសិករ ដើម្បីបង្កើនផលិតភាពដីរបស់ពួកគាត់។ របកគំហើញសំខាន់ៗពីការសិក្សា នឹងត្រូវយកមកប្រើប្រាស់ ដើម្បីស្វែងរកការគាំទ្រមតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រីកការគាំទ្រដល់កសិករមានដីធ្លីតូចតាចជាអាទិភាព ជាជាងការផ្តល់ដីសម្បទានខ្នាតធំ។ របាយការណ៍នេះ នឹងរួមបញ្ចូលនូវអនុសាសន៍មួយចំនួនដល់រាជរដ្ឋាភិបាល និងអង្គការនៃវេទិការអង្គការមិនមែនរដ្ឋាភិបាលនៃកម្ពុជាផងដែរ។

# ២. យុទ្ធសាស្ត្រ និងវិធីសាស្ត្រ

គម្រោងនេះ បានចាប់ផ្តើមនៅពាក់កណ្តាលខែធ្នូ ឆ្នាំ២០១៤ រហូតដល់ខែកុម្ភៈ ឆ្នាំ២០១៥។ របាយការណ៍ពង្រាង ត្រូវបានផ្ញើជូនវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា នៅខែមីនា ឆ្នាំ ២០១៥។

ការសិក្សាត្រូវបានកំណត់ត្រឹមក្របខណ្ឌនៃបញ្ហាទាំងឡាយ ដែលប៉ះពាល់ដល់គ្រួសារកសិករដែលមានដីធ្លីតូចតាច។ នេះរួមបញ្ចូលទិសដៅនយោបាយស្តីអំពីការអភិវឌ្ឍកសិកម្ម ផលវិបាកនៃអ្នកកាន់កាប់ដីធ្លីខ្នាតធំ និងករណីសិក្សា ស្តីពីគម្រោងដែលគាំទ្រដល់កសិករដែលមានដីធ្លីតូចតាច។

ដើម្បីចាប់ផ្តើមពិនិត្យលើឯកសារដែលមានស្រាប់ សំណួរស្រាវជ្រាវ ដែលមានបញ្ជាក់នៅក្នុងឯកសារការងារ និងការទទួលខុសត្រូវ ត្រូវបានបំបែកជាចំណុចតូចៗ ដែលត្រូវបានប្រើប្រាស់ជាគោលការណ៍ណែនាំសម្រាប់ការធ្វើបទសម្ភាសន៍។ បន្ទាប់មក លទ្ធផលដែលទទួលបានពីការសិក្សាលើគោលនយោបាយ ត្រូវបានប្រើប្រាស់ ដើម្បីរៀបចំជាបញ្ជីសំណួរ សម្រាប់ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ។ ជាជំហានបន្ទាប់ លទ្ធផលដែលទទួលបានពីការធ្វើបទសម្ភាសន៍នេះ ត្រូវបានប្រើប្រាស់ ដើម្បីបង្កើតនូវបញ្ជីសំណួរសម្រាប់គម្រោង និងការធ្វើករណីសិក្សា។

លទ្ធផលដែលទទួលបានពីការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ ត្រូវបានសំយោគទៅតាមបញ្ហាប្រឈម និងក្តីសង្ឃឹមចំពោះកសិករដែលមានដីធ្លីតូចតាច ទៅតាមក្របខណ្ឌវិភាគនៃការសិក្សា (រូបភាពទី២)។

យុទ្ធសាស្ត្រ និងបទពិសោធន៍នៃគម្រោងអភិវឌ្ឍន៍ ដែលទទួលបានពីករណីសិក្សាត្រូវបានចងក្រងដោយអនុលោមទៅតាមក្របខណ្ឌវិភាគ។




**រូបភាពទី 1: ក្របខណ្ឌការប្រមូលទិន្នន័យ និងដំណាក់កាលនៃសកម្មភាពសិក្សា**

# ៣. របកគំហើញនៃការសិក្សាស្រាវជ្រាវ

## ៣.១. អាទិភាពគោលនយោបាយ គាំទ្រការអភិវឌ្ឍកសិកម្មក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨)

វិស័យកសិកម្ម បានតំណាងឲ្យសសរស្តម្ភមួយ ក្នុងចំណោមសសរស្តម្ភទាំង៤ នៃយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលកម្ពុជា (ដំណាក់កាលទី៣)។ វាមិនមែនជាការភ្ញាក់ផ្អើលដែលថា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានរួមបញ្ចូលនូវចំណុចទាំងឡាយ នៃការលើកកម្ពស់វិស័យកសិកម្ម។ វិស័យនេះត្រូវបានកត់សម្គាល់ ថាជាវិស័យដែលមានតួនាទីសំខាន់ នៅក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ច ជាពិសេសការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ប៉ុន្តែក៏ស្ថិតក្នុងន័យសមភាព និងសន្តិសុខស្បៀងផងដែរ (RGC MoP, 2014)។

វិស័យកសិកម្ម ព្រៃឈើ និងជលផល បានចូលរួមចំណែកប្រមាណ ៣១.៦% នៃផលិតផលសរុបក្នុងស្រុក នៅឆ្នាំ ២០១៣ (RGC MAFF, 2015), បន្ទាប់ពីមានការធ្លាក់ចុះបន្តិចបន្តួចក្នុងឆ្នាំ ២០១៤ វិស័យនេះត្រូវបានរំពឹងទុកថា នឹងរួមចំណែកច្រើនថែមទៀតក្នុងកំណើនផលទុនសរុបក្នុងស្រុកនៅឆ្នាំ២០១៥។ អត្រាកំណើននៃវិស័យកសិកម្ម ដែលមានការប្រែប្រួលផ្អែកតាមលក្ខខណ្ឌអាកាសធាតុប្រចាំឆ្នាំ មានអតិផរណាចន្លោះពី ៣% ទៅ ៤% ក្នុងរយៈកាលឆ្នាំ ២០០៩ ដល់ ២០១៣ ហើយរំពឹងថា នឹងកើនឡើងរហូតដល់ ៤% ជាថ្មីម្តងទៀត នៅប៉ុន្មានឆ្នាំខាងមុខនេះ (RGC MAFF, 2015; RGC MoP, 2014)។ ការលើកកម្ពស់វិស័យកសិកម្ម ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានផ្តោតការយកចិត្តទុកដាក់លើការធ្វើទំនើបកម្ម ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម។ គោលបំណងទាំងនេះ ក៏មាននៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងលទ្ធផលសម្រេចបានសំខាន់ៗ និងបញ្ហាប្រឈម ដែលត្រូវបានរាយការណ៍ សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ ផងដែរ (RGC MoP, 2014)។

ការធ្វើទំនើបកម្មត្រូវបានគេមើលឃើញថា ជាមធ្យោបាយមួយដើម្បីលើកកម្ពស់ផលិតភាពតាមរយៈការបង្កើននូវយន្តការទាំងឡាយ ការស្រោចស្រព និងការនាំមកនូវបច្ចេកវិទ្យាថ្មី។ លើសពីនេះ ពិពិធភាវូបនីយកម្ម មានគោលបំណងឈានឆ្ពោះទៅរកផលិតផលដែលមានតម្លៃទីផ្សារខ្ពស់ ដោយផ្តោតលើប្រភេទដំណាំ និងកសិផលសម្រាប់ការនាំចេញជាសក្តានុពលផ្សេងទៀត (ឧ. កៅស៊ូ ដំឡូងមី ម្រេច ពោត ស្វាយចន្ទី ត្រអំពៅ គ្រាប់ស្វាយចន្ទីជាដើម)។ ដំណើរឆ្ពោះទៅមុខនេះ ត្រូវបានគាំទ្រតាមរយៈការពង្រឹង និងការពង្រីកនូវរចនាសម្ព័ន្ធសេវាគាំទ្រនៅកម្រិតមូលដ្ឋាន រួមមានៈ សេវាផ្សព្វផ្សាយ ព័ត៌មានទីផ្សារ ពូជ និង ការកែច្នៃផលិផលកសិកម្មជាដើម។ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ច្បាប់ និងបទប្បញ្ញត្តិជាច្រើន ត្រូវបានរំពឹងទុកថា បានចូលរួមចំណែកដល់ការធ្វើទំនើបកម្ម ជាពិសេសលើផលិតកម្មពូជ ការនាំចូលនូវធាតុចូលកសិកម្ម ប្រព័ន្ធកសិកម្មតាមកិច្ចសន្យា ការប្រើប្រាស់ដីកសិកម្ម កិច្ចការពារដំណាំ សមាគមប្រើប្រាស់ទឹក និងការអភិវឌ្ឍធនធានមនុស្ស ដែលបង្ហាញនូវក្របខណ្ឌគាំទ្រសម្រាប់ការ

អភិវឌ្ឍវិស័យកសិកម្ម។ ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្ម ត្រូវបានធ្វើផែនការដោយផ្តោតសំខាន់លើការអនុវត្តតាមបែបទំនើប ពិពិធភាវូបនីយកម្ម និងស្តីពីហិរញ្ញវត្ថុ និងទីផ្សារ។

វត្ថុបំណងនៃការធ្វើពាណិជ្ជូបនីយកម្ម នៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិជាសំខាន់ គឺការលើកកម្ពស់ការធ្វើជំនួញ និងការនាំចេញផលិតផលកសិកម្ម។ សហគមន៍កសិកម្ម មានការទទួលស្គាល់ នូវតួនាទីចាំបាច់នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ដែលជួយបង្កើតនូវបណ្តាញអាជីវកម្មកសិកម្ម។ ការកើនឡើងនូវពាណិជ្ជូបនីយកម្ម គឺពឹងផ្អែកលើការធានាបាននូវការធ្វើឲ្យប្រសើរឡើង នូវសមត្ថភាពនៃការកែច្នៃ ប្រព័ន្ធរៀបចំទុកដាក់ឲ្យបានរឹងមាំ លទ្ធភាពប្រសើរជាងមុនខាងផ្នែកទីផ្សារ ការសម្របសម្រួល និងការធ្វើឲ្យមានភាពសាមញ្ញនៃជំនួញ។ លើសពីនេះ គុណភាពនៃផលិតផលគួរតែឆ្លើយតបផងដែរ ទៅនឹងស្តង់ដាអន្តរជាតិសម្រាប់ការនាំចេញ។ គួរកត់សំគាល់ផងដែរថា ក្រៅពីការតភ្ជាប់ឲ្យបានប្រសើរជាងមុនរវាងអ្នកផលិតនិងឈ្មួញ និងលទ្ធភាពប្រសើរជាងមុន ក្នុងការទទួលបាននូវផ្នែកឥណទានដែលអាចទទួលយកបាន ការធ្វើឲ្យប្រសើរឡើងនូវភាពជាដៃគូរវាងកសិឧស្សាហកម្មខ្នាតធំ និងកសិកម្មលក្ខណៈគ្រួសារ ត្រូវបានកំណត់ជាការចូលរួមចំណែកទៅនឹងការយកចិត្តទុកដាក់លើការធ្វើពាណិជ្ជូបនីយកម្មនេះ។ ទោះជាយ៉ាងនេះក្តី ពុំមានព័ត៌មានបន្ថែមណាមួយត្រូវបានផ្តល់ ថាតើទំនាក់ទំនងតភ្ជាប់នេះ ត្រូវបានបង្កើតតាមរបៀបណានៅឡើយទេ។ ការអនុវត្តច្បាប់ស្តីពីសហគមន៍កសិកម្ម គោលនយោបាយលើកកម្ពស់ផលិតកម្មដំណាំស្រូវ និងការនាំចេញអង្ករ យុទ្ធសាស្រ្តអភិវឌ្ឍន៍ដំណាំកៅស៊ូធម្មជាតិកម្ពុជា ឆ្នាំ២០១១-២០២០ ត្រូវបានចាត់ទុកជាបញ្ញត្តិ ដែលគាំទ្រដល់គោលបំណងនៃការធ្វើពាណិជ្ជូបនីយកម្មនេះ។

ពិពិធកម្មក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ គឺជាការតម្រង់ទិសជាចម្បងទៅរកការលើកកម្ពស់តម្លៃផលិតផល ជាមួយនឹងសក្តានុពលសម្រាប់ការនាំចេញ។ គោលបំណងជាទូទៅនៃការផ្តួចផ្តើមនេះគឺដើម្បីបង្កើនតម្លៃបន្ថែមក្នុងផ្ទៃដី១ហិកតាលើគ្រប់ដំណាំទាំងអស់ ឲ្យបានត្រឹមចំនួន ៥០% ធៀបទៅនឹងឆ្នាំ២០០៧ នៅបំណាច់ឆ្នាំនៃផែនការបច្ចុប្បន្នក្នុងឆ្នាំ២០១៨ (RGC MoP, 2014)។ ការស្រាវជ្រាវនិងការអភិវឌ្ឍកសិកម្មដើរតួនាទីជាសំខាន់ មិនត្រឹមតែដើម្បីផ្តល់នូវគំនិតផ្តួចផ្តើមផ្នែកបច្ចេកវិទ្យាប៉ុណ្ណោះទេ តែថែមទាំងផ្តល់នូវការឆ្លុះបញ្ចាំងអំពីការទទួលយកនូវបច្ចេកទេសផ្សេងៗ ទៅនឹងបរិបទក្នុងតំបន់ និងម៉ូដែលដែលត្រូវបានលើកកម្ពស់។ ការតម្រង់ឆ្ពោះទៅកាន់ទីផ្សារនៃផលិតផលកសិកម្ម គឺមានភាពច្បាស់លាស់ដោយសង្កត់ធ្ងន់លើស្តង់ដា (ជាតិ) និងព្រមទាំងគុណភាពផលិតផលក្នុងន័យសុវត្ថិភាពស្បៀងនិងការត្រួតពិនិត្យផងដែរ។ ភាពដាច់ដោយឡែក ក៏ត្រូវបានធ្វើឡើងរវាងលក្ខខណ្ឌតម្រូវការក្នុងស្រុក ក្នុងតំបន់ និងតម្រូវការទីផ្សារអន្តរជាតិផងដែរ។

គួរកត់សម្គាល់ផងដែរថា ក្នុងចំណោមសំណើជាក់លាក់នៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ការអនុវត្តកសិកម្មល្អត្រូវបានលើកកម្ពស់ រួមទាំងប្រព័ន្ធគ្រប់គ្រងដំណាំចម្រុះផងដែរ។ ការអនុវត្តកសិកម្មល្អ ត្រូវបានសម្គាល់ជាមធ្យោបាយ ដើម្បីបង្កើនផលិតភាពកសិករតូចតាច។ ប្រព័ន្ធគ្រប់គ្រងដំណាំចម្រុះ គឺជាវិធីសាស្រ្តទាំងមូលរបស់កសិដ្ឋានដែលកំណត់ច្បាស់នូវទីតាំងជាក់លាក់ និងមានទិសដៅដើម្បីសម្រេចបាននូវតុល្យភាពដ៏ត្រឹមត្រូវរវាងផលិតកម្មដំណាំជាលក្ខណៈសេដ្ឋកិច្ច និងការគ្រប់គ្រងបរិស្ថានជាលក្ខណៈវិជ្ជមាន តាមរយៈការផ្គុំបញ្ចូលគ្នានូវការ

ដាំដំណាំបង្វិល ពូជដំណាំសមស្រប និងជាតុចូលសិប្បនិម្មិតក្នុងកម្រិតអប្បបរមា។ វាក៏ផ្តុំបញ្ចូលគ្នានូវបច្ចេកវិទ្យាទំនើប ជាមួយនឹងគោលការណ៍គ្រឹះនៃការអនុវត្តកសិកម្មល្អសម្រាប់រយៈពេលវែង (Kumar and Shivay, 2008)។ ក្នុងន័យការពង្រឹងប្រព័ន្ធកសិកម្ម ការវិភាគទីតាំងនៃប្រព័ន្ធអេក្រូបរិស្ថាននៅកម្រិតផ្សេងគ្នា និងការធ្វើផែនការប្រើប្រាស់ដីធ្លី ស្ថិតក្នុងចំណោមសកម្មភាពក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ទស្សនៈទានទាំង៣នេះត្រូវបានបញ្ជាក់ដោយសង្ខេប នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយត្រូវបានចាត់ទុកជាសំណើ ដើម្បីគាំទ្រគ្រួសារកសិករដែលមានដីធ្លីតូចតាច និងរួមចំណែកដល់ការអភិវឌ្ឍកសិកម្មប្រកបដោយចីរភាព។

ផ្តើមចេញពីការបង្ហាញសំខាន់ៗ វាហាក់បីដូចជាតំណភ្ជាប់ស្វ័យប្រវត្តិត្រូវបានធ្វើឡើងរវាងផលិតផលតម្លៃបន្ថែម ការបង្កើនប្រាក់ចំណូល និងការកាត់បន្ថយភាពក្រីក្រ។ ទោះយ៉ាងនេះក្តី លក្ខខណ្ឌ (ដំបូង) នៃដំណើរជោគជ័យនេះនៅមិនទាន់បានពិភាក្សា ឬ ពន្យល់នៅឡើយទេ។ នេះបង្កើតឲ្យមាននូវសំណួរដូចតទៅ៖ តើកសិករទាំងអស់ ពិសេសកសិករក្រីក្រ មានលទ្ធភាពទទួលបាននូវកសិកម្មតម្លៃបន្ថែមដែរឬទេ? ហើយជាទូទៅ តើកសិករដែលមានដីធ្លីតូចតាច មានសមត្ថភាពទទួលយក និងគ្រប់គ្រងកញ្ចប់បច្ចេកវិទ្យាទាំងមូល និងប្រមូលយកអត្ថប្រយោជន៍ពាក់ព័ន្ធបានដែរឬទេ?

ដោយផ្តល់នូវចម្រុះភាព និងការប្រកបរបរចិញ្ចឹមជីវិតដ៏សាំញ៉ាំរបស់គ្រួសារកសិករដែលមានដីធ្លីតូចតាចវាទំនងថា មានតែកសិករមួយចំនួនប៉ុណ្ណោះ ដែលអាចចូលរួមដោយជោគជ័យ លើការធ្វើទំនើបកម្មដែលបានលើកឡើង ដែលស្របតាមការអនុវត្តរបស់ពួកគាត់ និងទទួលបានអត្ថប្រយោជន៍ពីទីផ្សារសាកល។ សង្គមជនបទ ហ៊ុំព័ទ្ធដោយក្រុមកសិករមានដីធ្លីតូចតាចផ្សេងៗគ្នា ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ មានតែគ្រួសារកសិករមានដីធ្លីតូចតាចក្នុងចំណែកតូចមួយប៉ុណ្ណោះ ទទួលបាននូវដើមទុន ការប្រមូលផ្តុំគ្នា ព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធ ហើយអាចចាប់យកទីផ្សារផ្លូវការ ដើម្បីអភិវឌ្ឍន៍ឱកាសអាជីវកម្ម។ គ្រួសារកសិករដែលមានដីធ្លីតូចតាចភាគច្រើនមានភាពស្ទាក់ស្ទើរចំពោះការវិនិយោគក្នុងវិស័យកសិកម្មដែលជាផ្នែកមួយនៃជីវភាពរស់នៅរបស់ពួកគេ មិនសូវបានរៀបចំចងក្រងគ្នាជាក្រុម/សហគមន៍ និងជាទូទៅពួកគាត់ទៅធ្វើជំនួញជាមួយវិស័យមិនផ្លូវការ (Vorley et al., 2012)។ ចំណែកកសិករភាគច្រើនវិញ មិនអាចទទួលបាននូវបច្ចេកទេសកសិកម្មទំនើប និងឱកាសទីផ្សារសាកលនោះទេ។ ដូច្នេះ ការរៀបចំគោលនយោបាយ គប្បីធ្វើឡើងដើម្បីឆ្លើយតបទៅនឹងចម្រុះភាពនៃស្ថានភាពរបស់កសិករដែលមានដីធ្លីតូចតាចផ្សេងៗគ្នាទាំងនោះ។

ជាមួយនឹងអាទិភាពគោលនយោបាយដែលត្រូវបានគូសបញ្ជាក់ខាងលើផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ បានជំរុញនូវបរិបទមួយដែលមានតែអ្នកពាក់ព័ន្ធដែលមានមូលធនប៉ុណ្ណោះ ទើបអាចចូលរួមនៅក្នុងអន្តរការទំនើបកម្មនេះបាន អាចមានលទ្ធភាពប្រើប្រាស់នូវបច្ចេកវិទ្យាថ្មីៗ អាចផ្លាស់ប្តូរទៅដាំដុះប្រភេទដំណាំសម្រាប់ទីផ្សារ មានសមត្ថភាពរៀបចំខ្លួន ហើយអាចទទួលបានព័ត៌មានទីផ្សារ និងខ្សែបណ្តាញបាន។ ទាំងក្រុមហ៊ុនទទួលបានដីសម្បទាន និងក្រុមកសិករដែលមានលទ្ធភាពនៃចំណោមគ្រួសារកសិករដែលមានដីធ្លីតូចតាចអាចនឹងទទួលបានផលប្រយោជន៍ពីការផ្តួចផ្តើមនេះ ខណៈដែលភាគច្រើននៃគ្រួសារកសិករដែលមិនមានលទ្ធភាព

និងដែលមានដីធ្លីតូចតាច អាចគ្រាន់តែជាផ្នែកមួយរបស់ការអភិវឌ្ឍប៉ុណ្ណោះ ឬ មិនបានទទួលផលប្រយោជន៍ពីគំនិតផ្តួចផ្តើមទាំងនេះ។ លើសពីនេះ ទោះបីមានការកើនឡើងនូវផលកម្រៃនៅក្នុងលក្ខខណ្ឌពិតប្រាកដនៃដំណាំមួយចំនួនដូចជា ដំឡូងមី និងបន្លែ ដែលផ្តល់នូវប្រាក់ចំណូលជាសក្តានុពលសម្រាប់កសិករ វាគួរត្រូវបានកត់សម្គាល់ថា ជាអាទិ៍ កំណើនពិសេសរបស់ដំឡូងមី គឺពឹងផ្អែកលើការពង្រីកផ្ទៃដីដាំដុះ ដែលវានឹងមិនមាននិរន្តរភាព ដោយសារថា វាត្រូវបានអនុវត្តតាមរយៈការកាប់បំផ្លាញព្រៃឈើ និងធ្វើឲ្យដីខ្សោះជីជាតិដី (ACI, 2014)។

ដូច្នេះ យើងអាចលើកជាសំណួរមួយចំនួនដូចតទៅៈ

- តើមានអ្នកណាខ្លះ ដែលអាចទទួលផលពិតប្រាកដពីទំនើបភាវូបនីយកម្ម ដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា?
- ចំពោះកសិករគ្រប់ប្រភេទ តើត្រូវសម្របខ្លួនរបៀបណាទៅនឹងអាទិភាពគោលនយោបាយ ក្នុងវិស័យកសិកម្ម?
- ដោយពិចារណាលើឱកាស ដែលនាំមកដោយទីផ្សារផ្សេងៗ រួមមាន ទីផ្សារក្នុងស្រុក តំបន់ និងអន្តរជាតិ តើត្រូវអនុវត្តគំនិតផ្តួចផ្តើមទាំងនេះដោយរបៀបណា?
- តើត្រូវតភ្ជាប់កសិឧស្សាហកម្មខ្នាតធំ និងកសិកម្មជាលក្ខណៈគ្រួសារយ៉ាងដូចម្តេច? តាមរយៈការធ្វើកសិកម្មតាមកិច្ចសន្យា? ទំនាក់ទំនងផ្សេងទៀត?
- តើអ្វីជាតួនាទីជាក់លាក់របស់សហគមន៍កសិកម្មៈ ជាអ្នកផ្តល់សេវាកម្មទៅកសិករ? និងជាខ្សែសង្វាក់ទៅកាន់ទីផ្សារ? សម្រាប់ទីផ្សារប្រភេទណា?

## ៣.២. ភាពតានតឹងជាសក្តានុពល ក្នុងការគាំទ្រកសិកម្មខ្នាតធំ និងគ្រួសារកសិករដែលមានដីធ្លី តូចតាច

### ៣.២.១. គោលនយោបាយគាំទ្រគ្រួសារកសិករដែលមានដីធ្លីតូចតាច

ស្របទៅនឹងអាណត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រផ្នែកកសិកម្មរបស់ខ្លួន ដើម្បីគាំទ្រសេចក្តីថ្លែងការ ស្តីពីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងរបៀបវារៈដូចជា គោលនយោបាយនាំអង្ករចេញ សន្តិសុខ និងសុវត្ថិភាពស្បៀង ការកាត់បន្ថយភាពក្រីក្រ (RGC MAFF, 2015)។

ក្រោយពីដាក់ចេញនូវគោលនយោបាយ ស្តីអំពី "ការលើកកម្ពស់ផលិតកម្មស្រូវ និងការនាំអង្ករចេញ ការនាំចេញអង្ករ" ទៅកាន់ទីផ្សារអន្តរជាតិមានការកើនឡើងជាបន្តបន្ទាប់ពីចំនួនតិចតួចបំផុតនៅឆ្នាំ ២០០៨ ដល់ ២០០.០០០តោនក្នុងឆ្នាំ ២០១២។ អង្ករកម្ពុជាឈ្មោះថា ផ្ការំដួល ត្រូវបានចាត់ទុកជាអង្ករមានគុណភាពខ្ពស់បំផុត (RGC MoP, 2014; RGC MAFF, 2015)។ ផលិតកម្មកៅស៊ូ ក៏មានការកើនឡើង ជាសំខាន់ផងដែរ នៅថ្នាក់ជាតិៈ តំបន់ដាំដុះកៅស៊ូបានកើនឡើងជាងទ្វេដង រហូតដល់ ៣២៨.៧៧០ ហ.តក្នុងឆ្នាំ២០១៣ ហើយផលិតកម្ម

នាំចេញបានកើនឡើងប្រមាណ១៣៥% ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ កើនដល់ជាង ៨៦.០០០តោន (RGC MAFF, 2015) ដែលឃើញជាផ្លូវការថាជាលទ្ធផលនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិកម្ពុជា ២០១១-២០២០។ ដោយពិនិត្យមើលលើតួលេខ កាលពីមុន គោលនយោបាយនាំអង្ករចេញ និងកៅស៊ូ ហាក់ជួយរក្សាលទ្ធផលបានល្អប្រសើរ។

ដើម្បីលើកកម្ពស់គ្រួសារកសិករដែលមានដីធ្លីតូចក្នុងកិច្ចអភិវឌ្ឍន៍កសិកម្ម និងសហគមន៍កសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានរៀបចំច្បាប់មួយ ស្តីអំពីសហគមន៍កសិកម្ម នៅឆ្នាំ២០១៣ ដើម្បីគាំទ្រ និងគ្រប់គ្រងសហគមន៍កសិកម្មនៅទូទាំងប្រទេស (RGC MAFF, 2013)។ ច្បាប់នេះបង្កប់នូវការពិព័ណ៌នាយ៉ាងលម្អិតអំពីសិទ្ធិរចនាសម្ព័ន្ធតួនាទី និងការទទួលខុសត្រូវរបស់សហគមន៍កសិកម្ម។ លើសពីនេះ តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងភ្នាក់ងាររបស់ខ្លួនក្នុងការគាំទ្រដល់កសិករ ក៏មានបរិយាយលម្អិតផងដែរ។ ក្រោយពេលច្បាប់ត្រូវបានអនុម័តដោយសភាជាតិ នាយកដ្ឋាន សហគមន៍កសិកម្មត្រូវបានបង្កើតឡើងក្រោមអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។

នៅឆ្នាំ ២០១៤ អគ្គនាយកដ្ឋានកសិកម្ម បានធ្វើពង្រាងគោលនយោបាយពូជស្រូវ និងដំណាំរួមផ្សំផ្សេងៗទៀត។ គោលបំណងនៃគោលនយោបាយនេះ គឺដើម្បីធានាថា កសិករអាចទទួលបាននូវពូជដំណាំដែលមានគុណភាពល្អ និងប្រភេទពូជផ្សេងៗ។ គោលនយោបាយនេះស្របទៅនឹងច្បាប់ស្តីអំពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិរបស់អ្នកបង្កាត់ពូជឆ្នាំ២០០៨ និងអនុក្រឹត្យ ស្តីអំពីកសិកម្មតាមកិច្ចសន្យា រួមនឹងគោលនយោបាយនាំអង្ករចេញផងដែរ (RGC, 2011; RGC MAFF, 2008)។ គោលនយោបាយនេះ នឹងផ្តល់ឱកាសដល់កសិករដែលមានដីធ្លីតូចតាច និងអ្នកបង្កាត់ពូជ ដើម្បីចុះបញ្ជីពូជដំណាំថ្មីរបស់ពួកគាត់ ក្រោយពីបានធ្វើពិសោធន៍នៅទីវាលរួចរាល់។ ក្នុងពេលជាមួយគ្នាផងដែរ អគ្គនាយកដ្ឋានកសិកម្ម ក៏បានពង្រាងគោលនយោបាយថ្មីស្តីពីស្តង់ដាកសិកម្មសរីរាង្គកម្ពុជាផងដែរ។ គោលនយោបាយនេះ កំពុងស្ថិតក្នុងដំណើរការពិគ្រោះយោបល់ ក្នុងចំណោមក្រុមការងារបច្ចេកទេស និងនាយកដ្ឋានពាក់ព័ន្ធផ្សេងៗ នៃអគ្គនាយកដ្ឋានកសិកម្ម។ គោលនយោបាយពង្រាងនេះ ផ្តោតសំខាន់លើរាល់ប្រភេទមុខដំណាំទាំងអស់ និងផលិតផលសត្វក្នុងប្រទេសកម្ពុជា។ គោលនយោបាយនេះមានបំណងលើកកម្ពស់ផលិតផលសរីរាង្គរបស់កសិករ នឹងផ្តល់នូវលក្ខណៈវិនិច្ឆ័យយ៉ាងតឹងរឹង និងមធ្យោបាយ ដើម្បីសម្គាល់នូវផលិតផលកសិកម្មធម្មជាតិនៅកម្ពុជា។

ជារួម រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តនូវបញ្ញត្តិ និងគោលនយោបាយជាច្រើន ដើម្បីគាំទ្រដល់ការអភិវឌ្ឍកសិកម្មនៅកម្ពុជា។ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ កំពុងដើរតួនាទីយ៉ាងសំខាន់ ក្នុងការដឹកនាំគ្រប់គ្រង គាំទ្រ និងធានាថា សេចក្តីថ្លែងគោលនយោបាយ និងការប្តេជ្ញាចិត្តលើការអភិវឌ្ឍកសិកម្មទាំងឡាយអាចសម្រេចបាន ទន្ទឹមគ្នានោះធានាបាននូវសន្តិសុខនិងសុវត្ថិភាពស្បៀងនៅកម្ពុជា។ ទោះយ៉ាងណាក្តី សំណួរជាច្រើនដែលបានលើកឡើងខាងលើ នៅតែមិនទាន់បានឆ្លើយតប ហើយត្រូវទាមទារឲ្យមានការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការគាំទ្រក្រុមកសិករដែលមានដីធ្លីតូចតាចទាំងអស់ ក្នុងបរិបទចម្រុះភាពរបស់ពួកគាត់។

### ៣.២.២. គោលនយោបាយគាំទ្រអ្នកមានដីធ្លីធំ

រាជរដ្ឋាភិបាលកម្ពុជា បានលើកកម្ពស់ការវិនិយោគខ្នាតធំក្នុងវិស័យកសិកម្ម និងដំណាំកសិឧស្សាហកម្ម ក្នុងប្រទេសកម្ពុជា តាមរយៈការផ្តល់ដីសម្បទានសេដ្ឋកិច្ច ជាផ្នែកមួយនៃយុទ្ធសាស្ត្រ ផ្តោតលើការលូតលាស់សេដ្ឋកិច្ចក្នុងវិស័យកសិកម្ម។ ក្នុងឆ្នាំ២០០១ ច្បាប់ដីធ្លីថ្មីត្រូវបានអនុវត្ត ហើយលទ្ធភាពក្នុងការជួលដីសាធារណៈសម្រាប់ការវិនិយោគខ្នាតធំរហូតដល់ ៩៩ឆ្នាំ ត្រូវបានបញ្ជាក់។ ក្រុមហ៊ុនឯកជន អាចជួលដីរហូតដល់ ១០.០០០ ហិកតា ដោយផ្តល់ជាដីសម្បទានសេដ្ឋកិច្ច។ ក្រុមហ៊ុនសម្បទានទាំងអស់ តម្រូវឲ្យបង់ថ្លៃដីសម្បទានសេដ្ឋកិច្ចចាប់ពី០-១០ដុល្លារ/១ហិកតា/១ឆ្នាំនិងផ្អែកតាមផលិតកម្ម។ ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចទាំងឡាយ ត្រូវចាប់ផ្តើមសកម្មភាពអភិវឌ្ឍន៍ក្នុងរយៈពេល១២ខែបន្ទាប់ពីការផ្តល់ឲ្យ បើមិនដូច្នោះទេ ក្រុមហ៊ុនទាំងនោះអាចប្រឈមនឹងការលុបកិច្ចសន្យាចោល (RGC, 2001)។ ទោះយ៉ាងណាក្តី តម្លៃពន្ធត្រូវបានគេចាត់ទុកថា ស្ថិតក្នុងចំនួនទាបបំផុត ដែលមិនអាចដាក់សម្ពាធផ្នែកសេដ្ឋកិច្ចដល់ក្រុមហ៊ុនឲ្យវិនិយោគលើដីសម្បទានទាំងនោះ (Löhr, 2011) ហើយចំណូលរដ្ឋតាមរយៈការប្រមូលពន្ធ និងតម្លៃជួលដីសម្បទានសេដ្ឋកិច្ច ត្រូវបានប៉ាន់ប្រមាណថា នឹងមានចំនួនតិចតួចបំផុត (Sperffeldt et al., 2012; SRSG, 2007)។ ផ្អែកលើគោលការណ៍ថ្មីៗ ចេញផ្សាយនៅខែមេសា ឆ្នាំ២០១៥ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាទទួលបានចំណូលប្រមាណ ៨០ លានដុល្លារពីការជួលដីសម្បទានសេដ្ឋកិច្ច និងព្រៃឈើ ពីក្រុមហ៊ុនឯកជន ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ[2] ដែលតួលេខនេះ ត្រូវបានគេមើលឃើញថា មានចំនួនតិចតួចបំផុត បើប្រៀបធៀបទៅនឹងផ្ទៃដីដែលបានផ្តល់ឲ្យ។ ក្រុមហ៊ុនសម្បទានសេដ្ឋកិច្ចមួយចំនួនមិនបានបង់ប្រាក់ឈ្នួល ហើយក៏មានភស្តុតាងតិចតួច ដែលថាប្រាក់ចំណូលទាំងនេះ ត្រូវបានយកទៅវិនិយោគឡើងវិញដោយរដ្ឋាភិបាលក្នុងការអភិវឌ្ឍតំបន់សម្បទាន (Subedi, 2012)។ បញ្ញត្តិអំពីសម្បទានដីសេដ្ឋកិច្ចពេលនោះ ត្រូវបានបញ្ជាក់នៅក្នុងអនុក្រឹត្យលេខ ១៤៦ ស្តីអំពីសម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០០៥ ដែលកំណត់នូវនីតិវិធី យន្តការ និងការរៀបចំផ្សេងៗ សម្រាប់ការផ្តល់ដីរដ្ឋជាដីសម្បទានសេដ្ឋកិច្ច (RGC, 2005; Sperfeldt et al., 2012)។

យើងអាចធ្វើការបែងចែកដំណើរវិវឌ្ឍន៍ថ្មីៗ ស្តីពីគោលនយោបាយសម្បទានដីក្នុងប្រទេសកម្ពុជា ជា៣ ដំណាក់កាល (Sperfeldt et al., 2012)។ ដំណាក់កាលទី១៖ គឺពង្រីកចេញពីច្បាប់ដីធ្លីលើកទី១ ដែលដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ១៩៩២ និងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ រហូតដល់ការផ្សព្វផ្សាយជាសាធារណៈ នៃច្បាប់ដីធ្លីឆ្នាំ ២០០១។ រយៈពេលនេះ ត្រូវបានបែងចែកដោយគោលនយោបាយជាច្រើន ដែលមានទិសដៅលើកទឹកចិត្តដល់ការវិនិយោគឯកជន ដែលក្នុងរយៈពេលនេះ ការផ្តល់ដីសម្បទានរដ្ឋ ភាគច្រើន ជាសម្បទានព្រៃឈើ និងសម្បទានកសិកម្ម រហូតដល់ដំណាក់កាលចុងក្រោយក្នុងរយៈពេលនេះ។ ទោះយ៉ាងនេះក្តី ច្បាប់ដីធ្លីឆ្នាំ ១៩៩២ មិនបានគ្រប់គ្រងក្របខណ្ឌ និងកំណត់ការផ្តល់ដីសម្បទានសេដ្ឋកិច្ចទេ (Sperfeldt et al., 2012) ហើយនៅក្រៅច្បាប់នេះ

[2] Phnom Penh Post, *ELCs earning underwhelm,* 21 April 2015

ការផ្តល់សម្បទានក៏នៅតែកើតមាន (SRSG, 2004)។ ក្នុងដំណាក់កាលទី២ ដែលចាប់ផ្តើមជាមួយនឹងច្បាប់ដីធ្លីឆ្នាំ ២០០១ ក្របខណ្ឌគតិយុត្តថ្មីមួយ ត្រូវបានរៀបចំដោយពុំមានបញ្ញត្តិ និងយន្តការទាំងឡាយ ដើម្បីពង្រឹងច្បាប់ និងគ្រប់គ្រងការផ្តល់ដីសម្បទាន។ ចុងក្រោយ ដំណាក់កាលទី៣ ចាប់បន្តពីអនុក្រឹត្យស្តីអំពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច ឆ្នាំ២០០៥ និងយន្តការស្ថាប័នឆ្នាំ ២០០៦ សម្រាប់គោលនយោបាយសម្បទានដីថ្មីរហូតឆ្នាំ ២០១២។ ក្នុងដំណាក់កាលនេះ បន្ទាប់ពីក្របខណ្ឌគតិយុត្តថ្មីដែលពាក់ព័ន្ធទៅនឹងការផ្តល់ដីសម្បទាន ត្រូវបានអនុវត្តការផ្តល់ដីសម្បទានសេដ្ឋកិច្ចបានកើតឡើង ក្នុងដំណើរមួយយ៉ាងលឿន។ ក្នុងទំហំទ្រង់ទ្រាយធំ ដីត្រូវបានធ្វើសម្បទានក្នុងប្រទេសកម្ពុជា ទៅឲ្យវិនិយោគិនក្នុងស្រុក និងបរទេស ក្នុងរយៈពេលយ៉ាងយូរ ជាពិសេស ក្នុងកំឡុងឆ្នាំ ២០១០ និង២០១១ (Messerli et al., 2015; Sperfeldt et al., 2012)។ ឆ្នាំ ២០១២ ត្រូវបានគេមើលឃើញថា ជាឆ្នាំដែលមានការផ្លាស់ប្តូរជាច្រើន ទាក់ទងនឹងការផ្តល់ដីសម្បទានៈ សារាចរណែនាំលេខ០០១ (បទបញ្ជា ០១បប) ចេញនៅខែឧសភា ឆ្នាំ ២០១២ ដោយនាយករដ្ឋមន្ត្រី (RGC, 2012)។ វាបានកំណត់នូវការផ្អាកជាបណ្តោះអាសន្នការផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មី និងស្នើឲ្យមានការត្រួតពិនិត្យមើលឡើងវិញ នូវការផ្តល់ដីសម្បទានសេដ្ឋកិច្ចដែលមានស្រាប់ទាំងអស់ ដើម្បីពិនិត្យមើលនូវការអនុវត្តបញ្ញត្តិដែលមានស្រាប់ (ADHOC, 2013)។ នៅខែមិថុនា ឆ្នាំ ២០១២ យុទ្ធនាការថ្នាក់ជាតិ ត្រូវបានរៀបចំឡើង ក្នុងបំណងអនុវត្តនូវបទបញ្ជា ០១ ដោយធ្វើឲ្យមានលក្ខណៈផ្លូវច្បាប់ នូវការកាន់កាប់ដីមិនច្បាស់លាស់ក្នុងដែនដីសម្បទានសេដ្ឋកិច្ច និងចេញប័ណ្ណកម្មសិទ្ធិដីធ្លីជូនអ្នកកាន់កាប់ដីដែលកំពុងប្រើប្រាស់ និងបង្កបង្កើនផលលើដីនោះ។ ប្រភេទដីជាគោលដៅ គឺអាចបែងចែកជាបីប្រភេទគឺដីសម្បទានសេដ្ឋកិច្ច សម្បទានព្រៃឈើ និងដីដែលត្រូវបានរឹបអូសក្នុងតំបន់ ដែលគ្របដណ្តប់ដោយព្រៃឈើ (Im Chhun Lim, 2012)។ វាបានគាំទ្រ និងពង្រឹងគោលនយោបាយស្បែកខ្លារបស់រដ្ឋាភិបាល ក្នុងបំណងកាត់ចេញនូវតំបន់លំនៅដ្ឋានពីដីសម្បទាន និងកាត់បន្ថយការទន្ទ្រានដីដោយកសិករ និងសហគមន៍ (ADHOC, 2013)។

នាពេលបច្ចុប្បន្ន វាមានការលំបាកនៅក្នុងការប្រមាណនូវចំនួនដីសម្បទានពិតប្រាកដដោយសារតួលេខមានចំនួនផ្សេងគ្នា យោងតាមប្រភពដែលបានធ្វើការពិចារណា (ADHOC, 2014; Sperfeldt, 2012)។ ប្រភពព័ត៌មានពីគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ[3] បានបង្ហាញថា រហូតដល់ខែមិថុនា ឆ្នាំ ២០១២ មានក្រុមហ៊ុនចំនួន ១១៨ ត្រូវបានផ្តល់ដីសម្បទានសេដ្ឋកិច្ច ក្នុងទំហំផ្ទៃដីសរុបចំនួន ១.២០៤.៧៥០ហិកតា។ ទោះយ៉ាងនេះក្តី តួលេខនេះត្រូវបានគេដឹងថា មិនទាន់បានធ្វើបច្ចុប្បន្នភាព ហើយនៅមិនទាន់ចាត់ទុកជាតួលេខជាក់ស្តែងនៅឡើយ (ADHOC, 2013; Subedi, 2012)។ ក្នុងចំណោមប្រភពផ្សេងទៀត អង្គការអូឌីស៊ី[4] (Open Development Cambodia) បានបង្ហាញថា យ៉ាងហោចណាស់ មានក្រុមហ៊ុនដីសម្បទានចំនួន ១៩១ ក្រុមហ៊ុន និងមានផ្ទៃដីសរុប ១.៤៨៣.០២៦ ហិកតា ដែលពួកគេបានរកឃើញនូវឯកសារគតិយុត្តផ្លូវការពីប្រភពរដ្ឋាភិបាល

[3] http://www.elc.maff.gov.kh/, consulted in March 2015

[4] http://www.ioebdevelopmentcambodia.net/maps/downloads/page/2/, consulted in March 2015

ដែលនាំឲ្យគេអាចកំណត់បាននូវធាតុសំខាន់ៗ ៤ គឺៈ ឈ្មោះក្រុមហ៊ុន ទីតាំង (និយាមគោល ឬ និយាមភូមិសាស្ត្រ) និងគោលបំណងនៃដីសម្បទាន។ អង្គការលីកាដូ បានធ្វើបញ្ជីក្រុមហ៊ុនដីសម្បទានចំនួន ២៧២ ដែលបានផ្តល់ដីសម្បទានសរុបចំនួន ២.១៤១.១៤៦ហិកតា[5] ហើយអង្គការនេះ បានរាយការណ៍ពីក្រុមហ៊ុនចំនួន ២២៥ ដែលត្រូវបានផ្តល់ដីសម្បទានសេដ្ឋកិច្ច ក្នុងទំហំផ្ទៃដី ២.៦៥៧.៤៧០ហិកតា (ADHOC, 2014; ADHOC, 2013)។ ទោះបីជាយ៉ាងណាក៏ដោយមន្ត្រីរដ្ឋាភិបាលបានច្រានចោលនូវតួលេខទាំងនេះ។

ទោះបីមានប្រភពតួលេខផ្សេងគ្នាដូច្នេះ វាអាចគូសបញ្ជាក់ថា ក្រុមហ៊ុនឯកជនភាគច្រើនត្រូវបានផ្តល់ដីសម្បទានរដ្ឋសម្រាប់កសិកម្ម និងដំណាំកសិឧស្សាហកម្ម ដូចជា ចម្ការកៅស៊ូ ចម្ការឈើផ្សេងៗ (ចម្ការស្រល់អាកាស្យា) ដំណាំអំពៅ និងដំឡូងមី។ វិនិយោគិនជាតិដែលទទួលបានដីសម្បទានមានចំនួនច្រើន ហើយក្នុងចំណោមវិនិយោគិនបរទេសចិន និងវៀតណាម ជាវិនិយោគិនសំខាន់ គិតទាំងចំនួនក្រុមហ៊ុន និងទំហំដីសម្បទានទទួលបាន ពិសេសសម្រាប់ការដាំដុះដំណាំកៅស៊ូ (Messerli et al., 2015; Schönweger et al., 2014)។ គួរកត់សម្គាល់ថា ទោះបីការផ្តល់ដីសម្បទានសេដ្ឋកិច្ចភាគច្រើន ត្រូវបានកាន់កាប់ដោយបុគ្គល ឬ ក្រុមហ៊ុនកម្ពុជាក៏ដោយ ក៏រចនាសម្ព័ន្ធភាពជាម្ចាស់ ជួនកាលមានសភាពស្មុគស្មាញក្នុងការកំណត់ផងដែរ។ ហេតុដូចនេះ វាមានការលំបាកដើម្បីដឹងច្បាស់ថា តើម្ចាស់ក្នុងស្រុកមួយចំនួននោះ មានភាពជាដៃគូជាមួយវិនិយោគិនបរទេស ឬយ៉ាងណា ដោយសារថាមានព័ត៌មានតិចតួចប៉ុណ្ណោះដែលអាចស្វែងរកបានពីការរកស៊ីរួមគ្នានេះ (Sperfeldt et al., 2012)។

ទោបីជាមានទិន្នន័យជាច្រើន ស្តីអំពីដីសម្បទានសេដ្ឋកិច្ច និងកាតព្វកិច្ចរបស់ក្រុមហ៊ុនសម្បទាន ដើម្បីធ្វើការអភិវឌ្ឍយ៉ាងពិតប្រាកដ នូវគម្រោងកសិឧស្សាហកម្មដែលត្រូវបានគេមើលឃើញយ៉ាងណាក៏ដោយ ក៏កម្រិតនៃការអនុវត្តស្ថិតក្នុងភាពមិនច្បាស់លាស់ ដោយពុំមានព័ត៌មានច្បាស់លាស់ ដែលអាចរកបាន។ នេះអាចលើកជាសំណួរបានថា តើក្រុមហ៊ុនទាំងនោះ គ្រាន់តែចង់កាប់ឈើក្នុងតំបន់សម្បទាន ឬយ៉ាងណា (SRSG, 2007)។ ក្នុងករណីនេះ ការផ្តល់ដីសម្បទានសេដ្ឋកិច្ច បម្រើជាបរិបទបឋម សម្រាប់ការកាប់ឈើ។ ដូចដែលបានបញ្ជាក់ពីមុននេះ ប្រាក់ឈ្នួលពីការជួលដីក្នុងតម្លៃទាប នៅមិនទាន់ គ្រប់គ្រាន់ ដើម្បីជំរុញឲ្យក្រុមហ៊ុនសម្បទាន អនុវត្តនូវគម្រោងរបស់គេទេ (Löhr, 2011)។ លើសពីនេះ ទំហំដីសម្បទានមួយចំនួន ត្រូវបានរាយការណ៍ថា មានទំហំលើស ១០.០០០ហ.ត ពីការកំណត់ ហើយការផ្តល់សម្បទាន ១០.០០០ហ.ត មួយចំនួនទៀត ត្រូវបានផ្តល់ដល់ក្រុមហ៊ុនផ្សេងគ្នា ដែលមានឈ្មោះ ប្រហាក់ប្រហែលគ្នា ហើយប្រាកដណាស់ថា ក្រុមហ៊ុនទាំងនោះជារបស់ក្រុមមនុស្សតែមួយ។

ជាចុងបញ្ចប់ វាមានតម្លៃសម្រាប់កត់ចំណាំថា បើទោះជាដីសម្បទានសង្គមកិច្ច (RGC, 2003) ដែលអនុញ្ញាតឲ្យមានការបែងចែកដីទៅដល់កសិករអត់ដីធ្លី ត្រូវបានដាក់ចុះនៅក្នុងគោលនយោបាយផ្សេងគ្នា ក៏ការផ្តល់

[5] http://www.locadho-cambodia.org/land concessions/, consulted in April 2015

ដីសម្បទានសេដ្ឋកិច្ច ទទួលបានសារៈសំខាន់ច្រើនជាង ក្នុងន័យទំហំដីសម្បទាន ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ (ADHOC, 2014; Sperfeldt, 2012)។

### ៣.២.៣. ផលវិបាកនៃគោលនយោបាយដីសម្បទានសេដ្ឋកិច្ចចំពោះគ្រួសារដែលមានដីធ្លីតូចតាច

ផលប៉ះពាល់នាពេលបច្ចុប្បន្ន ពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច ចំពោះកសិករដែលមានដីធ្លីតូចតាច មានកម្រិតធ្ងន់ធ្ងរ និងមានច្រើនកុះករ។ ទាំងនោះរួមមាន៖ បញ្ហាសិទ្ធិមនុស្ស ការបំផ្លិចបំផ្លាញបរិស្ថាន ការបាត់បង់កម្មសិទ្ធិដីធ្លី ការបណ្តេញចេញដោយបង្ខំ ការផ្លាស់ទីលំនៅ ការបាត់បង់ឱកាសស្វែងរកធនធានធម្មជាតិ និងការផ្លាស់ប្តូរការប្រកបរបរចិញ្ចឹមជីវិតជាដើម។

ក្នុងន័យសិទ្ធិមនុស្ស ជាតុសំខាន់ៗមួយចំនួន អាចត្រូវបានគូសបញ្ជាក់៖ កង្វះការប្រឹក្សាយោបល់ជាមួយសហគមន៍ក្នុងតំបន់ នៅពេលដីត្រូវបានផ្តល់ជាសម្បទាន ដែលនាំទៅរកភាពក្រីក្រ និងជម្លោះ ទាំងជាមួយក្រុមហ៊ុន និងអាជ្ញាធរដែនដី ការលំបាកក្នុងការចុះបញ្ជីក្រុមជនជាតិដើមភាគតិចជានីតិបុគ្គល ដែលអនុញ្ញាតិឲ្យពួកគាត់អភិរក្សបាននូវវប្បធម៌ ភាសា និងការអនុវត្តកសិកម្មប្រពៃណី និងការស្នើឲ្យមានជាប័ណ្ណកម្មសិទ្ធិដីសមូហភាព ការទន្ទ្រានកាន់កាប់តំបន់វប្បធម៌និងព្រៃអារក្ខ ការបណ្តេញចេញដោយបង្ខំ ការផ្លាស់ទីលំនៅ និងការផ្លាស់ប្តូរទីតាំងសហគមន៍ ការប្រើកម្លាំងយោធាក្នុងដីសម្បទាន ដែលនាំឲ្យមានការបំភិតបំភ័យ និងអំពើហិង្សា ដោយឆ្មាំសន្តិសុខប្រដាប់អាវុធ កង្វះយន្តការដោះស្រាយប្រកបដោយប្រសិទ្ធភាពសម្រាប់សហគមន៍រងផលប៉ះពាល់ (Subedi, 2012)។ នៅពេលការបណ្តេញចេញកើតមាន ហើយប្រជាជនត្រូវបានផ្លាស់ប្តូរទីលំនៅចេញពីផ្ទះសម្បែង និងដីស្រែចម្ការរបស់ពួកគាត់ ទីតាំងទាំងនោះ មិនត្រូវបានគេរៀបចំរៀបរយ ឲ្យមានទឹកស្អាតប្រើប្រាស់ បង្គន់អនាម័យ សេវាសុខាភិបាល និងអប់រំ ហើយផ្តល់ឱកាសតិចតួច ក្នុងការការស្វែងរកការងារធ្វើ ឬការរកប្រាក់ចំណូលរបស់ពួកគាត់ (Subedi, 2014; Subedi, 2012)។

បើទោះជាគោលនយោបាយដែលមានស្រាប់ ផែនការ និងគំនិតផ្តួចផ្តើមថ្មីៗរបស់រដ្ឋាភិបាល សម្រាប់ដោះស្រាយជម្លោះដីធ្លី ក៏ជាទូទៅនៅមានកង្វះតម្លាភាព គណនេយ្យភាព និងអវត្តមានយន្តការដោះស្រាយជម្លោះប្រកបដោយប្រសិទ្ធភាព។ សំណួរជាច្រើនត្រូវបានលើកឡើងពីឯករាជ្យភាព និងប្រសិទ្ធភាពនៃបេសកកម្មចុះវាស់វែងដីធ្លី និងអាជ្ញាធរជាតិ ចំពោះដំណោះស្រាយជម្លោះដីធ្លី។ កង្វះប្រព័ន្ធតុលាការឯករាជ្យ និងយន្តការដោះស្រាយជម្លោះដីធ្លីប្រកបដោយគ្មានប្រសិទ្ធភាព មិនបានអនុញ្ញាតិឲ្យដើមបណ្តឹងទទួលបាននូវការដោះស្រាយស្របច្បាប់ចំពោះការរំលោភបំពានសិទ្ធិមកលើពួកគាត់ ឬ ការដោះស្រាយជម្លោះឡើយ (Subedi, 2014)។

បន្ថែមលើសនេះ គម្រោងផ្តល់ដីសម្បទានសេដ្ឋកិច្ច កំពុងបង្កើតឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះបរិស្ថាន។ គម្រោងនេះ ជាធម្មតា គួរណាស់ផ្តល់តែប្រភេទដីព្រៃណាដែលរិចរិល ឬដីដែលមិនត្រូវបានប្រើប្រាស់តែផ្ទុយទៅវិញ បង្កើតឡើងក្នុងតំបន់ព្រៃមានតម្លៃ និងតំបន់ការពារ ដូចជាឧទ្យានជាតិទៅវិញ (Sperfeldt et al., 2012; Subedi 2012)។ ក្តីបារម្ភ ជាសំខាន់ គឺការបំផ្លិចបំផ្លាញបរិស្ថាន ផលប៉ះពាល់លើជីវចម្រុះ ការដាំដំណាំ ឬ

ប្រភេទឈើដែលមិនមែនជាប្រភេទតាមធម្មជាតិរបស់វា និងការកាប់ឈើ ដោយខុសច្បាប់ក្នុងដីព្រៃសម្បទានជាដើម។ បញ្ហាផ្សេងៗទៀត ដែលបង្កើតឡើងតាមរយៈការផ្តល់ដីសម្បទានសេដ្ឋកិច្ច រួមមានផងដែរ ការហូរច្រោះដី និងការធ្វើឲ្យកខ្វក់ទឹក (Subedi 2012)។ លើសពីនេះ ការអនុវត្តបានតិចតួចនូវបញ្ញត្តិបរិស្ថាន បានធ្វើឲ្យប៉ះពាល់នូវសិទ្ធិជាវប្បធម៌របស់ជនជាតិដើមភាគតិច និងមិនមែនជនជាតិដើមភាគតិច នៅពេលដីដែលត្រូវបានកាន់កាប់ជាប្រពៃណី ប្រឈមនឹងការទន្ទ្រាន និងការអភិវឌ្ឍដែលមិនអាចគ្រប់គ្រងបាន (ADHOC 2013; Subedi 2012)។

ក្នុងន័យផលវិបាកលើការប្រកបរបរចិញ្ចឹមជីវិតរបស់កសិករដែលមានដីធ្លីតូចតាច ស្ថានភាព និងផលប៉ះពាល់ជាច្រើន មានភាពផ្សេងគ្នា ទៅតាមតំបន់ និងក្រុមពលរដ្ឋ ក៏ប៉ុន្តែ ធាតុកើតឡើងថ្មីមួយចំនួន អាចត្រូវបានគូសបញ្ជាក់។ ការទន្ទ្រានលើដីកសិកម្ម និងការបាត់បង់ជាពិសេស នៃទ្រព្យសម្បត្តិ ត្រូវបានជួបប្រទះដោយកសិករ រួមនឹងការបាត់បង់លទ្ធភាពទទួលបាននូវធនធានធម្មជាតិ ដែលមានការថយចុះ និងផលិតផលព្រៃឈើ ដែលនាំទៅដល់ការផ្លាស់ប្តូរជាចម្បង ក្នុងបរិស្ថានរបស់ពួកគាត់ និងការបាត់បង់ការប្រកបរបរចិញ្ចឹមជីវិត ជាប្រពៃណីរបស់ពួកគាត់។ វាត្រូវបានប៉ាន់ប្រមាណថា ប្រជាជនប្រមាណ ៤២០.០០០នាក់ ទទួលរងផងប៉ះពាល់ពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងការរឹបអូសដីផ្សេងទៀត ចាប់តាំងពីឆ្នាំ ២០០៣មក (LICADHO, 2014)។

ការបាត់បង់ទ្រព្យសម្បត្តិ មានចាប់ពី ១) ធ្ងន់ធ្ងរៈ ការបាត់បង់ដីទាំងអស់ និងរាប់បញ្ចូលសំណង់មួយចំនួន ឬ/និង ផ្លាស់ប្តូរទីតាំង និងការតាំងទីលំនៅថ្មីរបស់ប្រជាជន ២)មធ្យមៈ មិនមានការបណ្តេញចេញ ប៉ុន្តែមិនមានដីគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការ និង ៣) កម្រិតស្រាលៈ មានដីគ្រប់គ្រាន់ដើម្បីរក្សាសកម្មភាពកសិកម្ម ដើម្បីបំពេញសេចក្តីត្រូវការ។ កម្រិតនៃផលប៉ះពាល់ ក៏អាស្រ័យលើទំហំដីជាតម្រូវការ ភាពអាចរកបាននៃដីជាទូទៅក្នុងចំណោមតំបន់ប៉ះពាល់ចម្ងាយនៃសម្បទានដីទៅនឹងតំបន់ដែលត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋ និងចុងបញ្ចប់គឺជំហាននៃការអនុវត្តការផ្តល់ដីសម្បទានសេដ្ឋកិច្ច (Gironde et al., 2014)។ សម្រាប់ប្រជាជនដែលជួបការបណ្តេញចេញ ការផ្លាស់ប្តូរទីតាំង និងការតាំងទីលំនៅថ្មី ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ នឹងនៅតែពឹងអាស្រ័យជាចម្បង ទៅលើឱកាសដែលផ្តល់ឲ្យនៅទីតាំងថ្មី។ ប្រជាជននៅក្នុងចំណាត់ថ្នាក់ផ្សេង ដែលត្រូវបានរៀបរាប់មកហើយនោះ ច្បាស់ណាស់នឹងប្រឈមការបាត់បង់ដីធ្លី ឬ ខ្វះដី និងប្រឈមនឹងបញ្ហាលំបាកដែលគិតទុកជាមុនក្នុងការរក្សាការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់។

ក្រៅពីផលប៉ះពាល់ភ្លាមៗ ពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច ផលវិបាកនៃការប្រកបរបរចិញ្ចឹមជីវិត គួរត្រូវបានប៉ាន់ប្រមាណ នៅក្នុងដំណាក់កាលអន្តរកាលនេះ។ គ្រួសារដែលមានដីធ្លីតូចតាច ជាពិសេស ក្រុមជនជាតិភាគតិច ដែលអាចប្រឈមនឹងការបាត់បង់ទ្រព្យសម្បត្តិ នៅពេលនោះ នឹងត្រូវប្រឈមនឹងអន្តរកាលដីធ្លី។ អន្តរកាលដីធ្លី អាចយល់បានថា ជាការផ្លាស់ប្តូរដ៏សំខាន់នៃកសិកម្ម តួនាទីរបស់វាក្នុងសង្គម ការផ្លាស់ប្តូរទំនាក់ទំនងរបស់ប្រជាពលរដ្ឋ ជាមួយនឹងបរិស្ថាន (Castella, 2007)។ ដំណើរការនេះ បាននឹងកំពុងកើតឡើង និងផ្តួចផ្តើមដោយគោលនយោបាយសាធារណៈ មុនពេលផ្ទុះឡើងនូវការផ្តល់ដីសម្បទានសេដ្ឋកិច្ច ដូចជាការផ្សព្វផ្សាយបច្ចេកទេសទំនើប និងការអភិវឌ្ឍមូលដ្ឋានទីផ្សារ នៃដំណាំទីផ្សារ។ ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ពិសេសក្រោយ

ឆ្នាំ ២០០៥ បានបង្កើននូវជំហានមួយយ៉ាងធំ នៃការផ្លាស់ប្តូរការប្រកបរបរចិញ្ចឹមជីវិតអ្នកជនបទ និងផ្លាស់ប្តូរនូវបរិស្ថានសេដ្ឋកិច្ចសង្គម ដែលត្រូវបានកំណត់លក្ខណៈ ដោយតម្រូវការកើនឡើងនៃសាច់ប្រាក់ (Gironde et al, 2014)។ នាពេលបច្ចុប្បន្ន កសិករបានជួបនូវការផ្លាស់ប្តូរមិនស្មើគ្នាលើប្រព័ន្ធចិញ្ចឹមជីវិតជនបទរបស់ពួកគាត់ និងដំណើរការមួយនៃភាពផ្សេងគ្នាផ្នែកសេដ្ឋកិច្ច និងសង្គម ជាការគម្រាមកំហែង និងឱកាសដែលកើតចេញពីបរិស្ថានសេដ្ឋកិច្ចសង្គមថ្មី ដែលមិនប៉ះពាល់ដល់ប្រជាពលរដ្ឋ តាមរបៀបតែមួយ (Gironde et al, 2014)។

ការសិក្សានៅភាគពាយ័ព្យនៃប្រទេសបានបង្ហាញថា គេអាចធ្វើការបែងចែកក្រុមប្រជាពលរដ្ឋជាក្រុមផ្សេងគ្នាដោយផ្អែកលើថា តើគេទទួលរងផលប៉ះពាល់យ៉ាងដូម្តេច ហើយអាចឆ្លើយតបទៅនឹងការបាត់បង់ដីធ្លី និងការផ្លាស់ប្តូរជាសំខាន់នៃសកម្មភាពសេដ្ឋកិច្ចរបស់ពួកគាត់បានយ៉ាងណា (Gironde Senties Portilla, 2015; Geronde et al., 2014)។ វាត្រូវបានគេរាយការណ៍ថា ប្រមាណពាក់កណ្តាលនៃចំនួនប្រជាពលរដ្ឋដែលបានសិក្សា មានកសិករដែលធ្វើការមិនពេញម៉ោង ដែលសកម្មភាពកសិកម្មរបស់ពួកគាត់ មិនគ្រប់គ្រាន់ និងការកើនឡើងនៃការងារផ្តល់ប្រាក់ខែ ក្នុងចំណូលសរុបរបស់ពួកគាត់។ ពួកគាត់បានទុកដីមួយចំនួន ជាមូលដ្ឋានសម្រាប់ការប្រកបរបរចិញ្ចឹមជីវិត ប៉ុន្តែមិនអាចធ្វើការដាំដុះនូវដំណាំផ្សេងទៀតបាន ដូចជា ដំណាំកៅស៊ូជាដើម។ ក្តីសង្ឃឹមក្នុងពេលអនាគតរបស់ពួកគាត់ ពឹងអាស្រ័យជាសំខាន់ទៅលើការប្រកួតប្រជែងពីកម្មករផ្សេងៗ ជនចំណូលស្រុក ប៉ុន្តែប្រហែលជាអាចលើកកម្ពស់ទិសដៅការអភិវឌ្ឍ នៃបណ្តាញសង្គមដែលរីកចម្រើនរបស់ពួកគាត់។ ក្រុមមួយទៀតដែលមានប្រមាណ ៣០% នៃប្រជាពលរដ្ឋរងផលប៉ះពាល់ ដែលរួមបញ្ចូលនូវកម្មករធ្វើការក្នុងទីជនបទដែលការងារប្រាក់ខែគឺជាប្រភពប្រាក់ចំណូលសំខាន់មិនមានឱកាសចូលរួមក្នុងការដាំដុះប្រភេទដំណាំថ្មីបាន។ ជួនកាលប្រជាជនទាំងនេះជួបប្រទះនូវការបាត់បង់ដីធ្លីពីមធ្យមទៅធ្ងន់ធ្ងរ ហើយជាអ្នកដែលមានដីធ្លីតិចតួច ឬអត់ដី ប្រឈមការផ្លាស់ប្តូរទីតាំង និងការតាំងទីលំនៅថ្មី។ ដោយឱកាសការងារផ្តល់ជូនមានកម្រិត ការធ្វើចំណាកស្រុកនៃសមាជិកក្នុងគ្រួសារមានការកើនឡើង។ ជារឿយៗ ក្រុមនេះត្រូវបង្ខំចិត្តលក់ដូរទ្រព្យសម្បត្តិដែលនៅសេសសល់ដោយសារស្ថានភាពនៃតម្រូវការផ្នែកហិរញ្ញវត្ថុរបស់គាត់។ ជាចុងបញ្ចប់ មិនដល់ ១ភាគ៣ (ប្រមាណ២៣%) នៃប្រជាពលរដ្ឋដែលបានសិក្សា ដែលអាចចូលរួមក្នុងសកម្មភាពដាំដុះប្រភេទដំណាំថ្មី និងទទួលបានអត្ថប្រយោជន៍ពីវា។ ក្នុងចំណោមពួកគាត់ គេអាចធ្វើការបែងដាច់ដោយឡែកនូវក្រុមមានឥទ្ធិពល ដែលតំណាងឲ្យភាគរយតិចតួចប្រជាជនដែលរស់ដោយសកម្មភាពមិនមែនកសិកម្មបានអភិវឌ្ឍ ដោយមានទំនាក់ទំនងទៅនឹងចលនាដីធ្លី និងការរីកចម្រើននៃដំណាំ តួយ៉ាងដូចជា ម្ចាស់ហាង ឈ្មួញកណ្តាល អ្នកផ្តល់សេវាកម្ម (ដឹកជញ្ជូន ការផ្តល់ប្រាក់កម្ចី អ្នកលក់ម្ហូប ភោជនីដ្ឋាន អ្នកជួញដូរ) តំណាងឲ្យតែ ៧% និងចុងក្រោយបំផុត ១២%នៃគ្រួសារ ដែលការងារកសិកម្ម នៅជាសកម្មភាពសំខាន់ និងការកើនឡើងនៃដីធ្លីរបស់ពួកគាត់ ដើម្បីដាំដុះដំណាំទីផ្សារ ប៉ុន្តែដំណើរការផ្លាស់ប្តូរនៅមានដំណើរការយឺត ដោយសារពួកគាត់មិនមានមូលធនគ្រប់គ្រាន់សម្រាប់ការវិនិយោគបន្ថែមលើដំណាំទីផ្សារ (Gironde and Senties Portilla, 2015; Gironde et al., 2014)។ ក្តីរំពឹងក្នុងដំណាក់កាលអន្តរកាលនេះបានបង្ហាញថា ប្រជាពលរដ្ឋភាគច្រើននៅជុំវិញតំបន់សម្បទានសេដ្ឋកិច្ច កំពុងប្រឈមក្នុងដំណាក់កាលផ្លាស់ប្តូរនៃសកម្មភាពសេដ្ឋកិច្ច និងការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ ដែលជាលទ្ធផលចេញមកពីការផ្តល់ដីសម្បទាន

សេដ្ឋកិច្ចនេះ។ មានតែប្រជាពលរដ្ឋតិចតួចប៉ុណ្ណោះ មានសមត្ថភាពឆ្លើយតបទៅនឹងការផ្លាស់ប្តូរ ដោយចូលរួមធ្វើការដាំដុះនូវប្រភេទដំណាំថ្មីៗ ដូចជា កៅស៊ូ ដំឡូងមី ឬ អំពៅ។ ហើយសម្រាប់អ្នកដែលត្រៀមប្រើប្រាស់នូវពូជថ្មី ឬ ធាតុចូលដែលអាចរកបានដើម្បីផលិតដំណាំទីផ្សារ ជារឿយៗ ពួកគាត់មានបណ្តាញទីផ្សារតិចតួច អ្នកដែលត្រូវបានអភិវឌ្ឍដោយក្រុមហ៊ុនធំៗ ដើម្បីលក់ផលិតផលរបស់ពួកគាត់។ ស្ថានភាពនេះមានន័យថា ពួកគាត់ខ្វះនូវអំណាចនៃការចរចាតម្លៃ និងទទួលបានតម្លៃទាបសម្រាប់ផលិតផលរបស់ពួកគាត់។

ជាមួយនឹងអត្រាផ្តល់ការងារធ្វើលើផ្ទៃដី២០ហ.ត/១នាក់ និង៤០ហ.ត លើការងារបណ្តោះអាសន្ន សម្រាប់ការវិនិយោគដីនៅអាស៊ាន[6] ប្រាក់ខែដែលផ្តល់ដោយការវិនិយោគទ្រង់ទ្រាយធំ មានកម្រិតតិចតួចបំផុត (Mirza et al., 2015)។ លើសពីនេះ បុរសមានឱកាសច្រើនជាងស្ត្រី ហើយជនភាគតិចខ្មែរ ក៏មានឱកាសច្រើនជាងជនជាតិដើម។ ជាធម្មតា មានការងារដែលត្រូវការជំនាញទាប ត្រូវបានផ្តល់នៅពេលដំបូងនៃការចាប់ផ្តើមនៃសម្បទាន និងការងារដែលត្រូវការជំនាញតិចតួច ដែលត្រូវបានផ្តល់ឲ្យនៅពេលដំណាំកំពុងដុះលូតលាស់។ រលកដំបូងនៃការងារជាទូទៅត្រូវបានចាប់យកដោយប្រជាពលរដ្ឋក្នុងស្រុក ប៉ុន្តែស្ថិតក្នុងរយៈពេលមួយមានកំណត់។ ការងារជាប់លាប់ជាច្រើន ត្រូវបានចាប់យកដោយអ្នកមានជំនាញ ហើយប្រជាពលរដ្ឋក្នុងស្រុក ស្ថិតក្នុងការប្រកួតប្រជែងជាមួយអ្នកខាងក្រៅដែលមានបទពិសោធន៍ច្រើនជាង។ ករណីនេះ កើតមានជាពិសេសលើចម្ការកៅស៊ូ។ បើទោះបីការងារមានកម្រិតសម្រាប់ប្រជាជនក្នុងស្រុក ការងារទាំងនេះ អាចផ្តល់នូវស្វ័យភាព សម្រាប់យុវជនក្នុងស្រុក ដោយសារពួកគេអាចធ្វើការសម្រេចចិត្ត លើចំណែកនៃប្រាក់ចំណូលរបស់ពួកគេ ដែលពួកគេចង់រក្សាទុកដោយខ្លួនឯង (Gironde and Senties Portilla, 2015)។ ដោយសារការខ្សត់ដី កើតមាននៅតំបន់មួយចំនួន និងឱកាសការងារមានកម្រិតសម្រាប់ប្រជាជនក្នុងស្រុក យុទ្ធសាស្ត្របានលេចចេញមកនៃប្រជាពលរដ្ឋក្នុងស្រុក ក៏រួមបញ្ចូលការធ្វើចំណាកស្រុក ដែលកិច្ចការនេះភាគច្រើនមិនបានប្រុងប្រៀបទុកជាមុន (Gironde, 2014)។

## ៣.៣. បញ្ហាប្រឈម និងក្តីសង្ឃឹមក្នុងការគាំទ្រគ្រួសារកសិករដែលមានដីធ្លីតូចតាច

### ៣.៣.១. ក្របខណ្ឌវិភាគនៃការសិក្សា

លទ្ធផលទទួលបានពីអ្នកផ្តល់ព័ត៌មានសំខាន់ៗថ្នាក់ជាតិបានបង្ហាញនូវប្រព័ន្ធស្មុគស្មាញ ក្នុងការគាំទ្រគ្រួសារដែលមានដីធ្លីតូចតាច ដោយរួមទាំងកត្តាប្រឈម និងក្តីសង្ឃឹមផងដែរ។ ផលិតកម្មស្បៀង ជាលក្ខណៈគ្រួសារ គឺជាចំណុចចាប់ផ្តើម និងជាអាទិភាព សម្រាប់គ្រួសារកសិករដែលមានដីធ្លីតូចតាច ដោយសារថា ភាគច្រើននៃពួកគាត់ នៅជាកសិករដែលធ្វើកសិកម្មចិញ្ចឹមឆ្នាំងនៅឡើយ។ នាពេលបច្ចុប្បន្ន ផលិតកម្មក្នុងស្រុកមានអតិផរណា ហើយអតិផរណានេះ ក៏អាស្រ័យទៅតាមកម្រិតនៃការផ្គត់ផ្គង់ ទៅតាមប្រភេទកសិផលផងដែរ។ ទោះយ៉ាងនេះក្តី វាត្រូវបានគេទទួលស្គាល់ថា ការផ្សារភ្ជាប់គ្រួសារកសិករខ្នាតតូចទៅកាន់ទីផ្សារ គឺជាចលករសំខាន់មួយនៃ

[6] ជាការប៉ាន់ប្រមាណ ការផ្តល់ដីសម្បទានលើដីទំហំ ១០.០០០ហិកតា អាចបង្កើតការងារអចិន្ត្រៃយ៍បានប្រមាណ ៥០០ និងការងារបណ្តោះអាសន្ន ប្រមាណ ២៥០។

កំណើនសេដ្ឋកិច្ច ក៏ប៉ុន្តែនឹងមិនទទួលបានជោគជ័យឡើយ ដរាបណាសេចក្តីត្រូវការក្នុងគ្រួសារមិនទាន់បានបំពេញនៅឡើយ។ ការពង្រីកផលិតកម្ម ឲ្យឆ្លងផុតពីការប្រើប្រាស់ក្នុងគ្រួសារ ទាមទារនូវការវិនិយោគជាច្រើននូវពេលវេលា ធនធានហិរញ្ញវត្ថុ និងកិច្ចខិតខំប្រឹងប្រែង ដែលកិច្ចការទាំងនេះតម្រូវឲ្យមានការចូលរួមពីរាជរដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិលផងដែរ។ ការតភ្ជាប់កសិករទៅកាន់ទីផ្សារមានន័យថា ធ្វើការកំណត់ជាទៀងទាត់នូវគំរូផ្គត់ផ្គង់ ដើម្បីធានាថា កសិករអាចទទួលបាននូវអត្ថប្រយោជន៍ ពីផលិតកម្មកសិកម្មជាបន្តបន្ទាប់។ ការធ្វើផែនការផលិត និងជំនាញក្នុងការរៀបចំក្រុមអ្នកផលិត គឺជារឿងចាំបាច់។ កសិករចាំបាច់ត្រូវរៀបចំគ្នាជាក្រុមឲ្យបានល្អ ដើម្បីមានលទ្ធភាពចូលទៅកាន់ទីផ្សារ។ ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព អាស្រ័យលើការគាំទ្រដល់ការធ្វើកសិកម្មសម្រាប់ការលក់ដូរ ជាជាងការផលិតសម្រាប់ហូប និងការគាំទ្រការធ្វើជំនួញនូវអ្វីដែលនៅសេសសល់។

យើងជឿជាក់ថា ដើម្បីលើកកម្ពស់ផលិតកម្ម និងរក្សាបាននូវអត្ថប្រយោជន៍ ការផ្សារភ្ជាប់កសិករទៅកាន់ទីផ្សារ គួរត្រូវបានពង្រីកពីផ្សារក្នុងតំបន់ ទៅទីផ្សារក្នុងទីក្រុង និងបន្ទាប់មកទៅកាន់ទីផ្សារនាំចេញ។ ដើម្បីធ្វើដូចនេះបាន គឺមិនត្រឹមតែធ្វើការបង្កើននូវចំនួនលក់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវធានាឲ្យបានលើគុណភាព និងការកំណត់នូវប្រភេទផលិតផលផងដែរ។ អ្នកផលិតត្រូវតែគោរពនូវច្បាប់អាជីវកម្ម ដូចជាបរិមាណផ្គត់ផ្គង់ ពេលវេលាផ្គត់ផ្គង់ គុណភាព និងតម្រូវការជាក់លាក់ក្នុងការផ្គត់ផ្គង់ផងដែរ។ ប្រសិនបើអ្នកផលិត ខកខានមិនបានគោរពតាមលក្ខខណ្ឌតម្រូវការនេះទេ ផលិតផលដែលត្រូវផ្គត់ផ្គង់ នឹងត្រូវត្រឡប់មកអ្នកផលិតវិញ។ វាច្បាស់ណាស់ថា នៅពេលស្តង់ដាសុវត្ថិភាពចំណីអាហារ មិនឆ្លើយតបនឹងលក្ខខណ្ឌទីផ្សារនាំចេញ។ អ្នកផ្តល់បទសម្ភាសន៍សំខាន់ៗជឿជាក់ថា ក្នុងករណីនោះ មានតែផ្សារក្នុងស្រុក និងការកែច្នៃក្នុងស្រុកប៉ុណ្ណោះ អាចប្រើប្រាស់នូវទំនិញដែលមិនអាចនាំចេញបាន។ អ្នកផ្តល់ព័ត៌មានសំខាន់ៗមួយចំនួនមានទុទ្ទិដ្ឋិនិយម ចំពោះលទ្ធភាពក្នុងការបង្កើនទីផ្សារនាំចេញ នៅពេលដែលផ្សារក្នុងស្រុក និងការកែច្នៃក្នុងស្រុក នៅមិនទាន់អភិវឌ្ឍន៍នៅឡើយ។ ក្នុងករណីណាក៏ដោយ ការតភ្ជាប់កសិករទៅកាន់ទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ នឹងមិនមានដំណើរការល្អទេ ប្រសិនបើកសិករទាំងនោះមិនបានរៀបចំគ្នាជាក្រុម សមាគម សហគមន៍កសិកម្ម ឬជាសហព័ន្ធ។ ការប្រមូលផ្តុំអ្នកផលិតដែលមានចំណាប់អារម្មណ៍ដូចគ្នា នឹងបង្កលក្ខណៈងាយស្រួលដល់ស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន អាចធ្វើការជាមួយពួកគាត់ប្រកបដោយប្រសិទ្ធផលច្រើនជាងមុន។ លើសពីនេះ កសិករត្រូវតែបានបំពាក់បំប៉ន ជាមួយនឹងសមត្ថភាពបច្ចេកទេស និងជំនាញសហគ្រិនភាព ដើម្បីពួកគេអាចបង្កើនការប្រមូលផលរបស់ពួកគាត់ កាត់បន្ថយការចំណាយលើផលិតកម្ម និងបំពេញបានតាមតម្រូវការទីផ្សារ។

ដើម្បីធ្វើដំណើរចេញពីផលិតកម្មសម្រាប់បម្រើសេចក្តីត្រូវការក្នុងគ្រួសារឆ្ពោះទៅកាន់ទីផ្សារ (ផ្សារសរីរាង្គ ឬ ផ្សារនាំចេញ) កសិករត្រូវគោរពនូវច្បាប់អាជីវកម្ម រួមនឹងច្បាប់ផលិតកម្មផងដែរ (ការអនុវត្តកសិកម្មល្អ ផលិតកម្មតាមគោលការណ៍ធម្មជាតិ ឬ ផលិតកម្មសរីរាង្គ)។ រហូតមកដល់ពេលនេះ ភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនឯកជនបានផ្តល់ការគាំទ្រដល់កសិករដើម្បីពួកគាត់អាចឆ្លើយតបបាននូវលក្ខខណ្ឌតម្រូវនៃទីផ្សារ

នេះបាន។ ទោះយ៉ាងណា ការទទួលខុសត្រូវ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនេះ គឺពឹងផ្អែកលើកសិករផ្ទាល់។ ជាបន្តបន្ទាប់ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនឯកជន ចាប់ផ្តើមដកនូវការគាំទ្រដោយផ្ទាល់របស់គេ ហើយសហគមន៍កសិកម្ម ដើរតួនាទីជំនួស ដើម្បីធ្វើការជាមួយតួអង្គទីផ្សារនិងអតិថិជន។ ក្រោយមកទៀត សហគមន៍កសិកម្ម ក្លាយខ្លួនជាដៃគូអាជីវកម្ម (ឧទាហរណ៍ ជាមួយសហគ្រាសសេដាក)។ ក្រៅពីការផលិតសម្រាប់លក់មកទីផ្សារសរីរាង្គ ផលិតផលទូទៅពីកសិករធម្មតា ក៏ត្រូវបានផ្គត់ផ្គង់មកទីផ្សារក្នុងស្រុកផងដែរ។ ទោះយ៉ាងណាក៏ដោយ គេបានកត់សម្គាល់ថា នៅក្នុងខ្សែសង្វាក់ផលិតកម្មដូចនេះ នៅមានកង្វះការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងកង្វះការអន្តរាគមដោយផ្ទាល់ពីស្ថាប័នជំនាញរបស់រដ្ឋាភិបាលនៅឡើយ។ ជាញឹកញាប់បំផុត កសិករជួបនូវតម្លៃលក់ទាប ឬ បាត់បង់ការចំណេញ នៅពេលពួកគាត់លក់ផលិតផលរបស់ខ្លួន។ បន្ថែមលើសនេះ ការផ្គត់ផ្គង់ហួសតម្រូវការនៃផលិតផលទូទៅ មិនអាចត្រូវបានបង្វិលទៅកាន់ខ្សែសង្វាក់ផលិតកម្មមួយផ្សេងទៀត ដោយសារថា រោងចក្រកែច្នៃក្នុងស្រុកនៅពុំទាន់អភិវឌ្ឍន៍នៅឡើយ។ ដូច្នេះ ដើម្បីបង្កើនទីផ្សារនៃផលិតផលប្រភេទកសិឧស្សាហកម្ម រោងចក្រកែច្នៃក្នុងស្រុក ចាំបាច់ក៏ត្រូវអភិវឌ្ឍន៍ផងដែរ។

ជារួម គេយល់ថា នៅពេលដែលកសិករបានចូលទៅដល់ទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ ពួកគាត់អាចទទួលបានប្រាក់ចំណេញកាន់តែច្រើន ពីសកម្មភាពកសិកម្មរបស់ពួកគាត់។ នេះក៏នឹងលើកទឹកចិត្តឲ្យកសិករពង្រឹងបន្ថែមនូវសកម្មភាពកសិកម្មរបស់ខ្លួនផងដែរ។ លើសពីនេះ ការផ្លាស់ប្តូរនេះ នឹងបានរួមចំណែកដល់សេដ្ឋកិច្ចជាតិ ដោយសារថា ការកាត់បន្ថយការនាំចូលមកកម្ពុជា កំឡុងពេលដែលផលិតផលក្នុងស្រុក និងផលិតផលជាតិត្រូវបានបង្កើន។




**រូបភាពទី 2: ក្របខណ្ឌវិភាគនៃការសិក្សា**

### ៣.៣.២. តួនាទីតួអង្គពាក់ព័ន្ធសំខាន់ៗដើម្បីគាំទ្រកសិករតូចតាច

មានតួអង្គសំខាន់ៗបីក្រុមដែលគាំទ្រ និងធ្វើការជាមួយកសិករមានដីធ្លីតូចតាច៖ ភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនឯកជន។ របៀបនៃតួអង្គទាំងនេះធ្វើការជាមួយ ឬ ផ្តល់ការគាំទ្រដល់កសិករដែលមានដីធ្លីតូចតាច ផ្អែកលើដំណាក់កាលផ្សេងគ្នា នៃការអនុវត្តរបស់ពួកគេចំពោះកសិករ។

- **ជំហានទី១: ការបង្កើនផលិតកម្មសម្រាប់ទីផ្សារ និងសន្តិសុខស្បៀងក្នុងគ្រួសារ:** ភ្នាក់ងាររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ផ្តល់ជាពិសេសនូវការកសាងសមត្ថភាព ស្តីពីផលិតកម្មកសិកម្ម និងសម្របសម្រួលឲ្យកសិករ អាចទទួលបាននូវធាតុចូលកសិកម្ម ដូចជា គ្រាប់ពូជដែលមានគុណភាព ជី និងឧបករណ៍ផ្សេងទៀតសម្រាប់ផលិតកម្ម។ ការធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទីផ្សារ និងការតភ្ជាប់កសិករទៅនឹងទីផ្សារនៅមានកម្រិតនៅឡើយ។ នេះដោយផ្អែកលើការពិតដែលថា តម្លៃនៃផលិតផលកសិកម្មកម្ពុជា មិនទាន់ប្រកួតប្រជែងបានជាមួយនឹងផលិតផលនាំចូល ជាពិសេសបន្លែពីប្រទេសវៀតណាម និងឈើហូបផ្លែពីប្រទេសថៃ និងផលិតផលសាច់សត្វពីប្រទេសវៀតណាម និងថៃ។ ជាញឹកញាប់ ផលិតផលកសិកម្មកម្ពុជាអាចចូលទៅកាន់ទីផ្សារបាន ក្នុងករណីដែលផលិតផលនោះ ជាផលិតផលពិសេសឧទាហរណ៍ដូចជា ផលិតផលធម្មជាតិ ផលិតផលសុវត្ថិភាព និងផលិតផលសរីរាង្គ។ អង្គការមិនមែនរដ្ឋាភិបាល (សេដាក និង អេសអិនវី) ធ្វើការដើម្បីគាំទ្រដល់គ្រួសារកសិករ ដើម្បីបង្កើនផលិតកម្មរបស់ពួកគាត់តាមរយៈបច្ចេកវិទ្យាថ្មីៗថ្មីមសមស្រប (សេដាក៖ ការអនុវត្តកសិកម្មធម្មជាតិ និងអេសអិនវី៖ ការអនុវត្តកសិកម្មឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ) ក្នុងពេលដែលស្ថាប័នរដ្ឋាភិបាល សម្របសម្រួលនូវធនធាន និងសេវាសាធារណៈ រួមទាំងធាតុចូលកសិកម្ម និងឧបករណ៍កសិកម្ម (គ្រាប់ពូជ ជី បច្ចេកទេសអនុវត្ត។ល។)។

**កសិកម្មធម្មជាតិ ធានាបាននូវការធ្វើកសិកម្មដើម្បីសុខភាព អាហារប្រកបដោយសុខភាព សម្រាប់ពេលបច្ចុប្បន្ន និងអនាគត តាមរយៈការការពារនូវគុណភាពដី បង្កើនជីវចម្រុះ និងមិនធ្វើឲ្យប្រឌូក់ដល់បរិស្ថាន ដោយសារធាតុគីមី ឬ ការធ្វើសេនេទិចជាដើម (Tirado, 2009)។**

**កសិកម្មឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុគឺជាយុទ្ធសាស្ត្រចម្រុះ ដើម្បីឆ្លើយតបទៅនឹងកត្តាប្រឈមជាអន្តរទំនាក់ទំនងរវាងសន្តិសុខស្បៀង និងការប្រែប្រួលអាកាសធាតុ ក្នុងគោលបំណងសំខាន់ៗចំនួន ៣៖ (១) ការបង្កើនផលិតភាពកសិកម្មប្រកបដោយនិរន្តរភាព ដើម្បីគាំទ្រដល់កំណើនចំណូលសមស្រប ពីកសិដ្ឋាន សន្តិសុខស្បៀង និងការអភិវឌ្ឍ (២) សម្រប និងបន្សាំកសិកម្ម និងប្រព័ន្ធសន្តិសុខស្បៀង ទៅនឹងការប្រែប្រួលអាកាសធាតុក្នុងពហុកម្រិត និង (៣) កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីកសិកម្ម (រួមបញ្ចូលនូវដំណាំ សត្វ និងវារីវប្បកម្ម) (FAO, 2013)។**

- **ជំហានទី២: ការលើកកម្ពស់ផលិតកម្មសម្រាប់ទីផ្សារក្នុងស្រុក និងសន្តិសុខស្បៀងក្នុងស្រុកៈ** នៅពេលដែលកសិករលក់ផលិតផលកសិកម្មរបស់ពួកគាត់ ដោយគោរពតាមស្តង់ដាជាក់លាក់មួយ ដូចដែលមានរៀបរាប់ខាងលើ ជារឿយៗ ពួកគាត់បានរៀបចំគ្នាជាក្រុមផលិត ដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ឬ គម្រោងរដ្ឋាភិបាល ហើយធ្វើការជាមួយវិស័យឯកជនដែលដើរតួនាទីជាឈ្មួញកណ្តាល។ វិស័យឯកជន ក៏ដើរតួនាទីជាអ្នកចែកចាយ ឬ អ្នកលក់រាយទៅដល់អតិថិជនប្រើប្រាស់ចុងក្រោយក្នុងខេត្ត ឬ ទីក្រុង។ លើសពីនេះ កសិករក៏អាចលក់កសិផលរបស់ខ្លួននៅក្នុងតំបន់ ក្នុងភូមិរបស់ពួកគាត់ ទៅអ្នកជិតខាង ឬ ផ្សារក្នុងតំបន់ (ផ្សារក្នុងឃុំ និងស្រុក និងជួនកាលទៅកាន់ទីផ្សារក្នុងខេត្ត) ផងដែរ។ ភ្នាក់ងាររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនាពេលបច្ចុប្បន្ន ដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់នូវគុណប្រយោជន៍និងកេរ្តិ៍ឈ្មោះផលិតផលក្នុងស្រុក (ផលិតផលសរីរាង្គ សុវត្ថិភាព និងផលិតផលធម្មជាតិ) តាមរយៈពិពណ៌កសិកម្ម។ អ្នកផលិតជាលក្ខណៈបុគ្គលរួមនឹងក្រុមផលិតជាបន្តបន្ទាប់ ត្រូវបានស្គាល់ដោយអ្នកបរិភោគក្នុងតំបន់ទីក្រុង។ ពេលនោះ អ្នកបរិភោគក្នុងទីក្រុងអាចទិញកសិផលដោយផ្ទាល់ពីអ្នកផលិតផងដែរ។

លទ្ធផលនៃការសិក្សាបានបង្ហាញថា កសិករអាចផលិតបន្លែបានច្រើនបន្ថែមទៀត ដើម្បីផ្គត់ផ្គង់មកទីផ្សារនៅទីក្រុង។ ទោះជាយ៉ាងនេះក្តី ដោយផ្អែកលើបណ្តាញសម្របសម្រួល មានតែផលិតផលរបស់កសិករក្នុងកម្រិតតូចមួយប៉ុណ្ណោះ ដែលត្រូវបានផ្គត់ផ្គង់មកទីផ្សារទីក្រុង។

នៅក្នុងដំណាក់កាលនេះ ភ្នាក់ងាររដ្ឋាភិបាល ជាពិសេស អគ្គនាយកដ្ឋានកសិកម្ម ផ្តល់នូវក្របខណ្ឌគតិយុត្ត ដូចជា ច្បាប់ស្តីពីសហគមន៍កសិកម្ម និងច្បាប់ស្តីអំពីការធ្វើកសិកម្មតាមកិច្ចសន្យា ដល់កសិករ ដើម្បីបង្កើតសហគមន៍កសិកម្ម និងបង្កើនអាជីវកម្មកសិកម្មរបស់ខ្លួន។ សហគមន៍កសិកម្ម សរុបចំនួន ៥៥៦ ត្រូវបានបង្កើត និងដំណើរការ (GDA, 2015)[7]។ បច្ចុប្បន្ន អគ្គនាយកដ្ឋានកសិកម្ម កំពុងស្ថិតក្នុងដំណើរការផលិតនូវឯកសារបណ្តុះបណ្តាលសំខាន់ៗចំនួន២៖ ១) ឯកសារបណ្តុះបណ្តាល គ្រូបង្គោលផ្នែកសហគមន៍កសិកម្ម និង ២) ឯកសារបណ្តុះបណ្តាល ដើម្បីកសាងសមត្ថភាពសហគមន៍ កសិកម្ម។ អគ្គនាយកដ្ឋានកសិកម្ម ក៏មានផែនការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់ឃុំ នៅក្នុង ឃុំទាំងអស់ក្នុងប្រទេសកម្ពុជា និងបំពាក់ដោយគ្រូបណ្តុះបណ្តាល/អ្នកសម្របសម្រួលសហគមន៍កសិកម្ម ចំនួន២នាក់ក្នុង១ឃុំ ដើម្បីផ្តល់សេវា ពាក់ព័ន្ធនឹងសហគមន៍កសិកម្មនៅទូទាំងប្រទេសកម្ពុជា។

សេដាក និងអេសអិនវី បានធ្វើកិច្ចការដើម្បីលើកកម្ពស់លទ្ធភាពទៅកាន់ទីផ្សារ។ គួរកត់សម្គាល់ដែរថា សេដាកបានបង្កើតខ្សែចង្វាក់ទីផ្សារថ្មី ដើម្បីទិញផលិតផលក្នុងស្រុក ពីកសិករសហការរបស់ខ្លួន ហើយលក់

---

[7] សិក្ខាសាលាៈ វិស័យកសិកម្មកម្ពុជាៈ ភាពរួចរាល់សម្រាប់សហគមន៍អាស៊ានឆ្នាំ ២០១៥ និងពេលខាងមុខ នៅសណ្ឋាគារសុខា ភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០១៥។

ផលិតផលទាំងនោះ ទៅដល់អ្នកបរិភោគក្នុងទីក្រុង។ អង្គការអេសអិនវី បានធ្វើកិច្ចការ ដើម្បីលើកកម្ពស់ខ្សែសង្វាក់ទីផ្សារដែលមានស្រាប់ ដោយយុទ្ធសាស្ត្រអាជីវកម្មបែបបរិយាប័ន្ន ដើម្បីផ្សារភ្ជាប់កសិករទៅតួអង្គទីផ្សារ និងបង្កើនលទ្ធភាពទទួលបានព័ត៌មានទីផ្សារ។

**ក. អន្តរាគមន៍របស់សេដាកទៅកាន់ទីផ្សារ:** នៅខេត្តកំពង់ឆ្នាំង ក្រុមកសិករបានផលិតបន្លែដោយផ្អែកលើផែនការដែលបានព្រមព្រៀង ហើយផ្គត់ផ្គង់បន្លែមកផ្សារអង្គការសេដាកនៅក្រុងភ្នំពេញ រៀងរាល់៣ថ្ងៃម្តង។ ការសិក្សាបានបង្ហាញថា កសិករផលិតបានបង្កើនផ្ទៃដីផលិតកម្មបន្លែពី ៥៥០ទៅដល់ ៨៥០ម៉ែត្រក្រឡា ហើយផលិតកម្មរបស់គេ បានកើនឡើងពី ៤៧៥គីឡូក្រាម ដល់រង្វង់ ១.៣០០គីឡូក្រាមក្នុង១គ្រួសារជាមធ្យម។ នេះដោយសារថា កសិករបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសផលិតកម្ម និងអាចដាំដុះនូវប្រភេទដំណាំចម្រុះពេញមួយឆ្នាំ។ លើសពីនេះ កសិករអាចទទួលបានតម្លៃលក់ទ្វេដង បើធ្វើការប្រៀបធៀបជាមួយប្រភេទកសិផលដូចគ្នា ដែលប្រើប្រាស់សារធាតុគីមី។ ក្នុងខ្សែសង្វាក់ផលិតកម្មស្រូវ កសិករអាចបង្កើនផលិតកម្មរបស់ពួកគាត់ផងដែរ ដោយសារទទួលបានបច្ចេកទេសកែលម្អ ហើយអាចទទួលបានតម្លៃលក់ខ្ពស់ជាងស្រូវដែលផលិតដោយប្រើប្រាស់សារធាតុគីមី ប្រមាណ ៥០% ដោយផ្អែកតាមតម្លៃលក់នៅដើមឆ្នាំ២០១៥ (សូមយោងទៅករណីសិក្សាដើម្បីទទួលបានព័ត៌មានលម្អិត)។

**ខ. អន្តរាគមន៍របស់អេសអិនវី លើទីផ្សារ:** អង្គការ អេសអិនវី បានធ្វើការក្រោមភាពជាដៃគូជាមួយអង្គការអាយវីវ៉ាយ ដែលជាអង្គការក្នុងស្រុក ហើយផ្សារភ្ជាប់ផលិតកម្មបន្លែទៅកាន់ទីផ្សារ ដូចជា សួនធម្មជាតិ កាស៊ីណូភោជនីយដ្ឋាននៅតាមព្រំដែនកម្ពុជាវៀតណាម ផ្សារអ៊ីអន (AEON) នៅភ្នំពេញជាដើម។ ដោយសារផលិតផលក្នុងស្រុក ទទួលបាននូវភាពពេញនិយម ក្នុងចំណោមអ្នកបរិភោគជាងផលិតផលនាំចូល កសិផលរបស់កសិករទាំងនោះ ភាគច្រើនផ្គត់ផ្គង់តែក្នុងទីផ្សារក្នុងតំបន់ តាមភូមិ ឬ កម្រិតឃុំប៉ុណ្ណោះ។ អង្គការអេសអិនវី បានពង្រឹងចំណេះដឹង និងសមត្ថភាពបច្ចេកទេសដល់កសិករ ស្តីពីការអនុវត្តកសិកម្ម ឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ។ គោលបំណងនៃការអនុវត្តបច្ចេកទេសកសិកម្មឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ គឺដើម្បីបង្កើនសមត្ថភាពសម្របខ្លួនរបស់កសិករ ឲ្យឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ជាពិសេស ពួកគេគាំទ្រកសិករដើម្បីប្រើប្រាស់នូវការស្តុកទឹកប្រកបដោយប្រសិទ្ធភាព និងប្រព័ន្ធផ្គត់ផ្គង់សម្រាប់ផលិតកម្មបន្លែ។ ក្នុងពេលជាមួយគ្នានោះដែរ អេសអិនវី ក៏បានសម្របសម្រួលនូវការតភ្ជាប់ រវាងអ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម ឬ អ្នកផ្គត់ផ្គង់បច្ចេកវិទ្យាឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុទៅនឹងកសិករខ្នាតតូច។ ជាអាទិ៍ ស្រះកែលម្អការគ្រប់គ្រងទឹកដែលបាននាំមកដោយអង្គការអេសអិនវី បានបង្កភាពងាយស្រួលដល់គ្រួសារកសិករដែលមានដីធ្លីតូចតាច ដើម្បីបង្កើននូវវដ្តផលិតកម្មបន្លែរបស់ខ្លួន ពី១ដង ទៅ ៣ដងក្នុង១ឆ្នាំ នោះមានន័យថា បរិមាណបន្លែច្រើនជាងមុន ត្រូវបានផលិតដើម្បីផ្គត់ផ្គង់មកទីផ្សារក្នុងស្រុក។

- **ជំហានទី៣: ការបង្កើនផលិតកម្ម ឆ្ពោះទៅកាន់ទីផ្សារនាំចេញ:** នៅក្នុងដំណាក់កាលនេះ កសិករចូលទៅក្នុងទីផ្សារនាំចេញ។ ភ្នាក់ងាររដ្ឋាភិបាល ដើរតួនាទីសំខាន់ សម្រាប់ការគាំទ្រផ្នែកច្បាប់ ក្នុងពេលដែល

ក្រុមហ៊ុននាំចេញ បានធ្វើការជាមួយក្រុមហ៊ុនក្នុងស្រុក ដើម្បីទិញផលិតផលតាមបរិមាណត្រូវការសម្រាប់ការនាំចេញ។ អង្គការមិនមែនរដ្ឋាភិបាល ជារឿយៗ ធ្វើការជាមួយក្រុមផលិត ហើយរៀបចំគ្នាជាក្រុម ឬចុះឈ្មោះជាសហគមន៍កសិកម្ម។ ក្រុមហ៊ុននាំចេញ កម្រចុះដល់ ឬ ធ្វើការដោយផ្ទាល់ជាមួយសហគមន៍កសិកម្មណាស់ ប៉ុន្តែធ្វើការតាមរយៈឈ្មួញកណ្តាល ឬ ក្រុមហ៊ុនក្នុងស្រុក ជាឈ្មួញកណ្តាល។ ការប្រតិបត្តិរបស់សហគមន៍កសិកម្ម ពិបាកក្នុងការកំណត់ថាយ៉ាងណានៅឡើយទេ ដោយសារសហគមន៍ភាគច្រើនទើបតែត្រូវបានបង្កើតឡើងនាពេលថ្មីៗនៅឡើយ។ ទាំងសហគមន៍កសិកម្ម និងក្រុមហ៊ុននាំចេញ បានជួបប្រទះការលំបាក ក្នុងការធ្វើការងារជាមួយគ្នាលើការងារផ្នែកបរិមាណ ការផ្គត់ផ្គង់តាមពេលវេលា គុណភាពជាតម្រូវការ និងលក្ខខណ្ឌកំណត់មួយចំនួនទៀត។

រាជរដ្ឋាភិបាលកម្ពុជា ក្នុងឯកសារគោលនយោបាយរបស់ខ្លួន ស្តីអំពី ការលើកកម្ពស់ផលិតកម្មស្រូវ និងការនាំអង្ករចេញ បានកំណត់ទិសដៅ ក្នុងការសម្រេចឲ្យបានការនាំចេញអង្ករ ១លានតោន ក្នុងឆ្នាំ ២០១៥។ ដើម្បីសម្រេចបាននូវទិសដៅនេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតនូវសកម្មភាព និងយុទ្ធសាស្ត្រមួយចំនួន ដូចជាការធ្វើឲ្យប្រសើរឡើងនូវប្រភេទពូជស្រូវសម្រាប់ទីផ្សារនាំចេញ ការរៀបចំទិវាស្រូវអង្ករ ដើម្បីទាក់ទាញក្រុមហ៊ុននាំចេញ ការលើកកម្ពស់សមត្ថភាពកិនស្រូវក្នុងស្រុក និងការផ្តល់ឥណទានដល់សមាគមម៉ាស៊ីនកិនស្រូវ ដើម្បីទិញស្រូវពីកសិករ។

នៅកម្រិតស្ថាប័ន និងកម្រិតកម្មវិធី យុទ្ធសាស្ត្រចំនួន ២ ដែលគាំទ្រដល់កសិករដែលមានដីធ្លីតូចតាចត្រូវបានកំណត់។ សេដាក ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ធ្វើការងារដើម្បីលើកកម្ពស់ភាពអាស្រ័យលើខ្លួនឯងរបស់កសិករ តាមរយៈការរៀបចំចង្វាក់ទីផ្សារថ្មី។ អេសអិនវី ជាអង្គការអន្តរជាតិ ធ្វើការដើម្បីលើកកម្ពស់ប្រព័ន្ធទីផ្សារដែលមានស្រាប់ ដែលភាគីពាក់ព័ន្ធទាំងអស់ ទទួលបាននូវអត្ថប្រយោជន៍ពីការអភិវឌ្ឍជំនួញតាមបែបបរិយាប័ន្ន។

សេដាកបានដើរតួនាទីជាឈ្មួញកណ្តាល រវាងក្រុមហ៊ុននាំចេញ និងសហគមន៍កសិកម្ម ដើម្បីលើកកម្ពស់ផលិតផលសរីរាង្គ។ ក្រុមហ៊ុននាំចេញ បានចុះកិច្ចសន្យាជាមួយអង្គការសេដាក ដើម្បីទទួលបានការផ្គត់ផ្គង់នូវអង្ករសរីរាង្គ ក្នុងបរិមាណជាក់លាក់មួយ សម្រាប់ការនាំចេញ។ ពេលនោះ សេដាកបានធ្វើកិច្ចការជាមួយសហគមន៍កសិកម្ម ដើម្បីផលិតស្រូវសរីរាង្គ។ សម្រាប់ទីផ្សារនាំចេញ ប្រព័ន្ធត្រួតពិនិត្យគុណភាព គឺជាតម្រូវការចាំបាច់។ ក្នុងករណីនេះ សេដាកដើរតួនាទីជាភ្នាក់ងារត្រួតពិនិត្យផ្ទៃក្នុង និងធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកផលិតស្រូវសរីរាង្គ នៅពេលដែលក្រុមហ៊ុននាំចេញ បានណែនាំក្រុមហ៊ុនបញ្ជាក់គុណភាពខាងក្រៅ ដើម្បីត្រួតពិនិត្យមួយជាន់ទៀតនូវគុណភាពសម្រាប់ការនាំចេញ។ កសិករត្រូវរៀនសូត្រជាជំហានៗ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវនៃទីផ្សារនាំចេញនេះ។

ខាងក្រោមនេះ គឺជាជំហានជាមូលដ្ឋាន ក្នុងការតភ្ជាប់ប្រភេទកសិផលស្រូវទៅកាន់ទីផ្សារៈ

- ការចងក្រងក្រុម និងការកសាងសមត្ថភាព
- ផ្តល់ការបណ្តុះបណ្តាលពីការអភិវឌ្ឍបែបអាស្រ័យខ្លួនឯង
- ការគៀរគរធនធានហិរញ្ញវត្ថុ
- ការរៀបចំផែនការអាជីវកម្ម

អង្គការអេសអិនវី បានធ្វើការជាមួយភាគីអ្នកពាក់ព័ន្ធ ដើម្បីលើកកម្ពស់ខ្សែសង្វាក់ផលិតកម្មដំឡូងមី។ អេសអិនវី ជាមួយអង្គការមិនមែនរដ្ឋាភិបាលដៃគូក្នុងស្រុក បានរួបរួមជាមួយភាគីអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ដូចជាអ្នកផ្គត់ផ្គង់ធាតុចូល និងឈ្មួញ (អ្នកប្រមូលទិញដំឡូងមី) ដើម្បីគាំទ្រដល់កសិករ ក្នុងន័យការចែករំលែកព័ត៌មានបច្ចេកទេស ធ្វើការផ្គត់ផ្គង់នូវធាតុចូលដែលមានគុណភាពល្អ និងដើរតួនាទីជាអ្នកផ្តល់សេវាកម្ម។ មន្ត្រីពីមន្ទីរកសិកម្មខេត្ត ក៏បានសម្របសម្រួលការពង្រឹងសមត្ថភាពបច្ចេកទេស គាំទ្រ និងសម្របសម្រួលតំណភ្ជាប់ទីផ្សារផងដែរ។

ខាងក្រោមនេះ គឺជាជំហាន និងដំណើរការ ក្នុងការគាំទ្រដល់ចង្វាក់ផលិតកម្មដំឡូងមីៈ

- ការកំណត់ និងជ្រើសរើសសហគ្រាសកែច្នៃដំឡូងមី (សហគ្រិនក្នុងស្រុក)
- ការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីជ្រើសរើសតំបន់គោលដៅ
- ការចងក្រងក្រុមកសិករ និងរៀបចំផែនការផលិត ដើម្បីផ្គត់ផ្គង់ដល់សហគ្រាស
- ការកសាងសមត្ថភាព ពីការដាំដុះដំឡូងមី និងការផ្សារភ្ជាប់ទៅភាគីអ្នកពាក់ព័ន្ធ (សហគ្រាសក្នុងស្រុក និងអ្នកប្រមូលទិញ)។

ចំពោះការប៉ាន់ប្រមាណគុណភាព សហគ្រាសកែច្នៃក្នុងស្រុក និងឈ្មួញវៀតណាម ធ្វើការត្រួតពិនិត្យគុណភាពផលិតផល ហើយបន្ទាប់មក កំណត់នូវតម្លៃទិញចូលជាក្រោយ ដោយយោងលើគុណភាពផលិតផល។

## ៣.៤. ការគាំទ្រកសិករដែលមានដីធ្លីតូចតាចៈ ករណីសិក្សាអង្គការសេដាក និងអេសអិនវី

### ៣.៤.១. ការគាំទ្រផលិតកម្ម និងទីផ្សារស្រូវសរីរាង្គដោយអង្គការសេដាក

ដោយមានការគាំទ្រពីអង្គការសេដាក និងបណ្តាញកសិករ និងធម្មជាតិ សហគមន៍រោងម៉ាស៊ីនកិនស្រូវស្តុកស្តម្ភ ដែលមានសមាជិកសរុប ៤៧៩នាក់ ត្រូវបានបង្កើតឡើង នៅឆ្នាំ ២០១២ និងចុះឈ្មោះជាផ្លូវការ នៅមន្ទីរកសិកម្មខេត្តតាកែវ។ សហគមន៍នេះ ស្ថិតនៅភូមិត្រពាំងស្តុក ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ការគាំទ្រផ្នែកផលិតកម្ម និងទីផ្សារស្រូវសរីរាង្គ ត្រូវបានធ្វើឡើង តាមជំហានដូចខាងក្រោមៈ

**ជំហានទី១: ការកសាងសមត្ថភាពកសិករៈ** ការបណ្តុះបណ្តាលស្តីអំពីប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស.) ត្រូវបានរៀបចំ សម្រាប់កសិករក្នុងភូមិតាមរយៈអង្គការសេដាក។ វគ្គបណ្តុះបណ្តាលបច្ចេកទេស និងមិនមែនបច្ចេកទេសផ្សេងទៀត រួមនឹងការប្រជុំ សិក្ខាសាលា និងការធ្វើទស្សនកិច្ចសិក្សា ត្រូវបានរៀបចំសម្រាប់កសិករ និងកសិករជាថ្នាក់ដឹកនាំ។ គោលការណ៍បច្ចេកទេសប្រព័ន្ធប្រពលវប្បកម្មស្រូវជាច្រើន ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ក្នុងចំណោមអ្នកចូលរួមជាមួយគម្រោង។ ជាលទ្ធផល ទិន្នផលស្រូវមានការកើនឡើងប្រមាណ ៥០% បើប្រៀបធៀបជាមួយការអនុវត្តតាមទម្លាប់។

**ជំហានទី២: ការគៀរគរធនធានហិរញ្ញវត្ថុៈ** រយៈពេល ០១ឆ្នាំ ក្រោយគម្រោងចាប់ផ្តើម កសិករចំនួន២៥គ្រួសារក្នុងភូមិ បានចាប់ផ្តើមធ្វើការជាមួយគ្នាជាក្រុម ដើម្បីគៀរគរធនធនហិរញ្ញវត្ថុ តាមរយៈការដាក់ប្រាក់សន្សំជាក្រុម។ ចាប់ពីឆ្នាំ២០១០ ដល់ ២០១១ ក្រុមសន្សំចំនួន៩ក្រុមផ្សេងទៀតបានបង្កើតឡើងក្នុងភូមិចំនួន៩ នៃស្រុកព្រៃកប្បាស។ សហគមន៍សន្សំប្រាក់ថ្នាក់ស្រុក១ ត្រូវបានបង្កើតឡើង ក្នុងឆ្នាំ២០១២។ នៅដើមឆ្នាំ ២០១៥ ទុនសន្សំរបស់សហគមន៍ មានចំនួនជាង ២០០លានរៀល ឬ ប្រហាក់ប្រហែល ៥០.០០០ដុល្លារ។

**ជំហានទី៣: ការចាប់ផ្តើមសាកល្បងចេញពីម៉ាស៊ីនកិនស្រូវខ្នាតតូចៈ** ផ្អែកលើសក្តានុពលស្រូវ និងការគាំទ្រពីអង្គការសេដាក និងបណ្តាញកសិករ និងធម្មជាតិ សហគមន៍ម៉ាស៊ីនកិនស្រូវ ត្រូវបានបង្កើតឡើង ក្នុងឆ្នាំ ២០១២ ក្នុងទឹកប្រាក់តម្លៃ ម្ភៃលានប្រាំបីសែនប្រាំម៉ឺនរៀល ឬ ប្រហាក់ប្រហែល ៥.០០០ដុល្លារ។ នៅក្នុងដំណាក់កាលនេះ អង្ករត្រូវបានលក់នៅទីផ្សារក្នុងតំបន់ប៉ុណ្ណោះ។

**ជំហានទី៤: ការភ្ជាប់ទីផ្សារជាមួយសេដាកៈ** នៅឆ្នាំ ២០១៣ សហគមន៍បានចាប់ផ្តើមភ្ជាប់ទីផ្សារស្រូវសរីរាង្គទៅកាន់ទីផ្សារសេដាកនៅភ្នំពេញ ដើម្បីទទួលបានតម្លៃលក់ខ្ពស់។ ដើម្បីបំពេញតាមស្តង់ដាទីផ្សារ ស្រូវត្រូវបានដឹកជញ្ជូនទៅកាន់រោងម៉ាស៊ីនកិនស្រូវអង្គការសេដាកដើម្បីធ្វើការកែច្នៃ។ ជាមួយនឹងបទពិសោធន៍ដែលទទួលបាន ប្រាក់ចំណេញបានកើនឡើងពី៣លានរៀល ក្នុងបរិមាណស្រូវ១០០តោន ទៅដល់ ១០លានរៀល ក្នុងបរិមាណស្រូវ ១២០តោន នៅឆ្នាំ ២០១៤។

**ជំហានទី៥: ការគៀរគរទុន សម្រាប់បង្កើតម៉ាស៊ីនកិនស្រូវខ្នាតធំៈ** សេដាក ដោយបានធ្វើកិច្ចការជាមួយបណ្តាញកសិករនិងធម្មជាតិ[8] បានធ្វើការអំពាវនាវដល់សមាជិកកសិករទាំងអស់ ធ្វើការគៀរគរមូលនិធិ ដើម្បីវិនិយោគលើម៉ាស៊ីនកិនស្រូវ ដែលអាចកិនស្រូវប្រកបដោយគុណភាពស្តង់ដា សម្រាប់ការនាំចេញ។ ជាលទ្ធផល សហគមន៍ម៉ាស៊ីនកិនស្រូវស្តុកស្តម្ភ បានគៀរគរមូលនិធិវិនិយោគបានចំនួន ១៦៧លានរៀល ឬ ប្រហាក់ប្រហែលនឹង ៤២.០០០ដុល្លារ ពីម្ចាស់ភាគហ៊ុនចំនួន ២៤៧នាក់ មកពីសមាគមកសិករចំនួន ៦០ នៅទូទាំងប្រទេស។ សហគមន៍បានទិញដី១កន្លែងទំហំ ១ហ.ត សម្រាប់សាងសង់ឃ្លាំងស្រូវ។

---

[8] បណ្តាញកសិករនិងធម្មជាតិ គឺជាដៃគូរបស់សមាគម និងសហគមន៍កសិករ ដែលគាំទ្រដោយអង្គការសេដាក នៅទូទាំងប្រទេស។

**កំណត់ចំណាំ:** សេដាកបានសម្របសម្រួលការប្រជុំ ជាមួយថ្នាក់ដឹកនាំសមាគមកសិករ និងសហគមន៍កសិកម្មមកពីស្រុកចំនួន ៦០ ដែលស្ថិតនៅក្រោមឆ័ត្ររបស់បណ្តាញកសិករ និងធម្មជាតិ ដើម្បីបង្កើតឡើងនូវសហគមន៍ម៉ាស៊ីនកិនស្រូវ។ លក្ខខណ្ឌបានចែងថា ចំនួនរោងម៉ាស៊ីនកិនស្រូវនឹងត្រូវបង្កើតឡើង ដោយផ្អែកលើចំនួនមូលនិធិដែលបានគៀរគរ ពីសមាជិកថ្នាក់ស្រុកនីមួយៗ។ លើសពីនេះ សហគមន៍ថ្នាក់ស្រុកណាដែលអាចគៀរគរមូលនិធិបានច្រើនជាងគេពីសមាជិករបស់ខ្លួន នឹងត្រូវផ្តល់អាទិភាព ដើម្បីទទួលមូលនិធិពីស្រុកផ្សេងៗ ដើម្បីបង្កើតរោងម៉ាស៊ីនកិនស្រូវនៅស្រុកនោះ។ ជាលទ្ធផល សហគមន៍ថ្នាក់ស្រុកចំនួន៣ ក្នុងចំណោមស្រុកចំនួន ៦០ ត្រូវបានជ្រើសរើសឲ្យទទួលនូវមូលនិធិដែលបានគៀរគរ។ សហគមន៍ថ្នាក់ស្រុកទាំងនោះ រួមមានៈ ស្រុកព្រៃកប្បាស ខេត្តតាកែវ ស្រុកកំចាយមារ និងស្រុកស៊ីធរកណ្តាលនៃខេត្តព្រៃវែង។ ផលកម្រៃដែលទទួលបានពីអាជីវកម្ម រោងម៉ាស៊ីនកិនស្រូវ នឹងត្រូវបែងចែកទៅសមាជិកសហគមន៍ទាំង ៦០ស្រុក ផ្អែកតាមចំនួនភាគហ៊ុនរបស់គេ។ គួរកត់សម្គាល់ថា ការគៀរគរមូលនិធិ នឹងត្រូវធ្វើជាបន្តបន្ទាប់រៀងរាល់ឆ្នាំ ហើយសហគមន៍រោងម៉ាស៊ីនកិនស្រូវផ្សេងទៀត ត្រូវបានរំពឹងថា នឹងបង្កើតឡើងដោយផ្អែកលើលក្ខខណ្ឌតែមួយ។

**តារាងទី 1: ជំហានសំខាន់ៗ ក្នុងការរៀបចំសហគមន៍រោងម៉ាស៊ីនកិនស្រូវ**

| សូចនាករ | ដំណាក់កាលមុនពេលរៀបចំ | ដំណាក់កាលបច្ចុប្បន្ន | ការរំពឹងទៅថ្ងៃអនាគត/និរន្តរភាព |
|---|---|---|---|
| **ស្ថាប័ន** | - សេដាកបានប្រើប្រាស់មូលនិធិខាងក្រៅ ពីម្ចាស់ជំនួយ ដើម្បីកសាងសមត្ថភាពកសិករ ដើម្បីបង្កើនផលិតកម្មរបស់ពួកគាត់ | - សេដាក បន្តកសាងសមត្ថភាពសមាជិកគណៈកម្មការសហគមន៍ ឆ្ពោះទៅការអភិវឌ្ឍបែបអាស្រ័យលើខ្លួនឯង។ | - សេដាកនឹងបន្តកសាងសមត្ថភាពគណៈកម្មការសហគមន៍ ឆ្ពោះទៅការអភិវឌ្ឍ និងការគ្រប់គ្រងបែបអាស្រ័យលើខ្លួនឯង។ |
| **ដំណើរការ** | - ការបណ្តុះបណ្តាលបច្ចេកទេស និងមិនមែនបច្ចេកទេស រួមនឹងសកម្មភាពសន្សំប្រាក់ ត្រូវបានគាំទ្រដោយអង្គការសេដាក។ | - ក្រុមសន្សំប្រាក់ សហគមន៍សន្សំប្រាក់ ការកសាងសមត្ថភាពផ្នែកបច្ចេកទេសនិងមិនមែនបច្ចេកទេស និងសហគមន៍រោងម៉ាស៊ីនកិនស្រូវ ស្ថិត ក្រោមការជួយជ្រោមជ្រែងពីអង្គការសេដាក។ | - សេដាកនឹងដើរតួនាទីជាដៃគូអភិវឌ្ឍន៍ ជាមួយសហគមន៍រោងម៉ាស៊ីនកិនស្រូវនៅពេលអនាគត។ |
| **បណ្តាញ និង ដៃគូ** | - សេដាកបានផ្សារភ្ជាប់សហគមន៍ទៅនឹងបណ្តាញកសិករ និងធម្មជាតិ។ | - សេដាកបានភ្ជាប់សហគមន៍ទៅនឹងសហគមន៍រោងម៉ាស៊ីនកិនស្រូវថ្នាក់ជាតិក្នុងស្រុកចំនួន ៦០ ក្នុងប្រទេស។ | - សហគមន៍រោងម៉ាស៊ីនកិនស្រូវទាំងអស់ នឹងក្លាយជាសហព័ន្ធរោងម៉ាស៊ីនកិនស្រូវថ្នាក់ជាតិ និងជាដៃគូររបស់អង្គការសេដាក។ |
| **ភ្នាក់ងារគាំទ្រ** | - មន្ទីរកសិកម្មខេត្តបានចេញលិខិតចុះឈ្មោះក្រុមកសិករជាសមាគមកសិករ។ | - មន្ទីរកសិកម្ម បានចេញលិខិតចុះឈ្មោះសមាគមកសិករជាសហគមន៍កសិកម្ម។ | - សហព័ន្ធរោងម៉ាស៊ីនកិនស្រូវថ្នាក់ជាតិនឹងត្រូវបង្កើតឡើង។ |

ប្រភពៈ ការសម្ភាសបុគ្គលិកសេដាក នៅថ្ងៃទី១៩/២១ ខែមករា ឆ្នាំ២០១៥ និងថ្នាក់ដឹកនាំសហគមន៍រោងម៉ាស៊ីនកិនស្រូវ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០១៥។

**តារាងទី 2: ឥទ្ធិពលទៅលើការប្រកបរបរចិញ្ចឹមជីវិត តាមរយៈសហគមន៍រោងម៉ាស៊ីនកិនស្រូវ**

| ផលិតកម្ម | - មុនពេលមានសហគមន៍ | - ស្ថានភាពបច្ចុប្បន្ន |
|---|---|---|
| **កម្រិតបុគ្គល** | - ជាមធ្យម កសិករមានដី១ហ.ត សម្រាប់ផលិតកម្មស្រូវ។ ផលិតកម្ម គឺសម្រាប់បម្រើការហូបចុកក្នុង គ្រួសារ។ | - កសិករផលិតស្រូវ និងដំណាំចម្រុះផ្សេងទៀត សម្រាប់ការហូបចុកក្នុងគ្រួសារ និងលក់។ |
| **សមាជិកគ្រួសារដែលចូលរួមក្នុងសកម្មភាពស្វែងរកប្រាក់ចំណូល** | - កសិករពឹងផ្អែកលើផលិតកម្មស្រូវ កំឡុងពេលដែលសមាជិក សហគមន៍កសិកម្មមួយចំនួនធ្វើ សកម្មភាពមិនមែនកសិកម្ម ឧទាហរណ៍ ការងារនៅរោងចក្រ ជាដើម។ | - សមាជិកសហគមន៍មួយចំនួន មាន សមាជិក គ្រួសារ១រូប ដែលចូលរួមក្នុង សកម្មភាពសហគមន៍ ទាំងក្នុងការសន្សំ ប្រាក់ និងរោងម៉ាស៊ីនកិនស្រូវ។ |
| **កម្រិតក្រុម** | - កសិករធ្វើស្រែប្រមូលផលបាន ប្រមាណ ២តោនក្នុង១ហ.ត ឬ លក់ បាន ១.៦លានរៀល (តម្លៃ ៧០០ ទៅ ៩០០ រៀល/គ.ក្រ)។ | - ជាមួយបច្ចេកទេស ប.វ.ស កសិករទទួល បាន ទិន្នផល ៣តោនក្នុង១ហ.ត ឬ លក់ បាន ៤.៦៥លានរៀល (តម្លៃ ១.៥៥០ រៀល/គ.ក្រ)។ |
| **កម្រិតសហគមន៍** | - កសិករលក់ស្រូវឲ្យឈ្មួញ។ | - កសិករជាសមាជិកសហគមន៍ លក់ស្រូវ សរីរាង្គឲ្យសហគមន៍របស់ខ្លួន។<br>- សហគមន៍លក់អង្ករឲ្យផ្សារសេដាក[9]នៅ ភ្នំពេញ និងសម្រាប់ការនាំចេញ។ |

*ប្រភពៈ ការសម្ភាសបុគ្គលិកសេដាក នៅថ្ងៃទី១៩/២១ ខែមករា ឆ្នាំ២០១៥ ថ្នាក់ដឹកនាំ និងសមាជិកសហគមន៍រោងម៉ាស៊ីនកិនស្រូវ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០១៥។*

[9] ផ្សារសេដាក គឺជាក្រុមហ៊ុនចុះបញ្ជីឯករាជ្យ។ អង្គការសេដាក ក៏មានចំណែកភាគហ៊ុននៅក្នុងក្រុមហ៊ុននេះផងដែរ។

**បញ្ហាប្រឈម ដំណោះស្រាយ និងលទ្ធផល**

- ធនធានមានកម្រិតសម្រាប់ធ្វើកំប៉ុស ឬ ជីសរីរាង្គ គឺជាបញ្ហាប្រឈមសម្រាប់កសិករធ្វើស្រូវសរីរាង្គ ដែលចង់ពង្រីកផលិតកម្មស្រូវសរីរាង្គ។ ជាការឆ្លើយតប ការបណ្តុះបណ្តាលស្តីអំពីការធ្វើជីកំប៉ុស និងជីស្រស់ត្រូវបានផ្តល់។ ជាលទ្ធផល បរិមាណស្រូវចំនួន១០០តោន ត្រូវបានលក់នៅឆ្នាំ២០១៣ និង១២០តោន ត្រូវបានផលិត និងលក់នៅឆ្នាំ២០១៤។ គួរកត់សម្គាល់ថា ដើម្បីបំពេញតាមស្តង់ដា សរីរាង្គអន្តរជាតិ សម្រាប់ការនាំចេញ ត្រូវការចំណាយពេលវេលាយូរ ដើម្បីកសាងសមត្ថភាពកសិករឲ្យយល់ដឹងពីលក្ខខណ្ឌតម្រូវដោយប្រព័ន្ធត្រួតពិនិត្យគុណភាព។

- ទាំងសហគមន៍ និងសេដាក មានធនធានកំណត់ដើម្បីប្រមូលទិញស្រូវសរីរាង្គពីសមាជិក ក្នុងរដូវប្រមូលផល។ ប្រធានសហគមន៍បានប៉ាន់ប្រមាណថា នៅឆ្នាំនេះ ស្រូវសរីរាង្គប្រមាណ ៣០០តោន នឹងត្រូវផលិតដោយសមាជិកសហគមន៍ទាំងនៅក្នុងស្រុក និងស្រុកដែលនៅជិតខាង។ សហគមន៍បានខ្ចីទុនបន្ថែមពីសហគមន៍សន្សំប្រាក់ក្នុងឃុំ។ សហគមន៍រោងម៉ាស៊ីនកិនស្រូវស្តុកស្តម្ភ បានទិញស្រូវសរីរាង្គចំនួន១២០តោន។ ដើម្បីដោះស្រាយនូវបញ្ហាកង្វះថវិកា ផ្សារអង្គការសេដាក និងសហគមន៍ បានទិញស្រូវសរីរាង្គពីកសិករដោយជំពាក់ជាមួយលក្ខខណ្ឌដែលចែងថា ប្រសិនកសិករអនុញ្ញាតិឲ្យផ្សារអង្គការសេដាក និងសហគមន៍អាចទិញជំពាក់បាន នោះកសិករនឹងទទួលបាននូវតម្លៃបន្ថែម ២០រៀល/គ.ក្រ ក្នុង១ខែ ជាការប្រាក់។

### ៣.៤.២. ការគាំទ្រផលិតកម្ម និងទីផ្សារលើដំណាំបន្លែដោយអង្គការសេដាក

ដោយមានការគាំទ្រពីអង្គការសេដាក និងជីអាយហ្សេត ក្រុមផលិតបន្លែសរីរាង្គត្រូវបានបង្កើតឡើងដំបូងក្នុងឆ្នាំ២០០៧ ដោយមានសមាជិកសរុបចំនួន៧គ្រួសារ នៅភូមិថ្នរាប ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ សមាជិកក្រុមដែលធ្លាប់ផលិតបន្លែដោយប្រើប្រាស់សារធាតុគីមី អាចផលិតបន្លែបានក្នុងបរិមាណតិចតួចប៉ុណ្ណោះនៅរដូវវស្សា ហើយលក់ផលិតផលបានក្នុងតម្លៃទាប។ បន្ទាប់ពីទទួលបានការគាំទ្រពីអង្គការសេដាក ពួកគាត់បានផ្លាស់ប្តូរមករួមគ្នាជាក្រុមផលិតបន្លែសរីរាង្គវិញ។ បន្លែសរីរាង្គ ត្រូវបានលក់ផ្ទាល់ទៅផ្សារអង្គការសេដាកក្នុងទីក្រុងភ្នំពេញ។ នៅខេត្តកំពង់ឆ្នាំង ក្រុមដែលមានសមាជិកដំបូងចំនួន ៧នាក់ ក្នុងឆ្នាំ ២០០៧ បានពង្រីកនូវបរិមាណផលិតកម្មរបស់ខ្លួន និងបង្កើនសមាជិកក្នុងឃុំចំនួន២ទៀតក្នុងស្រុករលាប្អៀរ។ គិតត្រឹមឆ្នាំ២០១៤ មានសមាជិកក្រុមផលិតបន្លែសរីរាងសរុបមានចំនួន៤០នាក់។ ដំណើរការនៃការចងក្រងក្រុមផលិតមានរៀបរាប់ដូចខាងក្រោមៈ

**ជំហានទី១: ការរៀបចំការប្រជុំថ្នាក់ភូមិ និងការចងក្រងក្រុមៈ** ការប្រជុំត្រូវបានរៀបចំដោយគម្រោងអង្គការសេដាកក្នុងភូមិគោលដៅដែលត្រូវបានជ្រើសរើស ដើម្បីបង្ហាញពីគោលបំណង នៃការរៀបចំចងក្រងក្រុមផលិតបន្លែសរីរាង្គ។ ការប្រជុំបានកំណត់កសិករមួយចំនួន ដែលមានចំណាប់អារម្មណ៍ក្នុងការធ្វើការជាក្រុម។ គួរកត់សម្គាល់ថា កសិករដែលមានចំណាប់អារម្មណ៍ក្នុងការចូលរួមជាក្រុម រមែងជាកសិករដែលមានប្រភពទឹកល្អជាងអ្នកដទៃពី

អណ្ដូងស្នប់ ឬ អណ្ដូងលូ និងមានកម្លាំងពលកម្មអាចធ្វើការងារនេះបាន ដែលយ៉ាងហោចណាស់មានគ្នា២នាក់/១គ្រួសារ។ ធនធានទាំងនេះហើយ ដែលធ្វើឲ្យអ្នកចូលរួមសម្រេចចិត្តចូលរួមក្នុងក្រុមផលិតនេះ។

**ជំហានទី២: ការកសាងសមត្ថភាព ដល់សមាជិកក្រុមដែលមានចំណាប់អារម្មណ៍៖** កសិករចាប់អារម្មណ៍ ត្រូវបានបណ្ដុះបណ្ដាលជាស៊េរីពីវិធីសាស្ត្រផលិតបន្លែ។ ការបណ្ដុះបណ្ដាល ការប្រជុំរួមនឹងការធ្វើទស្សនៈកិច្ចសិក្សាត្រូវបានរៀបចំសម្រាប់កសិករ និងអ្នកដឹកនាំកសិករ។ ដើម្បីអាចផលិតបន្លែបាន វិធីសាស្ត្រក្នុងការផលិតត្រូវបានការផ្លាស់ប្ដូរ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលសម្របសម្រួលដោយគណៈកម្មការត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានបង្កើតឡើង។ គណៈកម្មការមានគ្នាសរុបចំនួន ៥នាក់ជាតំណាងមកពីក្រុមនីមួយៗ។ សមាជិកក្រុមគ្រប់រូបដឹងថា ប្រសិនបើគេរកឃើញថា បន្លែមានប្រើប្រាស់សារធាតុពុលគីមី នៅពេលនោះសមាជិកក្រុមនោះនឹងត្រូវបានបណ្ដេញចេញពីក្រុម និងធ្វើការផាកពិន័យផងដែរ។

**ជំហានទី៣: ផលិតកម្ម និងការភ្ជាប់ទៅទីផ្សារ៖** ក្រុមផលិតបន្លែសរីរាង្គ៣ក្រុម ដែលមានសមាជិក៤០នាក់ ត្រូវបានបង្កើតក្នុងឃុំចំនួន៣ នៃស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ ផែនការផលិតត្រូវបានរៀបចំរវាងអ្នកផលិតជាសមាជិកក្រុម និងអ្នកទិញ គឺអង្គការសេដាក។ បន្លែសរីរាង្គជាង១០ប្រភេទ ត្រូវបានប្រមូលផ្ដុំនៅតាមទីតាំងប្រមូលផ្ដុំផ្សេងៗគ្នា និងលក់ផ្ទាល់មកទីផ្សារអង្គការសេដាកនៅភ្នំពេញរៀងរាល់២ ទៅ ៣ដង ក្នុងមួយសប្ដាហ៍ក្នុងបរិមាណ ២៥០គីឡូក្រាមជាមធ្យមក្នុង១លើក។ ដំណើរការនេះ ត្រូវបានធ្វើឡើង ដោយមានការសម្របសម្រួលពីបុគ្គលិកអង្គការសេដាក។ នាពេលថ្មីៗនេះ គម្រោងអង្គការសេដាកត្រូវបានបញ្ចប់ ហើយគណៈកម្មការតាមក្រុមផលិតនីមួយៗ ចាប់ផ្ដើមចាត់ចែងដំណើរការនេះដោយខ្លួនឯង។

**តារាងទី 3: ដំណាក់កាលសំខាន់ៗ ក្នុងការរៀបចំក្រុមផលិតបន្លែសរីរាង្គ**

| សូចនាករ | ដំណាក់កាលមុនពេលរៀបចំ | ដំណាក់កាលបច្ចុប្បន្ន | ទស្សនវិស័យទុកពេលអនាគត/និរន្តរភាព |
|---|---|---|---|
| **ស្ថាប័ន** | - ពុំមានការចងក្រងក្រុមផលិត។<br>- សេដាកប្រើប្រាស់នូវមូលនិធិខាងក្រៅពីម្ចាស់ជំនួយ ដើម្បីពង្រឹងសមត្ថភាពកសិករ ដើម្បីបង្កើនផលិតកម្មបន្លែរបស់ពួកគាត់។ | - ក្រុមផលិតបន្លែសរីរាង្គត្រូវបានបង្កើតដោយមានសមាជិកសរុបចំនួន ៤០ នាក់។ សេដាកកំពុងកសាងសមត្ថភាពសមាជិកគណៈកម្មការដើម្បីបំពេញតម្រូវការរបស់គេ។ | - ក្រុមផលិតអាចធ្វើការពង្រីកខ្លួន និងអាចផលិតបន្លែបានច្រើនបន្ថែមទៀត ប្រសិនមានតម្រូវការបន្លែមពីទីផ្សារ។<br>- សមត្ថភាពសមាជិកគណៈកម្មការសហគមន៍គួរត្រូវបានពង្រឹង ដើម្បីលើក |

| | | | |
|---|---|---|---|
| | | - រចនាសម្ព័ន្ធគ្រប់គ្រង និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានភាពរឹងមាំ។ ថ្នាក់ដឹកនាំក្រុមស្ទើរតែទាំងអស់អាចធ្វើការសម្របសម្រួលដំណើរការផលិតកម្មរហូតដល់ទីផ្សារបានដោយខ្លួនឯង។ | ទឹកចិត្តឲ្យមានការគ្រប់គ្រងនិងការអភិវឌ្ឍបែបអាស្រ័យលើខ្លួនឯង។ |
| **ដំណើរការ** | - កសិករលក់កសិផលជាលក្ខណៈបុគ្គលទៅអ្នកក្នុងមូលដ្ឋាន ឬ ផ្សារក្នុងតំបន់។ | - ក្រុមបានផលិតបន្លែ ដើម្បីបម្រើសេចក្តីត្រូវការទីផ្សារបន្លែសរីរាង្គ។ សកម្មភាពសន្សំប្រាក់ក៏បានអនុវត្តដោយសមាជិកក្រុម ដើម្បីបំពេញនូវរាល់សេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុ ជាពិសេសក្នុងបំណងផលិតកម្ម។<br><br>- ក្រុមសន្សំបានចូលរួមចំណែកជាសំខាន់ ក្នុងការបម្រើនូវសេចក្តីត្រូវការហិរញ្ញវត្ថុរបស់សមាជិក។ ជាឧទាហរណ៍ មូលនិធិក្រុមសន្សំប្រាក់ ដែលមាន៧ក្រុមក្នុងភូមិធ្នង់កំបុត ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ មានចំនួនសរុបប្រមាណ ៣០លានរៀល ឬ ប្រហាក់ប្រហែល | - ដរាបណាមានតម្រូវការទីផ្សារចំពោះផលិតផលរបស់កសិករ ក្រុមនឹងនៅតែមានសកម្មភាព ហើយអាចបង្កើនផលិតកម្ម និងសមាជិករបស់ខ្លួនផងដែរ។ |

| | | | |
|---|---|---|---|
| | | ៧.៥០០ដុល្លារ។<br>- សេដាកកំពុងបន្តផ្តល់នូវការគាំទ្រ តាមរយៈការរៀបចំកិច្ចប្រជុំប្រចាំត្រីមាស សម្រាប់ថ្នាក់ដឹកនាំក្រុមផលិត។ | |
| **បណ្តាញ និងដៃគូ** | - ការតភ្ជាប់ក្រុមផលិតទៅនឹងបណ្តាញកសិករ និងធម្មជាតិ (ប.ក.ធ)។ | - សហព័ន្ធក្រុមផលិតបន្លែសរីរាង្គ ត្រូវបានបង្កើតឡើង ក្នុងខេត្តផ្សេងៗ: កំពត កំពង់ស្ពឺ តាកែវ និងខេត្តត្បូងឃ្មុំ ។ | - ពង្រឹងបណ្តាញ និងមជ្ឈមណ្ឌលស្តុកទុកបន្លែ។ |
| **ភ្នាក់ងារគាំទ្រផ្សេងៗ** | - ការបង្កើតក្រុមផលិត | - ចន្លោះឆ្នាំ ២០១១ ដល់ ២០១៤ សេដាក និង ជីអាយហ្សេត បានគាំទ្រការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងក្រោយពេលប្រមូលផល។ | - សេដាកនឹងសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម ដើម្បីបង្កើតប្រព័ន្ធត្រួតពិនិត្យគុណភាពដោយមានការចូលរួម ដែលសមាជិកម្នាក់ៗចូលរួមធានានូវគុណភាពផលិតផល។ |

*ប្រភពៈ ការសម្ភាសបុគ្គលិកសេដាក នៅថ្ងៃទី១៩/២១ ខែមករា ឆ្នាំ២០១៥ និងថ្នាក់ដឹកនាំក្រុមផលិតបន្លែ នៅថ្ងៃទី៨/១៤ ខែកុម្ភៈ ឆ្នាំ ២០១៥ ។*

**តារាងទី 4: ឥទ្ធិពលលើការប្រកបរបរចិញ្ចឹមជីវិត តាមរយៈក្រុមផលិតបន្លែសរីរាង្គ**

| ផលិតកម្ម | មុនគម្រោង | ស្ថានភាពបច្ចុប្បន្ន |
|---|---|---|
| **កម្រិតបុគ្គល** | - កសិករផលិតបន្លែដោយប្រើប្រាស់ជីគីមី ថ្នាំពុលគីមីដែលប៉ះពាល់ដល់សុខភាព ហើយលក់បន្លែក្នុងបរិមាណតិចតួចទៅ | - កសិករអាចដាំដុះបន្លែបានច្រើនមុខ និងពេញមួយឆ្នាំ។<br>- បន្លែត្រូវបានលក់មកផ្សារអង្គការសេដាក |

| | | |
|---|---|---|
| | ផ្សារក្នុងមូលដ្ឋាន។<br>- ការដាំដុះធ្វើឡើងតែក្នុងរដូវវស្សា ហើយមានបន្លែតិចប្រភេទប៉ុណ្ណោះ។<br>- សមាជិកគ្រួសារពឹងពាក់ស្ទើរតែទាំងស្រុងទៅលើផលិតកម្មស្រូវតែមួយមុខ។ | ហើយតម្លៃខ្ពស់ជាងទ្វេដង ប្រៀបធៀបតម្លៃលក់នៅទីផ្សារក្នុងតំបន់។ បន្លែដែលផលិតលើសក៏ងាយស្រួលលក់ក្នុងតំបន់ផងដែរ។<br>- ផលិតកម្មបន្លែសរីរាង្គ បានក្លាយជាប្រភពចំណូលសំខាន់ នៅពេលដែលផលិតកម្មស្រូវ និងការចិញ្ចឹមសត្វជាចំណូលបន្ទាប់បន្សំក្នុងគ្រួសារ។ |
| **កម្រិតក្រុម** | - កសិករអាចដាំដុះបន្លែបានតែនៅរដូវវស្សាពិសេសសម្រាប់ការហូបចុកក្នុងគ្រួសារ។ សមាជិកក្រុម អាចរកចំណូលបានប្រមាណពី២៥ ទៅ ៧៥ដុល្លារ ក្នុង ១ខែ ដោយផលិតកម្ម ធ្វើឡើងក្នុងទ្រង់ទ្រាយតូច និងលក់ដូរបន្តិចបន្តួចក្នុងតម្លៃទាប។ | - កសិករអាចដាំដុះបន្លែសរីរាង្គបានពេញមួយឆ្នាំ ហើយលក់មកទីផ្សារអង្គការសេដាកក្នុងតម្លៃខ្ពស់ (ប្រមាណ១០០% លើសតម្លៃទីផ្សារក្នុងតំបន់)។ ការសិក្សាបង្ហាញថា សមាជិកក្រុមអាចរកចំណូលបានប្រមាណ១៥០-២០០ដុល្លារ/១ខែ។<br>- ទំហំដីដាំដុះ បានកើនពី ៥.៥អា ទៅ ៨.៥អា ជាមធ្យមក្នុង១គ្រួសារ និងពី ៦ខែ ទៅពេញ១ឆ្នាំ។<br>- ផលិតកម្មបន្លែ បានកើនឡើង ៣ដង គឺពី ៤៧៥គ.ក្រ ទៅ ១៣៣៦គ.ក្រ ក្នុង១គ្រួសារក្នុង១ឆ្នាំ។<br>- ប្រាក់ចំណូលបានកើនឡើងស្ទើរ ១០ដង ប្រៀបធៀបនឹងចំណូលដែលរកបានពីមុន (ទិន្នន័យដើម ១៣៩ដុល្លារ ហើយនៅឆ្នាំ ២០១៤ បានកើនដល់ ១.៣២១ដុល្លារ)។ ការកើនឡើងនេះ គឺអាស្រ័យដោយ បន្លែសរីរាង្គ ត្រូវបានលក់មកទីផ្សារអង្គការសេដាកក្នុងតម្លៃថ្លៃជាងតម្លៃលក់នៅផ្សារក្នុងស្រុក ការកើនឡើងនូវផ្ទៃដីដាំដុះ និងរយៈ |

| | | |
|---|---|---|
| | | ពេលដាំដុះ ដែលផ្លាស់ប្តូរពី៦ខែ រហូតពេញមួយឆ្នាំ។ លើសពីនេះ ចំណូលផ្សេងទៀត ពីការចិញ្ចឹមសត្វ ផលិតកម្មស្រូវ និងសកម្មភាពក្រៅកសិកម្មក៏បានកើនឡើងផងដែរ។ |
| **កម្រិតសហគមន៍** | - កសិករមួយចំនួនតូច ដាំដុះបន្លែបន្តិចបន្តួចសម្រាប់លក់នៅទីផ្សារ ប៉ុន្តែផលិតកម្មនៅមានកម្រិតនៅឡើយ។ | - កសិករមួយចំនួន អាចផលិតពូជដំណាំមួយចំនួន ដោយខ្លួនឯង និងប្រើប្រាស់សម្រាប់ការដាំដុះលើកក្រោយៗទៀត និងលក់ទៅអ្នកជិតខាងផងដែរ។<br>- ផលិតកម្មបន្លែនៅរដូវវស្សា មានចំនួនច្រើនលើសពីសេចក្តីត្រូវការ (ប្រមាណ៥០% នៃផលិតកម្មបន្លែសរុប) ។ សមាជិកក្រុមសម្រេចចិត្តលក់បន្លែទាំងនោះទៅទីផ្សារក្នុងតំបន់។ បើទោះណា បន្លែដែលពួកគាត់លក់ មានតម្លៃប្រហាក់ប្រហែលនឹងបន្លែធម្មតា ប៉ុន្តែពួកគាត់អះអាងថា បន្លែសរីរាង្គរបស់ពួកគេ ងាយស្រួលលក់ជាងបន្លែធម្មតា ដោយសារអ្នកបរិភោគស្គាល់សមាជិកក្រុមបន្លែសរីរាង្គ។ |

*ប្រភពៈ ការសម្ភាសបុគ្គលិកសេដាក នៅថ្ងៃទី១៩/២១ ខែមករា ឆ្នាំ២០១៥ និងក្រុមផលិតបន្លែ នៅថ្ងៃទី៨/១៤ ខែកុម្ភៈ ឆ្នាំ ២០១៥*

**បញ្ហាប្រឈមៈ**

- សមាជិកក្រុមមួយចំនួនប្រឈមនឹងកង្វះទឹកស្រោចស្រព កំឡុងរដូវប្រាំង ពីខែមីនារហូតខែឧសភា ដែលធ្វើឲ្យពួកគាត់ អាចផលិតបន្លែបានក្នុងបរិមាណតិចជាងធម្មតា។
- កង្វះកម្លាំងពលកម្មជាឧបសគ្គសម្រាប់កសិករដាំបន្លែ ប្រសិនពួកគាត់ចង់ពង្រីកផលិតកម្មរបស់ខ្លួន។ កសិករមានដីផលិតកម្មប្រមាណ ០.៥ហ.ត/គ្រួសារ។ អ្នកដែលធ្វើការងារក្នុងផលិតកម្មបន្លែ ភាគច្រើនស្ថិតក្នុងវ័យ ៥០ឆ្នាំ។ គ្រួសារដែលមានសមាជិកជាមធ្យម ២នាក់ អាចដាំដុះបន្លែលើដីប្រមាណ៥០០

ម៉ែត្រក្រឡា។ ទោះយ៉ាងណា លទ្ធភាពទទួលបានអគ្គីសនីប្រើប្រាស់បានចូលរួមចំណែកដល់ការពង្រីកទំហំផលិតកម្ម នៅពេលគេអាចប្រើម៉ាស៊ីនបូមទឹកសម្រាប់ការស្រោចស្រព។

- ប្រភេទបន្លែមួយចំនួន មិនអាចទុកពូជសម្រាប់ដាំដុះនៅរដូវបន្ទាប់បានទេ។ ជាទូទៅ កសិករទិញពូជពីផ្សារក្នុងតំបន់ ឬ ទីរួមខេត្ត។ ទោះយ៉ាងណា ពូជទាំងនោះមានអត្រាកម្រិតដុះទាប ដែលជាហេតុធ្វើឲ្យមានការចំណាយខ្ពស់ក្នុងផលិតកម្ម។

**មតិយោបល់៖**

- លក្ខខណ្ឌតម្រូវអប្បបរមា សម្រាប់សមាជិកក្រុមផលិតបន្លែសរីរាង្គ គឺប្រភពទឹកប្រើប្រាស់ តាមរយៈស្រះ ឬអណ្តូង។ ការចិញ្ចឹមគោក្របី ក៏បានចូលរួមចំណែកក្នុងប្រព័ន្ធផលិតកម្មផងដែរ ក្នុងចំណោមអ្នកផលិតបន្លែទាំងអស់។

- ការពង្រីកចំនួនសមាជិកក្រុម មិនមែនជាការលំបាកទេ ដោយសារប្រជាជនក្នុងសហគមន៍បានដឹងពីអត្ថប្រយោជន៍ជាវិជ្ជមានពីផលិតកម្មបន្លែសរីរាង្គ។ ទោះយ៉ាងណា ការរៀបចំក្រុមបានក៏ត្រូវពឹងអាស្រ័យលើសមត្ថភាពទីផ្សារដើម្បីស្រូបយកផលិតផលពីសហគមន៍ផងដែរ។

- យើងបានរកឃើញថា ផលិតកម្មបន្លែ ត្រូវបានអនុវត្តជាសំខាន់ ដោយក្រុមមនុស្សមានវ័យចាស់ ខណៈដែលកម្លាំងវ័យក្មេងធ្វើការក្នុងវិស័យឧស្សាហកម្ម ពិសេសជាកម្មករកាត់ដេរ។ ការចំណាយលើការវិនិយោគលើដីផលិតកម្មទំហំ ៥០០ម៉ែត្រក្រឡា ប្រហាក់ប្រហែល ៥០០ដុល្លារ។ ទឹកប្រាក់នេះនឹងត្រូវចំណាយលើការសាងសង់រោង ធ្វើរង គ្រោងឈើ ម៉ាស៊ីនបូមទឹក និងពាងសម្រាប់ស្តុកទឹក។

- វិធីដាំដុះតាមបែបសរីរាង្គ ចំណាយកម្លាំងពលកម្ម និងការខិតខំប្រឹងប្រែងច្រើនជាងផលិតកម្មធម្មតា។ វាទាមទារឲ្យមានការប្រើប្រាស់សារធាតុសរីរាង្គច្រើន និងចំណេះដឹងបច្ចេកទេសផងដែរ។ ក៏ប៉ុន្តែ ការកំណត់តម្លៃថេររបស់អង្គការសេដាក ដែលជាធម្មតាខ្ពស់ជាងតម្លៃទីផ្សារក្នុងស្រុក គឺមានសារៈសំខាន់ ដើម្បីទាក់ទាញកសិករ និងលើកទឹកចិត្តពួកគាត់ ឲ្យបន្តអនុវត្តការធ្វើកសិកម្មតាមបែបសរីរាង្គ។

### ៣.៤.៣. ការគាំទ្រផលិតកម្ម និងទីផ្សារបន្លែសុវត្ថិភាពដោយដៃគូរបស់អង្គការអេសអិនវី

សហព័ន្ធសមាគមកសិករកម្ពុជានៃអ្នកផលិតកសិកម្ម (ស៊ីហ្វាប) ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើការនៅក្នុងខេត្តស្វាយរៀង។ ចាប់ពីឆ្នាំ២០១២ រហូតមកទល់បច្ចុប្បន្ន ក្រោមកម្មវិធីកសិកម្មដែលឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ អង្គការអេសអិនវី បានសហការគាំទ្រដល់អង្គការ ស៊ីហ្វាប ដើម្បីអនុវត្តគម្រោងកសិកម្មឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក្នុងភូមិចំនួន ៩ នៅក្នុងឃុំចំនួន ៦ នៃស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។ មុនការគាំទ្រដោយអង្គការអេសអិនវី ស៊ីហ្វាបមានក្រុមសមាគមកសិករចំនួន៦ នៅកម្រិតឃុំ។ ក្នុងចំណោមសមាគមទាំង៦ មានសមាគម៤ ដែលត្រូវបង្កើតឡើងដោយអង្គការស៊ីហ្វាប និង២ផ្សេងទៀត បង្កើតឡើងដោយ

អង្គការស៊ីដសេ និងគាំទ្របន្តដោយអង្គការស៊ីហ្វាប។ គួរកត់សម្គាល់ថា មានក្រុមផលិត៣ប្រភេទដែលស្ថិតនៅក្រោមឆ័ត្រសមាគមកសិករ។ ក្នុងផលិតកម្មបន្លែ មានសមាជិកផលិតបន្លែចំនួន៣១៩នាក់ ក្នុងនោះស្រីមានចំនួន ១១៥នាក់ ស្មើនឹង ៣១% នៃសមាជិកសរុប។

សមាគមកសិករ ត្រូវបានបង្កើតឡើង ដោយស៊ីហ្វាប តាមជំហានដូចខាងក្រោម៖

**ជំហានទី១: ការបង្កើនការយល់ដឹង៖** ការប្រជុំត្រូវបានរៀបចំ ដើម្បីបង្កើនការយល់ដឹងពីផលិតកម្មបន្លែសុវត្ថិភាព ក្នុងចំណោមក្រុមផលិតបន្លែ។ អ្នកចូលរួម ៤០នាក់ជាមធ្យម បានចូលរួមក្នុងកិច្ចប្រជុំ១លើកៗ។

**ជំហានទី២: ការរៀបចំក្រុម៖** ក្នុងដំណាក់កាលដំបូង កសិករសមាជិកចំនួន ៧នាក់ បានចងក្រងគ្នាជាក្រុម។ ក្រុមនីមួយៗមានថ្នាក់ដឹកនាំ៣នាក់ (ប្រធាន អនុប្រធាន និងបេឡា) ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកក្រុម។

**ជំហានទី៣: ការរៀបចំធ្វើមហាសន្និបាត សមាគមកសិករ៖** លក្ខន្តិកៈសមាគមកសិករដែលត្រូវបានពង្រាងដោយអង្គការ ស៊ីហ្វាប ត្រូវបានយកមកពិភាក្សាបញ្ចប់ និងអនុម័ត ដោយសមាជិកនៃសមាគមកសិករនីមួយៗ ក្នុងកំឡុងពេលមហាសន្និបាត។ គណៈកម្មការគ្រប់គ្រងសមាគមក៏ត្រូវបានរៀបចំផងដែរ ក្នុងកំឡុងមហាសន្និបាត។ គណៈកម្មការគ្រប់គ្រងសមាគមនីមួយៗ មានសមាជិក៥រូប រួមមាន ប្រធាន អនុប្រធាន បេឡា និងសមាជិក២រូបទៀត។ គួរកត់សម្គាល់ថា ថ្នាក់ដឹកនាំ៣រូបនៃក្រុមកសិករនីមួយៗ ត្រូវបានអញ្ជើញឲ្យឈរឈ្មោះជាបេក្ខជនជាគណៈកម្មការគ្រប់គ្រងសមាគមកសិករ។ មេភូមិ និងមេឃុំ ក៏ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងមហាសន្និបាតនេះផងដែរ។

**ជំហានទី៤: ការរៀបចំមហាសន្និបាត ជ្រើសរើសក្រុមប្រឹក្សាយោបល់សមាគមកសិករ៖** សមាជិកក្រុមប្រឹក្សាយោបល់ចំនួន ៤រូប ត្រូវបានជ្រើសរើស ដោយសមាជិកសមាគមកសិករនីមួយៗ។

ជាទូទៅ គេត្រូវការរយៈពេលពី ៥ទៅ ៦ខែ ដើម្បីបង្កើតបាន សមាគមកសិករ ១។ ពេលវេលានេះ មិនរាប់បញ្ចូលការគាំទ្រពង្រឹងសមត្ថភាពសមាគម ដែលត្រូវបានផ្តល់ដោយអង្គការស៊ីហ្វាប ក្រោយសមាគមកសិករត្រូវបានបង្កើត។

ដំណើរការៈ សមាគមកសិករ/សហគមន៍កសិករ ផ្តល់សេវាកម្មធំៗ ៣ប្រភេទ ៖

១) **ការសន្សំ និងសេវាកម្មឥណទាន៖** គួរកត់សម្គាល់ថា សមាជិកសមាគមកសិករបានធ្វើការសន្សំរួមគ្នា ដើម្បីផ្តល់សេវាកម្មឥណទានដល់សមាជិកខ្លួន និងភូមិជទៃផ្សេងទៀត។ អត្រាការប្រាក់ចន្លោះពី ២ ទៅ ៣% ក្នុង១ខែ ជាមួយរយៈពេលកម្ចី ០៦ខែ។

២) **ការផ្គត់ផ្គង់ធាតុចូលកសិកម្ម** (ឧទាហរណ៍ គ្រាប់ពូជបន្លែ ថ្នាំងកៅស៊ូ និងសម្ភារៈកសិកម្មផ្សេងទៀត)៖ នេះបង្កលក្ខណៈងាយស្រួលដល់កសិករទទួលបាននូវធាតុចូលកសិកម្មសម្រាប់ផលិតកម្ម។

៣) **ការផ្សព្វផ្សាយកសិកម្ម៖** ការផ្សព្វផ្សាយកសិកម្មផ្តោតជាសំខាន់ទៅលើផលិតកម្មបន្លែ ស្រូវ និងការចិញ្ចឹមមាន់។

អេសអិនវី បានផ្តល់នូវការកសាងសមត្ថភាពដល់សមាគមកសិករ ស្តីអំពីកសិកម្មដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេស ដើម្បីគាំទ្រកសិករ ពង្រឹងសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ការអនុវត្តកសិកម្មដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុមួយចំនួន ដែលបានផ្តល់ដល់កសិករមានដូចជាៈ

១) ការបណ្តុះបណ្តាលពីការស្តុកទឹកទុក និងប្រព័ន្ធផ្គត់ផ្គង់៖ ប្រភេទស្រះក្រាលប្លាស្ទិក ត្រូវបានណែនាំដល់កសិករចូលរួម។ អេសអិនវីក៏បានសហការជាមួយអាជ្ញាធរដែនដី ដើម្បីតម្លើងស្នប់រវៃ សម្រាប់កសិករ និងផ្តល់វគ្គបណ្តុះបណ្តាលពីការថែទាំស្នប់រវៃផងដែរ។

២) ការបណ្តុះបណ្តាលពីភាពងាយរងគ្រោះនៃបម្រែបម្រួលអាកាសធាតុ និងការធ្វើការវាយតម្លៃផលប៉ះពាល់៖ លទ្ធផលដែលបានពីការវាយតម្លៃនេះ បានជួយដល់កសិករក្នុងការវាយតម្លៃពីផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ លើផលិតកម្មកសិកម្ម និងការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ ហើយក៏ធ្វើឲ្យពួកគាត់បានយល់ដឹងពីវិធានការណ៍ ដើម្បីឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុ។ ក្នុងពេលជាមួយគ្នានោះ វាក៏ផ្តល់នូវគំនិតដល់កសិករដើម្បីរៀបចំគំរូប្លង់ ឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ និង ដើម្បីដោះស្រាយនឹងបម្រែបម្រួលអាកាសធាតុនាពេលអនាគតផងដែរ។ បន្ថែមលើសនេះ លទ្ធផលដែលបានពីការប៉ាន់ប្រមាណ ក៏លើកទឹកចិត្តឲ្យក្រុមប្រឹក្សាឃុំ ធ្វើសមាហរណកម្មសកម្មភាពកសិកម្ម ដែលឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុទៅក្នុងកម្មវិធីវិនិយោគឃុំផងដែរ។

៣) ការរៀបចំទិវាស្រែកសិករ៖ ដើម្បីផ្ទេរ និងផ្សព្វផ្សាយការអនុវត្តកសិកម្មល្អ ពីកសិករទៅកសិករ។

៤) បណ្តុះបណ្តាលកសិករពីវិធីស្រោចស្រពលើការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព ក្នុងផលិតកម្មបន្លែ ហើយក្នុងពេលជាមួយគ្នានោះ លើកទឹកចិត្តពួកគាត់ឲ្យកត់ត្រានូវចំណាយ និងចំណូលពីបន្លែផងដែរ។

**តារាងទី 5: ដំណាក់កាលនៃវឌ្ឍនភាពសំខាន់ៗ ក្នុងការរៀបចំក្រុមផលិតបន្លែ និងសមាគមកសិករ**

| សូចនាករ | ដំណាក់កាលមុនពេលមានក្រុម/សមាគម | ដំណាក់កាលបច្ចុប្បន្ន | ការរំពឹងទុកទៅថ្ងៃអនាគត/និរន្តរភាព |
|---|---|---|---|
| **ស្ថាប័ន** | - សមាគមកសិករចំនួន ៦ត្រូវបានរៀបចំដោយស៊ីហ្វាប/ស៊ីដសេ មុនពេលមានអន្តរាគមន៍របស់អង្គការអេសអិនវី ក្នុងគម្រោងកសិកម្មឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ។ | - គណៈកម្មការគ្រប់គ្រងសមាគម មានសមត្ថភាពសម្របសម្រួលការគ្រប់គ្រងទូទៅ និងប្រតិបត្តិការប្រចាំថ្ងៃរបស់សមាគម។<br>- សមាជពេញអង្គដែលមានសមាជិកទាំងអស់ចូលរួម ត្រូវបានរៀបចំយ៉ាងហោច ១ដង/ឆ្នាំ។<br>- កិច្ចប្រជុំប្រចាំខែ ក្នុងចំណោមគណៈកម្មការគ្រប់គ្រងសមាគម ត្រូវបានរៀបចំជាទៀងទាត់។<br>- កិច្ចប្រជុំ ឬ ការបណ្តុះបណ្តាលសម្រាប់សមាជិកសមាគម ត្រូវបានរៀបចំ តែនៅពេលណា ដែលមានអន្តរាគមន៍របស់ស៊ីហ្វាប ឬអង្គការដទៃផ្សេងទៀតប៉ុណ្ណោះ។ | - ដោយមានការគាំទ្រពីអង្គការស៊ីហ្វាប សមាគមទាំងនោះនឹងមានដំណើរការល្អ។ |
| **ដំណើរការ** | - ក្រោយការបង្កើតឡើងសមាគមបានផ្តល់ការផ្សព្វផ្សាយពីកសិកម្ម និងសេវាសន្សំ និងឥណទានដល់សមាជិករបស់ខ្លួន។ | - ក្នុងការធ្វើការងារជាក្រុម កសិករចាំបាច់ត្រូវធ្វើការសម្របសម្រួលឲ្យមានការលក់រួម នូវផលិតផលបន្លែរបស់ខ្លួននាពេលអនាគត។<br>- នាពេលបច្ចុប្បន្ន សមាគមកសិករ បានទទួលមូល | - តួនាទីរឹងមាំនៃសេវាឥណទាននេះ និងសមត្ថភាពរបស់សមាគម ក្នុងការបង្កើត ចំណូល នឹងដឹកនាំសមាគមកសិករ ឆ្ពោះទៅរកនិរន្តរភាពហិរញ្ញវត្ថុនាពេលអនាគត។ |

| | | | |
|---|---|---|---|
| | | និធិបន្ថែម ជាប្រាក់កម្ចីពី អង្គការស៊ីហ្វាប ដើម្បីផ្តល់សេវាឥណទានដល់សមាជិកកសិកររបស់ខ្លួន និងអ្នកភូមិផ្សេងទៀត។ | |
| **បណ្តាញនិងដៃគូ** | - ដូចបានរៀបរាប់ខាងលើសមាគមកសិករត្រូវបានបង្កើតឡើងនិងទទួលការគាំទ្រពីអង្គការស៊ីហ្វាប។ ដូច្នេះ សមាគមទាំងនេះ បានធ្វើការក្នុងភាពជាដៃគូជាមួយអង្គការស៊ីហ្វាប ដើម្បីផ្តល់សេវាកម្មការផ្សព្វផ្សាយកសិកម្ម និងឥណទានទៅដល់សមាជិក និងសហគមន៍ផងដែរ។ | - អេសអិនវី ក្នុងគម្រោងកសិកម្ម ឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ មានផែនការ ក្នុងការធ្វើឲ្យប្រសើរឡើង នូវការតភ្ជាប់ទីផ្សារ សម្រាប់កសិករគោលដៅ។ អង្គការមួយ ឈ្មោះ អាយវីវ៉ាយ បានកំពុងធ្វើការលើចង្វាក់ផ្គត់ផ្គង់ បន្លែទៅកាន់ទីផ្សារ (ដូចជាផ្សារសួនធម្មជាតិ កាស៊ីណូ ភោជនីយដ្ឋាននៅក្រុងបាវិត នៃព្រំប្រទល់ដែន កម្ពុជា វៀតណាម និងផ្សារទំនើប អ៊ីអន។<br>- ការប្រជុំពិគ្រោះយោបល់ រវាងអេសអិនវី និងផ្សារសួនធម្មជាតិ ត្រូវបានរៀបចំ។ បច្ចុប្បន្ន អេសអិនវី បាននឹងកំពុងធ្វើការបន្ថែមទៀត ជាមួយភាគីអ្នកផ្គត់ផ្គង់ ដើម្បីធានាទាំងគុណភាព និងបរិមាណ សម្រាប់ទីផ្សារប្រភេទនេះ។<br>- ស៊ីហ្វាប បានផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត និងគាំទ្រសមាគមកសិករ ដើម្បីចុះឈ្មោះជាសហគមន៍កសិករ។ | - ស៊ីហ្វាប រំពឹងទុកថា សមាគមកសិករទាំងនេះ គឺជាដៃគូជាយុទ្ធសាស្ត្រ ដើម្បីផ្តល់សេវាកម្ម/ឥណទានសម្រាប់និរន្តរភាពស្ថាប័ននាពេលអនាគត។ |

| | | | |
|---|---|---|---|
| **ភ្នាក់ងារគាំទ្រ** | - មន្ទីរកសិកម្មខេត្តស្វាយរៀងបានចូលរួមពង្រឹងនិងគាំទ្រសមាគមទាំងនេះ។ | - អេសអិនវីក្នុងគម្រោងកសិកម្មឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ បានបង្កើតនូវទំនាក់ទំនងរវាងមន្ទីរកសិកម្មខេត្តស្វាយរៀងជាមួយនឹងគម្រោង។ ការនេះនឹងបង្កភាពងាយស្រួល ដល់គម្រោងកសិកម្មឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ និងមានឥទ្ធិពលទៅលើការរៀបចំយុទ្ធសាស្ត្ររបស់មន្ទីរកសិកម្មខេត្ត ស្តីអំពីកសិកម្ម ដែលឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ។ | - យើងរំពឹងថា មន្ទីរកសិកម្មខេត្ត នឹងដាក់បញ្ចូលកសិកម្មដែលឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ ទៅក្នុងផែនការរបស់ខ្លួន ដែលនឹងធ្វើឲ្យសមាគមកសិករមានភាពរឹងមាំ និងនិរន្តរភាព។ |

*ប្រភពៈ ការសម្ភាសបុគ្គលិកអេសអិនវី នៅថ្ងៃទី ៣១ខែធ្នូ ឆ្នាំ២០១៤ និងនៅថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៥ និងដៃគូអេសអិនវី នៅថ្ងៃទី ១២-១៣ ខែកុម្ភៈ ឆ្នាំ ២០១៥។*

**តារាងទី 6: ឥទ្ធិពលទៅលើការប្រកបរបរចិញ្ចឹមជីវិត តាមរយៈក្រុមផលិតបន្លែ និងសមាគមកសិករ**

| ផលិតកម្ម | មុន | ពេលបច្ចុប្បន្ន |
|---|---|---|
| **កម្រិតបុគ្គល** | - កសិករពឹងអាស្រ័យលើទឹកភ្លៀងជាប្រភពទឹកសំខាន់ ។ មានតែកសិករតិចតួចប៉ុណ្ណោះ ដែលអាចដាំបន្លែ និងលក់នៅទីផ្សារ។<br>- ដីសម្រាប់ផលិតកម្មបន្លែ មានប្រមាណ ៧០ម៉ែត្រក្រឡា ក្នុង ១គ្រួសារ។ | - កសិករភាគច្រើនក្នុងតំបន់គោលដៅគម្រោង មានស្រះទឹក សម្រាប់ស្តុកទឹកភ្លៀង ប៉ុន្តែប្រភពទឹកនោះ មិនគ្រប់គ្រាន់សម្រាប់ការដាំដុះបន្លែពេញ១ឆ្នាំឡើយ។<br>- ផ្អែកតាមទិន្នន័យ ដែលប្រមូលដោយអង្គការអេសអិនវី ក្នុងគម្រោងកសិកម្មឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ កសិករចំនួន២០កសិករ ដែលអនុវត្តបច្ចេកវិទ្យា កសិកម្មឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ បានបង្ហាញថា កសិករបានជ្រើសរើសដំណាំ ដែលដុះលូតលាស់លឿនក្នុងរយៈពេលខ្លី និងធន់នឹងភាពរាំងស្ងួត។ កសិករសហការស្ទើរតែទាំងអស់ បានបង្កើនផ្ទៃដីដាំដុះ សម្រាប់ផលិតកម្មបន្លែពី ៧០ម៉ែត្រក្រឡា ទៅដល់ ៣២០ម៉ែត្រក្រឡាជាមធ្យម។ បរិមាណបន្លែផលិត បានកើនឡើងពី ៦០គ.ក្រ ទៅដល់ ៣៤០គ.ក្រ/១គ្រួសារ ជាមធ្យម។ ផលិតភាពបានកើនឡើងពី ០.៨៦ គ.ក្រ ទៅដល់ ១.០៦គ.ក្រ/ម៉ែត្រក្រឡា។ ប្រាក់ចំណូលបានកើនឡើងពី ១៧៤.៩០០រៀល ទៅដល់ ៦៣២.៦០០រៀល/គ្រួសារ ជាមធ្យម ឬ កើនឡើង ២៦២%។<br>- សន្តិសុខស្បៀងក្នុងគ្រួសារបានកើនឡើង។ សំខាន់ជាងនេះទៀត កសិករប្រើប្រាស់បន្លែពីកសិដ្ឋានខ្លួនឯងសម្រាប់បរិភោគ ដែលធ្វើឲ្យពួកគាត់មានសុខភាពល្អ។ ពួកគាត់ក៏ទទួលបានត្រី ពីស្រះក្រាលសំពត់ប្លាស្ទិកសម្រាប់ |

| | | |
|---|---|---|
| | | បរិភោគក្នុងគ្រួសារផងដែរ។ ប្រាក់ចំណូលដែលបានពីការលក់បន្លែ រួមនឹងចំណូលពីការងារមិនមែនកសិកម្ម បានធ្វើឲ្យចំណូលគ្រួសារទាំង មូលមានការកើនឡើង និងជីវភាពល្អប្រសើរជាងមុនផងដែរ។ |
| **កម្រិតក្រុម** | | - សាមគ្គីភាពនិងការសហការក្នុងចំណោមកសិករ មានភាពប្រសើរឡើង នៅពេលពួកគេបានចងក្រងគ្នាជាក្រុម ឬ ជាសមាគមកសិករ។ ការនេះ ក៏មានសារៈសំខាន់ផងដែរ សម្រាប់សកម្មភាពផ្សព្វផ្សាយកសិកម្ម ។<br>- អេសអិនវីមានគម្រោងគាំទ្រស្ត្រីជាកសិករ តាមរយៈការកែច្នៃបន្លែ។ ការនេះ នឹងអាចជួយឲ្យស្ត្រីជាកសិករ អាចបង្កើនតម្លៃផលិតផលបន្លែរបស់ពួកគាត់ផងដែរ។<br>- សមាជិកក្រុមផលិតបន្លែមិនបានលក់បន្លែរួមគ្នាទេ ប៉ុន្តែលក់ជាបុគ្គលរៀងៗខ្លួន។ ៤០%នៃបរិមាណបន្លែ សរុប ត្រូវបាននាំពីភូមិ ទៅលក់នៅផ្សារក្នុងខេត្តស្វាយរៀង ២០% លក់ទៅឲ្យគ្រួសារនៅក្បែរខាង និង ៤០%ទៀត លក់នៅផ្សារក្នុងស្រុក។ |
| **កម្រិតសហគមន៍** | - អាស្រ័យលើភាពងាយរងគ្រោះនៃបម្រែបម្រួលអាកាសធាតុ និងរបាយការណ៍ប៉ាន់ប្រមាណផលប៉ះពាល់ ដែលធ្វើឡើងដោយអង្គការអេសអិនវីនៅឆ្នាំ ២០១៤ បានបង្ហាញថា ប្រមាណ ៧០% នៃគ្រួសារសរុប ក្នុងឃុំដែលបានធ្វើការ | - អាស្រ័យកង្វះទឹកប្រើប្រាស់ កសិករចាំបាច់បង្កើននូវសមត្ថភាពប្រើប្រាស់ទឹក កំឡុងគ្នានេះ ក៏ត្រូវពង្រឹងជំនាញបច្ចេកទេស ក្នុងការអនុវត្តកសិកម្មដែលប្រើប្រាស់ទឹកតិចផងដែរ នោះគឺការអនុវត្តកសិកម្មដែលឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុនោះឯង។ |

| |
|---|
| សិក្សា បានខ្ចីប្រាក់ពីធនាគារ។<br>ទំហំកម្ចីជាមធ្យម ៥០០ដុល្លារ<br>និងខ្ពស់បំផុត ២៥០០ដុល្លារ<br>ក្នុងអត្រាការប្រាក់ ១.៩ ទៅ<br>៣% ក្នុង១ខែ។ |

ប្រភព: ការសម្ភាសបុគ្គលិកអង្គការអេសអិនវី នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និងថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៥ អង្គការដៃគូរបស់អេសអិនវី និងក្រុមផលិតបន្លែ នៅថ្ងៃទី១២-១៣ ខែកុម្ភៈ ឆ្នាំ២០១៥។

**បញ្ហាប្រឈម ដំណោះស្រាយ និងលទ្ធផលៈ**

- ការយល់ដឹងក្នុងចំណោមកសិករ អាជ្ញាធរដែនដី (មេភូមិ មេឃុំ និងក្រុមប្រឹក្សាឃុំផ្សេងៗទៀត) ស្តីអំពីទស្សនៈទាន នៃបម្រែបម្រួលអាកាសធាតុ និងកសិកម្មដែលឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ នៅមានកម្រិតនៅឡើយ។ ជាការឆ្លើយតប គម្រោងបានរៀបចំសកម្មភាពបង្កើនការយល់ដឹងពីបម្រែបម្រួលអាកាសធាតុ។ ប្រជាជនប្រមាណ ៣០០នាក់ រួមមានកសិករ និងអាជ្ញាធរដែនដី បានបង្កើនចំណេះដឹងរបស់ខ្លួន និងការបន្សាំទៅនឹងការប្រែប្រួលនេះ។

- សម្ភារៈកសិកម្មមួយចំនួន មិនអាចរកបាននៅក្នុងសហគមន៍។ ជាអាទិ៍កសិករមិនអាចស្វែងរកផ្ទាំងប្លាស្ទិក ឬ សម្ភារៈដែលអាចជំនួសបាន ក្នុងតំបន់របស់ពួកគាត់។ ផ្ទាំងប្លាស្ទិកមានតម្លៃខ្ពស់ ប្រមាណ ១០០ដុល្លារ សម្រាប់ស្រះ១។ បញ្ហានេះ ធ្វើឲ្យរាំងស្ទះដល់ដំណើរ ការបច្ចេកទេសដែលគម្រោងបានណែនាំ។ ជាការឆ្លើយតប អេសអិនវីបានធ្វើការពិភាក្សាជាមួយថ្នាក់ដឹកនាំសមាគម ដើម្បីធ្វើឲ្យប្រសើរឡើងនូវចង្វាក់ផ្គត់ផ្គង់ធាតុចូលនៃឧបករណ៍កសិកម្ម រួមនឹងផ្ទាំងប្លាស្ទិកផងដែរ។ ថ្នាក់ដឹកនាំសមាគមមានចំណាប់អារម្មណ៍ក្នុងការបំពេញតួនាទីជាអ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម តែទោះយ៉ាងណាក្តី ការសិក្សាស៊ីជម្រៅពីតម្រូវការសម្ភារៈទាំងនោះគឺចាំបាច់ត្រូវតែធ្វើ។

- អាស្រ័យកង្វះទឹកប្រើប្រាស់ កសិករមិនអាចផលិតបន្លែបានច្រើន ដើម្បីធានានូវការផ្គត់ផ្គង់ទីផ្សារបានឡើយ។ ជាការឆ្លើយតប អេសអិនវីបានគាំទ្រកសិករ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការស្តុកទឹកទុក និងប្រព័ន្ធផ្គត់ផ្គង់ទឹក សម្រាប់ផលិតកម្មបន្លែ។ ជាគម្រោងសាកល្បង កសិករដាំបន្លែចំនួន ១០គ្រួសារ ត្រូវបានជ្រើសរើស ដើម្បីធ្វើការសាកល្បងនូវប្រភេទស្រះក្រាលផ្ទាំងប្លាស្ទិក និងស្នប់រ៉ៃ។ យោងតាមបទពិសោធន៍កសិករ ស្រះក្រាលសំពត់ប្លាស្ទិក បង្ហាញលទ្ធផល ១) អាចបង្កើនវដ្តផលិតកម្មបន្លែពី១ដង ទៅ ៣ដងក្នុង១ឆ្នាំ ២) បង្កើនប្រាក់ចំណូលបន្ថែមចំនួន ២១០ដុល្លារ/ឆ្នាំ តាមរយៈផលិតកម្មបន្លែ ដោយមិនរាប់បញ្ចូលការហូបចុកនិងចំណូលពីត្រី និង ៣) ៨% នៃស្រះដែលបានកែលម្អ ត្រូវបានប្រើប្រាស់សម្រាប់ការចិញ្ចឹមត្រី សម្រាប់ទុកហូបក្នុងគ្រួសារ និងលក់។

**មតិយោបល់:**

- កសិករសហការ និងថ្នាក់ដឹកនាំសមាគមកសិករ និងកសិករមិនសហការ[10]មួយចំនួន បានអនុវត្តគំនិតផ្តួចផ្តើមថ្មីក្នុងវិស័យកសិកម្ម ដែលជាលទ្ធផល អាចជួយបង្កើនផលិតកម្មស្បៀង និងប្រាក់ចំណូលរបស់ពួកគាត់បានមួយកម្រិត។
- អាជ្ញាធរដែនដី/ក្រុមប្រឹក្សាឃុំ បានកោតសរសើរនូវការចូលរួមចំណែក និងការប្តេជ្ញាចិត្តរបស់សមាគមកសិករ ក្នុងកិច្ចអភិវឌ្ឍន៍សហគមន៍។ ចំពោះគម្រោងកសិកម្មឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ អេសអិនវីនឹងជំរុញការធ្វើសមាហរណកម្ម បទពិសោធន៍ជោគជ័យ និងការអនុវត្តល្អៗ ទៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋាន។ ការធ្វើសមាហរណកម្មកសិកម្មដែលឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ នឹងផ្តល់អត្ថប្រយោជន៍ដល់កសិករជាច្រើនទៀត នៅពេលអនាគត។

### ៣.៤.៤. ការគាំទ្រផលិតកម្ម និងទីផ្សារដំឡូងមី ដោយដៃគូរអង្គការអេសអិនវី

គម្រោងអាជីវកម្មតាមបែបបរិយាប័ន្ន ដើម្បីលើកកម្ពស់កសិករដាំដំឡូងមីប្រកបដោយចីរភាព ត្រូវបានអនុវត្តចាប់ពីឆ្នាំ ២០១៣ ដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមានឈ្មោះថា វីជីលែនកម្ពុជា ក្រោមមូលនិធិពីអង្គការអេសអិនវី។ នៅឆ្នាំ២០១៤ មានក្រុមផលិតដំឡូងមីសរុប ២០ក្រុម ក្នុងភូមិ ចំនួន ១៨ នៃស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម និងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ គ្រួសារកសិករសរុបចំនួន ៥៧៦គ្រួសារ ដែលមានសមាជិកជាស្ត្រី ចំនួន ១៣៦នាក់ បានចុះឈ្មោះជាក្រុមផលិតដំឡូងមី។ ក្រុមផលិតទាំងអស់ដែលបានបង្កើតលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ត្រូវបានទទួលស្គាល់ជាផ្លូវការ ដោយក្រុមប្រឹក្សាឃុំ។

ជាលទ្ធផល ក្រុមផលិតដំឡូងមីបានដំណើរការអាជីវកម្ម និងធ្វើការជាមួយសហគ្រាសកែច្នៃ។ នៅដំណាច់ឆ្នាំ ២០១៤ ក្រុមផលិតដំឡូងមី ១២ក្រុម ក្នុងចំណោម ២០ក្រុម បានចុះកិច្ចព្រមព្រៀងលក់ ជាមួយនឹងសហគ្រាសដែលបានជ្រើសរើស និងទទួលបានប័ណ្ណសម្គាល់សមាជិក។ ផ្អែកតាមកិច្ចព្រមព្រៀង និងផែនការរបស់ក្រុមកសិករទាំង១៥៧គ្រួសារ មានផែនការផលិតដំឡូងមី ចំនួន ៣.៧៥៥តោន ដើម្បីផ្គត់ផ្គង់មកសហគ្រាសកែច្នៃ។

ដំណើរការក្នុងការរៀបចំក្រុមផលិតដំឡូងមី មានដូចខាងក្រោមៈ

**ជំហានទី១: ការកំណត់ និងជ្រើសរើសសហគ្រាសកែច្នៃដំឡូងមីៈ** គម្រោងបានធ្វើកិច្ចព្រមព្រៀង ជាមួយសហគ្រាសកែច្នៃដំឡូងមី។ សហគ្រាសកែច្នៃ សុង ហេង និងទីតាំងប្រមូលទិញដំឡូងមី ៣កន្លែង (ជាឈ្មួញកណ្តាល) ត្រូវបានជ្រើសរើសជាអតិថិជនរបស់គម្រោង។

**ជំហានទី២: ការជ្រើសរើសតំបន់គោលដៅៈ** ផ្អែកតាមការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដីដែលពាក់ព័ន្ធ ដូចជាក្រុមប្រឹក្សាឃុំ មេភូមិ និងការស្នើពីភាគីសហគ្រាសកែច្នៃ ឃុំសក្តានុពល ចំនួន ៤ ត្រូវបានជ្រើសរើសជាតំបន់

[10] កសិករមិនសហការៈ កសិករដែលមិនចូលរួមក្នុងក្រុម និងមិនទទួលបានការបណ្តុះបណ្តាលពីគម្រោង។

គោលដៅរបស់គម្រោង។ គម្រោងបានទុកពេលឲ្យភូមិនីមួយៗ រយៈពេល ២សប្តាហ៍ ដើម្បីរៀបចំកិច្ចពិគ្រោះយោបល់ជាមួយអ្នកភូមិ អំពីថាតើ គួរចូលរួមជាមួយគម្រោង ឬ យ៉ាងណា។ ជាលទ្ធផល ភូមិសក្តានុពល ចំនួន ១៨ ភូមិ ត្រូវបានកំណត់ជាភូមិគោលដៅ សម្រាប់គម្រោង ដោយជំហាននេះ ប្រើប្រាស់ពេលវេលាសរុប ៤សប្តាហ៍។

**ជំហានទី៣: ការចងក្រងក្រុមកសិករ និងរៀបចំលក្ខន្តិកៈក្រុម៖** ក្រុមការងារគម្រោង បានរៀបចំការប្រជុំទូទៅក្នុងភូមិសក្តានុពលទាំងអស់ ដើម្បីបង្ហាញពីទស្សនៈទាន និងគៀរគរកសិករ ឲ្យធ្វើការចងក្រងក្រុមផលិតជំឡូងមី។ មានការប្រជុំ៣ប្រភេទក្នុងភូមិនីមួយៗ ១) ជួបជាមួយកសិករជាទូទៅ ហើយបន្ទាប់មកជ្រើសរើសកសិករដែលចាប់អារម្មណ៍ និងថ្នាក់ដឹកនាំបណ្តោះអាសន្ន ដើម្បីរៀបចំពង្រាងលក្ខន្តិកៈ ២) ជួបជាមួយតំណាងកសិករ ដើម្បីពិនិត្យឡើងវិញនូវលក្ខន្តិកៈពង្រាង និង ៣) ការប្រជុំចុងក្រោយ ជាមួយកសិករដែលមានចំណាប់អារម្មណ៍ ដើម្បីចុះឈ្មោះជ្រើសរើសថ្នាក់ដឹកនាំ និងអនុម័តលក្ខន្តិកៈ។ ជាលទ្ធផល ក្រុមផលិតជំឡូងមី ចំនួន ២០ក្រុម ត្រូវបានរៀបចំដោយក្នុងដំណាក់កាលនេះ ប្រើប្រាស់រយៈពេល ៣ខែ។

**ជំហានទី៤: រៀបចំផែនការផលិត៖** បន្ទាប់ពីការរៀបចំក្រុមផលិតជំឡូងមីរួចមក លក្ខន្តិកៈត្រូវបានអនុម័តដោយសមាជិកក្រុម ដោយមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ។ បន្ទាប់មក ពួកគាត់បានចាប់ផ្តើមរៀបចំផែនការផលិត ជាមួយសមាជិករបស់ពួកគាត់។ ក្នុងជំហាននេះ ត្រូវប្រើរយៈពេលប្រហែល ១ខែ។

**ជំហានទី៥: ការកសាងសមត្ថភាពកសិករ៖** មានវគ្គបណ្តុះបណ្តាលចំនួន ៣ ស្តីអំពីបច្ចេកទេសផលិតកម្មជំឡូងមីក្នុង១ក្រុម និង៤វគ្គ សម្រាប់ថ្នាក់ដឹកនាំក្រុម ស្តីពីភាពជាអ្នកដឹកនាំ ការគ្រប់គ្រង និងកិច្ចពិភាក្សាអាជីវកម្ម។ ការពិគ្រោះយោបល់ចំនួន៣ប្រភេទ ស្តីពីចង្វាក់ទីផ្សារ ត្រូវបានរៀបចំ ពិសេសការធ្វើកិច្ចព្រមព្រៀងលក់ ជាមួយសហគ្រាសកែច្នៃ តាមរយៈការពិភាក្សាអាជីវកម្ម។

**តារាងទី 7: ជំហានសំខាន់ៗ ក្នុងការរៀបចំក្រុមផលិតជំឡូងមី**

| សូចនាករ | ដំណាក់កាលមុនពេលរៀបចំ | ដំណាក់កាលបច្ចុប្បន្ន | ក្តីរំពឹងក្នុងពេលអនាគត/និរន្តរភាព |
|---|---|---|---|
| **ស្ថាប័ន** | - មិនមានលក្ខន្តិកៈ និងរចនាសម្ព័ន្ធក្រុម។ | - ក្រុមផលិតជំឡូងមីនៅមិនទាន់រឹងមាំនៅឡើយ ដោយទើបធ្វើការចងក្រងបានរយៈពេល ៨ ខែ។<br>- សកម្មភាពសន្សំប្រាក់ ត្រូវបានណែនាំក្នុងក្រុមផលិតជំឡូងមី។ | - ក្រុមនឹងមិនបន្តដំណើរការប្រសិនគ្មានការវិនិយោគបន្ថែម ដើម្បីពង្រឹងក្រុម។ |

| | | | |
|---|---|---|---|
| **ដំណើរការ** | - អ្នកផ្គត់ផ្គង់ធាតុចូល និងឈ្មួញ មិនមានសេវាកម្មដល់កសិករ។<br>- ក្រុមត្រូវបានបង្កើតរួចរាល់ ប៉ុន្តែពួកគាត់មិនអាចផ្តល់សេវាល្អដល់សមាជិក ដោយកង្វះការប្តេជ្ញាចិត្ត។ | - មន្ទីរកសិកម្មខេត្តបានឯកភាពផ្តល់វគ្គបណ្តុះបណ្តាលដល់កសិករ។<br>- ថ្នាក់ដឹកនាំក្រុមនៅខ្សោយ និងខ្វះការប្តេជ្ញាចិត្តដោយសារពួកគាត់ពុំបានឃើញពីផលប្រយោជន៍របស់ក្រុម និងផលចំណេញរយៈពេលយូរ។ | - ក្រុមនឹងបន្តសកម្មភាព ប្រសិនរដ្ឋាភិបាលមានគោលនយោបាយគាំទ្រផលិតកម្មដំឡូងមី។ |
| **បណ្តាញនិងដៃគូ** | - មិនមានបណ្តាញ ឬដៃគូ។ | - អេសអិនវីបានកសាងភាពជាដៃគូជាមួយអង្គការ CIAT ដើម្បីអនុវត្តគម្រោង និងភាពជាដៃគូជាមួយមន្ទីរកសិកម្មខេត្ត ប៉ុន្តែទំនាក់ទំនងនេះ នៅមានកម្រិតនៅឡើយដោយកង្វះថវិកាគាំទ្រ។<br>- អេសអិនវីបានជ្រើសរើសអង្គការដៃគូក្នុងស្រុក (វីជីលែន កម្ពុជា) ដើម្បីធ្វើការគៀរគរក្រុម និងពង្រឹងក្រុមផលិត។<br>- អេសអិនវីបានព្យាយាមធ្វើការពាក់ព័ន្ធសំខាន់ៗផ្សេងទៀតក្នុងខ្សែសង្វាក់ផលិតកម្ម ដូចជាអ្នកផ្គត់ផ្គង់ធាតុចូល និងឈ្មួញក្នុងស្រុក ដែលត្រូវបានគេស្គាល់ថាជា ទីតាំងប្រមូលទិញដំឡូងមីក្នុងសហគមន៍។ ឈ្មួញក្នុងស្រុកនឹងផ្តល់ឲ្យកសិករនូវការចែករំលែកព័ត៌មានបច្ចេកទេស និងផ្គត់ផ្គង់នូវធាតុ | - បណ្តាញនឹងទទួលបានការគាំទ្របន្ថែមពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដោយសារនាពេលបច្ចុប្បន្ន ភ្នាក់ងារអភិវឌ្ឍន៍ជាច្រើនមានចំណាប់អារម្មណ៍ធ្វើការគាំទ្រដល់វិស័យផលិតកម្មដំឡូងមីនេះ។<br>- ថវិកានៅមានកំណត់ ប៉ុន្តែប្រសិនក្រុមសន្សំប្រាក់ មានដំណើរការល្អ ពួកគាត់អាចទទួលបានការគាំទ្របន្តទៀត ដោយសារពួកគេចង់មានចំណែកភាគហ៊ុនជាមួយកសិករ។ |

| | |
|---|---|
| | ចូលដែលមានគុណភាព ឬ ដើរតួនាទីជាអ្នកផ្តល់សេវាកម្ម។ បច្ចុប្បន្ន អ្នកផ្តល់សេវាកម្មចំនួន៦នាក់ ត្រូវបានជ្រើសរើសដើម្បីផ្តល់ព័ត៌មានពីផលិតកម្មដំឡូងមី និងផ្គត់ផ្គង់ធាតុចូលរួមនឹងសម្ភារៈដែលមានគុណភាពដល់កសិករ។ |

*ប្រភពៈ ការសម្ភាសបុគ្គលិកអេសអិនវី នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ និងថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ដៃគូរបស់អង្គការអេសអិនវី និងក្រុមផលិត នៅថ្ងៃទី៩-១០ ខែកុម្ភៈ ឆ្នាំ២០១៥។*

**តារាងទី 8: ឥទ្ធិពលទៅលើការប្រកបរបរចិញ្ចឹមជីវិត តាមរយៈក្រុមផលិតដំឡូងមី**

| ផលិតកម្ម | មុនពេល | បច្ចុប្បន្ន |
|---|---|---|
| **កម្រិតបុគ្គល** | - កសិករអនុវត្តការដាំដុះដំណាំតែ១ប្រភេទលើដីជាច្រើន ប៉ុន្តែទិន្នផល បានធ្លាក់ចុះពី១ឆ្នាំទៅ១ឆ្នាំ។ | - ការដាំដុះដំណាំតែ១ប្រភេទ នៅតែបន្តអនុវត្ត ប៉ុន្តែក៏មានកសិករមួយចំនួនបានផ្លាស់ប្តូរមកដាំដំណាំចម្រុះវិញ។<br>- ទិន្នផលដំឡូងមី ហាក់មានការកើនឡើងបន្ទាប់ពីកសិករបានអនុវត្តបច្ចេកទេសដែលបានណែនាំដោយគម្រោង។ |
| **ចំនួនសមាជិកគ្រួសារ ដែលធ្វើការក្នុងសកម្មភាពស្វែងរកប្រាក់ចំណូល** | - សមាជិកគ្រួសារ ធ្វើការក្នុងផលិតកម្មដំឡូងមី និងសកម្មភាពកសិកម្មផ្សេងទៀត។ | - គ្រឿងយន្តកសិកម្ម ត្រូវបានជំនួស ហើយកម្លាំងពលកម្មក្នុងវិស័យកសិកម្ម ត្រូវបានកាត់បន្ថយ។ កម្លាំងពលកម្មមួយចំនួនបានផ្លាស់ប្តូរមកធ្វើការងារមិនមែនកសិកម្ម ដើម្បីជីវភាពរស់នៅ។ |
| **កម្រិតក្រុម** | - ចំណូលនៅដំណាក់កាលទិន្នន័យដើមគ្រាៈ ៤.៦៨០ដុល្លារ/គ្រួសារ ដែលក្នុងនោះ ៣.៥៣៦ដុល្លារ ស្មើនឹង ៧១% បានមកពី | - ការសិក្សាមួយផ្សេងទៀតនឹងត្រូវធ្វើឡើងនៅខែមិថុនា ឆ្នាំ២០១៥ ដើម្បីវាយតម្លៃពីឥទ្ធិពលគម្រោង។ |

| | | |
|---|---|---|
| | ផលិតកម្មដំឡូងមី។<br>- ការចំណាយលើផលិតកម្មដំឡូងមីៈ ៥២៥ ដុល្លារ/ហ.ត។<br>- ចំណូលពីដំឡូងមីក្នុង១ហ.តៈ ១.១៨៩ ដុល្លារ។ | - ចំណាយក្នុងផលិតកម្មៈ ៥១៧ដុល្លារ<br>- ចំណូលៈ ១២០០ដុល្លារ ដោយផ្អែកលើតម្លៃដំឡូងមី។ ចំនួននេះ នឹងត្រូវធ្វើបច្ចុប្បន្នភាព ដោយសារថា ការប្រមូលផល នឹងបញ្ចប់នៅខែមេសា។ |
| **កម្រិតសហគមន៍** | - កែច្នៃជាដំឡូងស្ងួត និងលក់ផលិតផលទៅឲ្យឈ្មួញក្នុងស្រុក និងឈ្មួញវៀតណាម ក៏ដូចជា ដំឡូងស្រស់ទៅអ្នកកែច្នៃ។ | - ភាគច្រើន កសិករលក់ដំឡូងស្រស់ ទៅឲ្យឈ្មួញ អ្នកកែច្នៃ និងឈ្មួញវៀតណាម។ |

*ប្រភពៈ ការសម្ភាសបុគ្គលិកអេសអិនវី នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ និង ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ដៃគូរបស់អង្គការអេសអិនវី និងក្រុមផលិត នៅថ្ងៃទី៩-១០ ខែកុម្ភៈ ឆ្នាំ២០១៥។*

**បញ្ហាប្រឈម ដំណោះស្រាយ និងលទ្ធផលៈ**

- **កត្តាចង្រៃ និងជំងឺៈ** ពុំមានដំណោះស្រាយ បញ្ហាជំងឺលើដំឡូងមីនៅឡើយទេ (Witch's Broom)។ គម្រោងបានណែនាំដល់កសិករពីប្រព័ន្ធដំណាំចម្រុះ និងជ្រើសរើសដើមដែលមានសុខភាពល្អ ឬ ពូជដែលគ្មានជំងឺ។ ទោះយ៉ាងនេះក្តី ដំណោះស្រាយដែលបានស្នើឡើង មិនសូវមានផលវិជ្ជមាន ដោយសារកសិករមិនអាចរកបាននូវប្រភេទដើម ឬ ពូជទាំងនោះ។ កសិករក៏នៅខ្វះចំណេះដឹង ពីការប្រើប្រាស់ជី និងការគ្រប់គ្រងកត្តាចង្រៃ។ CIAT ដែលជាដៃគូ របស់អេសអិនវីលើគម្រោង អាជីវកម្មបែបបរិយាប័ន្នស្តីពីដំឡូងមី បានធ្វើការដាំដុះឡើងវិញនូវពូជដែលមានសុខភាពល្អ សម្រាប់ផ្តល់ឲ្យកសិករ ប៉ុន្តែពូជទាំងនោះ នៅមិនទាន់គ្រប់គ្រាន់តាមតម្រូវការនៅឡើយ។

- **អតិផរណាតម្លៃៈ** តម្លៃដំឡូងមី គឺត្រូវបានគ្របដណ្តប់ និងគ្រប់គ្រងដោយឈ្មួញវៀតណាម និងមានការប្រែប្រួលញឹកញាប់បំផុត។ កសិករភាគច្រើនប្រើប្រាស់ប្រាក់កម្ចីសម្រាប់ផលិតកម្មដំឡូងមី និងត្រូវសងត្រឡប់ទៅវិញតាមកាលកំណត់នៅរដូវប្រមូលផល។ ហេតុដូច្នេះ កសិកររមែងបង្ខំចិត្តលក់ផលិតផលរបស់ខ្លួន ទោះបីបានតម្លៃទាប ដើម្បីយកទៅសងប្រាក់កម្ចី។ ប៉ុន្តែ ក៏មានកសិករមួយចំនួន បានធ្វើការសន្សំប្រាក់ជាក្រុម ទោះបីពួកគាត់ពុំមានប្រាក់កាសគ្រប់គ្រាន់ ដើម្បីបំពេញតាមតម្រូវការយ៉ាងណាក៏ដោយ។

**មតិយោបល់:**

ជាទូទៅ គម្រោងបានជួយដល់កសិករ ឲ្យបង្កើននូវផលិតកម្ម និងប្រាក់ចំណូលរបស់ពួកគាត់ តាមរយៈបច្ចេកវិទ្យាកែលម្អ។ ទោះយ៉ាងណា លទ្ធភាពឆ្ពោះទៅទីផ្សារ គឺជាបញ្ហាប្រឈមសម្រាប់កសិករ និងអ្នកកែច្នៃ ដោយសារកំសោយនៃអភិបាលកិច្ចលើខ្សែសង្វាក់ផលិតកម្ម និងអតិផរណាតម្លៃ។ សហគ្រាសកែច្នៃមួយចំនួន បានបិទអាជីវកម្មកែច្នៃរបស់ខ្លួន ដោយសារពួកគាត់ពុំអាចប្រកួតប្រជែងបានជាមួយប្រទេសជិតខាង ក្នុងន័យតម្លៃផលិតផលសម្រេច និងការចំណាយលើការកែច្នៃ និងដឹកជញ្ជូន។ សហគ្រាសកែច្នៃដំឡូងមី ក៏ពុំមានសមត្ថភាពហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីប្រមូលទិញដំឡូងមី នៅរដូវប្រមូលផល សម្រាប់ការកែច្នៃពេញ១ឆ្នាំបានទេ។

គោលនយោបាយវិស័យដំឡូងមី មានសារៈសំខាន់បំផុត ព្រោះវានឹងលើកទឹកចិត្តដល់ការវិនិយោគឯកជនក្នុងការកែច្នៃដំឡូងមី ដែលនឹងជួយឲ្យតម្លៃដំឡូងមីមានស្ថេរភាព។ គោលនយោបាយ ត្រូវបញ្ចូលនូវយុទ្ធសាស្ត្រក្នុងការកាត់បន្ថយថ្លៃដើមក្នុងការកែច្នៃ និងការនាំចេញ ដើម្បីធានាឲ្យមានការប្រកួតប្រជែងលើតម្លៃលក់បាន។ វិស័យដំឡូងមីនៅជាជម្រើសសម្រាប់កសិករ ក្នុងការបង្កើតចំណូល ដោយសារដំណាំនេះ មានភាពធន់នឹងគ្រោះរាំងស្ងួត តម្រូវការចំណាយវិនិយោគបន្តិចម្តងៗ និងអាចបត់បែនពីអាយុ ១០ ទៅ ១៨ខែ ក្នុងការប្រមូលផល។ បច្ចុប្បន្ន កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (UNDP) មានគម្រោងលើកកម្ពស់ការនាំចេញដំឡូងមី ក្នុងទិសដៅស្របគ្នា ជាមួយក្រសួងពាណិជ្ជកម្ម ដែលលើកកម្ពស់វិស័យដំឡូងមីនេះផងដែរ។ គម្រោងនេះនឹងបន្តគាំទ្រកសិករ និងអ្នកវិនិយោគ ដើម្បីគាំទ្រផលិតកម្មដំឡូងមីនេះ។

## ៣.៥. ការវិភាគ និងចំណេះដឹងដែលទទួលបានពីករណីសិក្សា

### ៣.៥.១. យុទ្ធសាស្ត្រចង្វាក់សាកល និងចង្វាក់ប្រមូលផ្តុំពីមូលដ្ឋាន

វិធីសាស្ត្រទីផ្សារ ២ប្រភេទ ត្រូវបានកត់សម្គាល់: ចង្វាក់សាកល និងចង្វាក់ប្រមូលផ្តុំពីមូលដ្ឋាន។

**យុទ្ធសាស្ត្រចង្វាក់ប្រមូលផ្តុំពីមូលដ្ឋាន:** យុទ្ធសាស្ត្រនេះ ត្រូវបានបង្កើតឡើង ដោយអ្នកស្រាវជ្រាវនៃវិទ្យាស្ថានជាតិស្រាវជ្រាវកសិកម្មនៃប្រទេសបារាំង (INRA) និង មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្ម (CIRAD)។

យុទ្ធសាស្ត្រចង្វាក់ប្រមូលផ្តុំពីមូលដ្ឋាន មានប្រភពដើមចេញមកពីការស្រាវជ្រាវកសិកម្មបច្ចេកវិទ្យានៃប្រទេសបារាំង។ នៅពេលប្រទេសបារាំងដាក់អាណានិគម គោលនយោបាយកសិកម្មផ្តោតសំខាន់ទៅលើការអភិវឌ្ឍប្រភេទដំណាំកសិកម្មសម្រាប់ការនាំចេញ ដូចជា កៅស៊ូ កប្បាស និងកាហ្វេជាដើម។ កិច្ចការនេះទាមទារនូវការយកចិត្តទុកដាក់ និងការវិភាគពីប្រភេទចង្វាក់ផលិតផលនីមួយៗ ដែលធ្វើឲ្យចង្វាក់ប្រមូលផ្តុំពីថ្នាក់មូលដ្ឋានមានភាពសមស្របសម្រាប់ការងារនេះ។

វិធីសាស្ត្រនេះ ផ្តោតសំខាន់លើប្រព័ន្ធផលិតកម្មក្នុងស្រុក ហើយដែលប្រព័ន្ធនេះទទួលរងឥទ្ធិពលពីស្ថាប័នសាធារណៈ (Raikes et al., 2000)។ ឧទាហរណ៍ នៅពេលរដ្ឋាភិបាលចុះកិច្ចព្រមព្រៀង នាំចេញនូវផលិតផល

កសិកម្មជាក់លាក់ណាមួយក្នុងបរិមាណច្រើន វាចាំបាច់ត្រូវធានានូវការផ្តល់នូវផលិតផលទាំងនោះ។ ហេតុដូច្នេះ អ្នកផលិតធំៗភាគច្រើន នឹងចុះកុងត្រាបន្ត ឬ ចូលរួមដើម្បីផលិតនូវផលិតផលនាំចេញទាំងនោះ តាមបរិមាណត្រូវការ ខណៈដែលអ្នកផលិតតូចៗ (កសិករ) កម្រមានឱកាស ផ្គត់ផ្គង់នូវផលិតផលក្នុងចំនួនច្រើនដូច្នេះ។ លើសពីនេះ ការវិភាគពីចង្វាក់ប្រមូលផ្តុំពីមូលដ្ឋាន ដាក់បញ្ចូលទាំងទ្រឹស្តីបណ្តាញសង្គម សម្រាប់យុទ្ធសាស្ត្រជាក់លាក់នៃទំនាក់ទំនងសង្គម និងដំណាក់កាលនីមួយៗនៃចរាចរណ៍ទំនិញ។ យុទ្ធសាស្ត្រទីផ្សារនេះ ក៏មានគោលបំណងកសាងនូវទំនាក់ទំនងសង្គមរឹងមាំ ក្នុងចំណោមក្រុមអ្នកផលិត ដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ និងទំនាក់ទំនងជាមួយអតិថិជនក្នុងការកសាងនូវទំនុកចិត្តក្នុងរង្វង់អ្នកផលិតនិងដើម្បីទទួលបានតម្លៃទីផ្សារខ្ពស់ជាងផលិតផលធម្មតា។

យុទ្ធសាស្ត្រចង្វាក់ទីផ្សារបន្លែ ដែលត្រូវបានអនុវត្តដោយអេសអិនវី និងសេដាក គឺស្រដៀងគ្នាទៅនឹងយុទ្ធសាស្ត្រចង្វាក់ប្រមូលផ្តុំពីមូលដ្ឋាន ដែលតាមរយៈទីផ្សារនេះ អ្នកផលិតក្នុងទ្រង់ទ្រាយតូច (កសិករ) ត្រូវបានរៀបចំជាក្រុម សមាគមកសិករ ឬ សហគមន៍កសិកម្ម ហើយភាពជាក់លាក់នៃផលិតផលក្នុងស្រុក បរិមាណ ពេលវេលាផ្គត់ផ្គង់ និងគុណភាពត្រូវបានកំណត់។ ផលិតផលទាំងអស់គឺត្រូវបានប្រមូលផ្តុំពីក្រុមអ្នកផលិតក្នុងតំបន់ និងផ្តោតទៅលើកម្រិតផ្សេងៗ ដូចជា ឃុំ ឬ ស្រុក និងផ្តល់ទៅកាន់ទីផ្សារ ខេត្ត ឬ ក្រុង។ រហូតមកដល់ពេលនេះ សេដាកបានធ្វើការលើកកម្ពស់ផលិតកម្មបន្លែសរីរាង្គដោយជោគជ័យ ដោយសារគេបានកំណត់នូវតម្លៃធានា និងព្រមព្រៀងទិញផលិតផលក្នុងបរិមាណជាក់លាក់មួយ។

លើសពីនេះ វិទ្យាស្ថានស្រាវជ្រាវ និងការអភិវឌ្ឍជនបទកម្ពុជា (អង្គការ CIRD) ក៏បានធ្វើការជាមួយកសិករដាំម្រេច និងរៀបចំក្រុមផលិត ដោយអនុវត្តតាមយុទ្ធសាស្ត្រចង្វាក់ប្រមូលផ្តុំពីមូលដ្ឋាន។ ពួកគាត់បានរៀបចំកិច្ចការ ដើម្បីទទួលបានវិញ្ញាបនបត្រ បញ្ជាក់ផលិតផលសម្គាល់ភូមិសាស្ត្រ សម្រាប់ម្រេចកំពត។ ម្រេចកំពតមានកេរ្តិ៍ឈ្មោះល្អទាំងនៅលើទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ ជាពិសេស ទីផ្សារអឺរ៉ុប។ ជាមួយនឹងកេរ្តិ៍ឈ្មោះនេះ អ្នកធ្វើការនាំចេញបានទាក់ទងជាមួយក្រុមផលិតម្រេចកំពត និងរៀបចំកិច្ចសន្យាសម្រាប់ទីផ្សារនាំចេញ។ ទោះយ៉ាងណាក្តី ក្នុងក្របខណ្ឌនៃការសិក្សា យើងមិនមានធនធាន និងពេលវេលាគ្រប់គ្រាន់ ដើម្បីសិក្សាទៅលើករណីម្រេចកំពតឡើយ។ ការរកឃើញនេះ គឺផ្អែកលើការសម្ភាសជាមួយបុគ្គលិកជំនាញរបស់អង្គការ CIRD ដែលជាអ្នកអនុវត្តគម្រោងផលិតផលសម្គាល់ភូមិសាស្ត្រ។

**យុទ្ធសាស្ត្រចង្វាក់សាកលៈ** យុទ្ធសាស្ត្រចង្វាក់សាកល ត្រូវបានអភិវឌ្ឍឡើង ដោយលោក Gary Gereffi និងក្រុមការងាររបស់គាត់ ក្នុងវិស័យសេដ្ឋកិច្ចនយោបាយនៃការរំពឹងពីការអភិវឌ្ឍ (Gereffi, 1999)។ ការវិភាគពីខ្សែចង្វាក់សាកល ត្រូវបានបង្កើតឡើងជាបឋម សម្រាប់ចង្វាក់ប្រភេទឧស្សាហកម្ម (Raikes et al., 2000)។ ពួកវាផ្តោតទៅលើការលេចឡើង នៃប្រព័ន្ធផលិតកម្មជាសាកលមួយ ដែលការធ្វើសមាហរណកម្មសេដ្ឋកិច្ចឈានទៅដល់ពាណិជ្ជកម្មអន្តរជាតិទាំងទម្រង់វត្ថុធាតុដើម និងផលិតផលសម្រេច (Gereffi, 2000)។

អត្ថន័យនៃការជំរុញឲ្យមានខ្សែចង្វាក់ទីផ្សារដំឡូងមី ដែលត្រូវបានអនុវត្តដោយអង្គការអេសអិនវី គឺស្រដៀងគ្នាទៅនឹងយុទ្ធសាស្ត្រខ្សែចង្វាក់សាកល។ ផលិតផលដំឡូងមី ត្រូវបានផ្គត់ផ្គង់ទៅប្រទេសក្រៅ ដូចជា

វៀតណាម និង ចិន ចេញពីប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជាជាដើម។ ដើម្បីបំពេញនូវតម្រូវការរបស់ឧស្សាហកម្ម ដំឡូងមី កសិករនៅកម្ពុជាបានដាំដំណាំដំឡូងមី ដើម្បីផ្គត់ផ្គង់ទីផ្សារ។ ទោះយ៉ាងណា ដោយកង្វះការសម្របសម្រួល និងការអនុវត្តច្បាប់ ក្នុងចំណោមភាគីពាក់ព័ន្ធ កសិកររមែងជួបបញ្ហាកង្វះអំណាចនៃការចរចា និងបរាជ័យក្នុងអាជីវកម្មរបស់ខ្លួន ដោយបរិមាណផ្គត់ផ្គង់លើសពីតម្រូវការ និងតម្លៃលក់ទាប។ នេះដោយសារថា ដំឡូងមីមិនអាចបង្វិលចូលទីផ្សារក្នុងស្រុក សម្រាប់ការប្រើប្រាស់ ប្រសិនបើវាមិនត្រូវបាននាំចេញ។ អេសអិនវីបានធ្វើការដើម្បីលើកកម្ពស់ចង្វាក់ផលិតកម្មដំឡូងមី តាមរយៈយុទ្ធសាស្ត្រអភិវឌ្ឍន៍អាជីវកម្មបែបបរិយាប័ន្ន ក្នុងគោលបំណងនាំភាគីពាក់ព័ន្ធ ដើម្បីធ្វើការជាមួយគ្នា និងនាំមកនូវអត្ថប្រយោជន៍ដល់អ្នកពាក់ព័ន្ធទាំងអស់។

ជាលទ្ធផល កសិករដាំដំឡូងមីត្រូវបានភ្ជាប់ជាមួយឈ្មួញក្នុងស្រុក និងសហគ្រាសកែច្នៃក្នុងស្រុក។ ទោះយ៉ាងណា អាស្រ័យដោយទំហំពាណិជ្ជកម្ម នៃឧស្សាហកម្មក្នុងស្រុក ដំឡូងមីនៅតែពឹងផ្អែកយ៉ាងខ្លាំងទៅលើទីផ្សារនាំចេញ ដោយការលក់វត្ថុធាតុដើម ដែលជំរុញដោយចង្វាក់សាកល។ ដើម្បីទទួលបានអត្ថប្រយោជន៍ពីផលិតកម្មដំឡូងមី ដែលលើសពីសេចក្តីត្រូវការ ក្នុងប្រទេសកំពុងអភិវឌ្ឍ តួយ៉ាងប្រទេសកម្ពុជា អ្នកទិញនៅក្នុងប្រទេសអភិវឌ្ឍន៍ មិនចាប់អារម្មណ៍ចំពោះការរៀបចំប្រព័ន្ធផលិតកម្ម ដើម្បីធានាការផ្គត់ផ្គង់ដល់ពួកគេទេ (ពោលគឺ គ្មានការធ្វើកិច្ចសន្យាដាំដុះដើម្បីនាំចេញ) ប៉ុន្តែក្នុងពេលជាមួយគ្នានោះ អ្នកទិញអាចទម្លាក់តម្លៃ ដើម្បីបានចំណេញច្រើនពីប្រព័ន្ធចង្វាក់សាកល ដែលមិនមានការគ្រប់គ្រងនេះ។ ប្រព័ន្ធកសិកម្មតាមកិច្ចសន្យា គឺជាឧបករណ៍ដើម្បីលើកកម្ពស់យុទ្ធសាស្ត្រចង្វាក់សាកល នៅពេលដែលកសិករ និងអ្នកទិញ បានយល់ព្រមទៅលើផលិតផលជាក់លាក់ណាមួយ ការកំណត់នូវតម្លៃ និងពេលវេលានៃការផ្គត់ផ្គង់ផលិតផល។

**សមាហរណកម្មយុទ្ធសាស្ត្រប្រមូលផ្តុំពីថ្នាក់មូលដ្ឋាន និងចង្វាក់សាកលៈ** សេដាក ក៏បានកំពុងធ្វើការច្របាច់បញ្ចូលគ្នានូវយុទ្ធសាស្ត្រចង្វាក់ទីផ្សារទាំងពីរ ក្នុងកិច្ចអន្តរាគមន៍លើផលិតផលស្រូវ ដែលត្រូវបានគេស្គាល់ជាប្រភេទទីផ្សារអង្ករសរីរាង្គ។ ដំបូងឡើយ កសិករដែលផលិតស្រូវសរីរាង្គបានចងក្រងគ្នាជាក្រុមនៅកម្រិតភូមិ និងបន្ទាប់មក ចងក្រងជាបណ្តាញថ្នាក់ឃុំ ថ្នាក់ស្រុក ខេត្ត និងថ្នាក់ជាតិ។ អង្ករសរីរាង្គមានគោលដៅទីផ្សារជាច្រើនទាំងនៅទីផ្សារក្នុងតំបន់ នៅតាមទីក្រុង និងទីផ្សារនាំចេញ។ សហគ្រាសសេដាកទិញស្រូវសរីរាង្គពីកសិករ ហើយកិនលក់ទៅឲ្យអតិថិជននៅទីក្រុង។ នេះហៅថា យុទ្ធសាស្ត្រប្រមូលផ្តុំពីថ្នាក់មូលដ្ឋាន។ លើសពីនេះ សេដាកក៏ដើរតួនាទីជាឈ្មួញកណ្តាល និងសហការជាមួយក្រុមហ៊ុននាំចេញ ដើម្បីនាំចេញអង្ករសរីរាង្គទៅកាន់ទីផ្សារបរទេស ឧទាហរណ៍ សហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិកជាដើម។ ក្នុងករណីនេះ អ្នកនាំចេញអង្ករសរីរាង្គបានធ្វើកិច្ចសន្យាជាមួយសេដាក ក្នុងបរិមាណអង្ករសរីរាង្គជាក់លាក់ណាមួយ។ សេដាកធ្វើការសម្របសម្រួលជាមួយកសិករក្នុងការផលិតស្រូវសរីរាង្គ ដើម្បីបំពេញតាមតម្រូវការនាំចេញ។ តម្រូវការកំណត់មួយចំពោះអង្ករសរីរាង្គ ត្រូវបានយល់ព្រមដោយទីផ្សារនាំចេញ ឬអ្នកបញ្ជាទិញ ដែលបន្ទាប់មក ធ្វើការជាមួយក្រុមហ៊ុនក្នុងស្រុក (សហគ្រាសសេដាក) ហើយនេះត្រូវបានគេស្គាល់ថាជាយុទ្ធសាស្ត្រចង្វាក់សាកល។

ជារួម យុទ្ធសាស្ត្រទាំងពីរ (យុទ្ធសាស្ត្រខ្សែចង្វាក់សកល និងយុទ្ធសាស្ត្រប្រមូលផ្ដុំពីមូលដ្ឋាន) ឬ ការប្រុបាច់បញ្ចូលគ្នានូវយុទ្ធសាស្ត្រទាំងពីរ មានភាពសមស្របក្នុងការគាំទ្រកសិករតូចតាច។ ទោះយ៉ាងណា ក្នុងដំណាក់កាលដំបូងនៃការតភ្ជាប់កសិករទៅកាន់ទីផ្សារ និងដើម្បីជួយដល់កសិករ ក្នុងការត្រៀមខ្លួនតបទល់នឹងកត្តាប្រឈមផ្នែកទីផ្សារ យុទ្ធសាស្ត្រប្រមូលផ្ដុំពីថ្នាក់មូលដ្ឋាន មានលក្ខណៈសមស្របខ្លាំងជាង។ យុទ្ធសាស្ត្រប្រមូលផ្ដុំពីថ្នាក់មូលដ្ឋាននឹងជួយដល់កសិករ ដើម្បីទទួលបាននូវការរៀបចំចងក្រងក្រុម ដើម្បីផលិតសម្រាប់ទីផ្សារក្នុងស្រុក និងជាបន្តបន្ទាប់ ការរៀនសូត្រយ៉ាងឆាប់រហ័សដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃទីផ្សារនៅទីក្រុង និងទីផ្សារនាំចេញ។ ចំណេះដឹង បទពិសោធន៍ក្នុងការចងក្រងក្រុម ឬ សហគមន៍កសិកម្ម គឺមានស្រាប់ហើយ។ ការទទួលយកយុទ្ធសាស្ត្រទីផ្សារណាមួយ គឺអាស្រ័យលើធម្មជាតិ នៃផលិតផលដែលត្រូវបានជ្រើសរើស និងភាពរួចរាល់នៃអ្នកពាក់ព័ន្ធផ្សេងៗចំពោះប្រភេទផលិតផលនោះ។ យុទ្ធសាស្ត្រប្រមូលផ្ដុំពីថ្នាក់មូលដ្ឋាន មានឥទ្ធិពលជំរុញអំណាចដែលជួយដល់អ្នកផលិត ទទួលបាននូវការចងក្រងគ្នាជាក្រុម និងពង្រឹងអំណាចដល់ពួកគាត់ ខណៈយុទ្ធសាស្ត្រចង្វាក់សាកលមានឥទ្ធិពលទាញយកអំណាច ដើម្បីពង្រឹង និងលើកទឹកចិត្ត ដល់កសិករឲ្យចូលទៅក្នុងប្រព័ន្ធទីផ្សារ។




**រូបភាពទី 3: ការបង្ហាញទម្រង់រូបភាពពីយុទ្ធសាស្ត្រទីផ្សារទាំងពីរ៖ យុទ្ធសាស្ត្រសាកល (ឆ្វេង) និងយុទ្ធសាស្ត្រការប្រមូលផ្ដុំពីមូលដ្ឋាន (ស្ដាំ)**

### ៣.៥.២. គុណសម្បត្តិ និងគុណវិបត្តិនៃយុទ្ធសាស្ត្រចង្វាក់សាកល និងយុទ្ធសាស្ត្រប្រមូលផ្ដុំពីថ្នាក់មូលដ្ឋាន

យុទ្ធសាស្ត្រចង្វាក់ទីផ្សារទាំងពីរត្រូវបានអនុវត្ត ដើម្បីផ្សារភ្ជាប់ផលិតផលរបស់កសិករទៅកាន់ទីផ្សារ។ វាមានទាំងគុណសម្បត្តិ និងគុណវិបត្តិ ដែលគួរត្រូវបានយកមកគិតគូរពិចារណា នៅពេលយកយុទ្ធសាស្ត្រនេះ ទៅអនុវត្តក្នុងផលិតផលផ្សេងទៀតនៅកម្ពុជា។

**យុទ្ធសាស្ត្រចង្វាក់សាកលៈ** យុទ្ធសាស្ត្រនេះ ពាក់ព័ន្ធទៅនឹងប្រភេទផលិតផលគោលដៅ ក្នុងចំនួនច្រើន ដែលជាធម្មតាជំរុញដោយតម្រូវការទីផ្សារសាកល។ យុទ្ធសាស្ត្រនេះ ល្អសម្រាប់អ្នកមានដីធ្លីធំ ឬ ឈ្មួញកណ្ដាល តាមរយៈការធ្វើកសិកម្មតាមកិច្ចសន្យា ជាជាងកសិករតូចតាចក្នុងតំបន់។ យុទ្ធសាស្ត្រចង្វាក់សាកល លើកទឹកចិត្តឲ្យមានការលូតលាស់ម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេស ជាជាងកសិករខ្នាតតូច។

**យុទ្ធសាស្ត្រប្រមូលផ្ដុំពីថ្នាក់មូលដ្ឋានៈ** យុទ្ធសាស្ត្រនេះ ផ្ដោតទៅលើប្រព័ន្ធផលិតកម្មក្នុងស្រុក។ វាធ្វើសមាហរណកម្ម ទ្រឹស្ដីបណ្ដាញសង្គម សម្រាប់រៀបចំយុទ្ធសាស្ត្រជាក់លាក់ ដើម្បីយល់ដឹងពីទំនាក់ទំនងសង្គម និងអន្តរការ តាមរយៈការគៀរគរកសិករមូលដ្ឋាន និងផលិតផលរបស់ពួកគាត់ សម្រាប់ទីផ្សារ។ វាក៏មានបំណងពង្រឹងទំនាក់ទំនងសង្គមឲ្យរឹងមាំជាមួយក្រុមអ្នកផលិត ដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ និងដើម្បីកសាងទំនុកចិត្តជុំវិញអ្នកផលិត និងអ្នកប្រើប្រាស់ក្នុងការទទួលបានតម្លៃទីផ្សារលក់ខ្ពស់ជាងផលិតផលធម្មតា។ ក្រុមសហគមន៍ រៀនសូត្របានយ៉ាងឆាប់រហ័សពីបែបបទនៃក្រមសីលធម៌និងច្បាប់អាជីវកម្ម ដើម្បីចូលទៅក្នុងទីផ្សារនាំចេញ។ យុទ្ធសាស្ត្រនេះចំណាយពេលច្រើន និងធនធានហិរញ្ញវត្ថុ ដើម្បីគៀរគរសហគមន៍ឲ្យធ្វើការជាមួយគ្នា និងពង្រឹងប្រព័ន្ធផលិតកម្មរបស់ពួកគាត់ ដើម្បីបំពេញនូវទីផ្សារសរីរាង្គ ឬ ទីផ្សារធម្មជាតិ។ លើសពីនេះ យុទ្ធសាស្ត្រនេះនឹងមិនដំណើរការល្អ ប្រសិនបើសហគមន៍ ខ្វះទំនុកចិត្ត និងសាមគ្គីភាព។

### ៣.៥.៣. ផលិតផលសុវត្ថិភាព អង្គការដៃគូអេសអិនវី (និងផលិតផលទីផ្សារធម្មជាតិ (សេជាក))

ការផ្សារភ្ជាប់កសិករទៅទីផ្សារ ក្លាយជាប្រធានបទពេញនិយម ក្នុងការងារអភិវឌ្ឍន៍ បន្ទាប់ពីការចេញគោលការណ៍នៃការអភិវឌ្ឍពិភពលោក ក្នុងឆ្នាំ ២០០៨។ គោលការណ៍បានបញ្ជាក់ថា ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកំពុងអភិវឌ្ឍន៍ វាជាការចាំបាច់ ក្នុងការផ្សារភ្ជាប់កសិករទៅកាន់ទីផ្សារ។ ចាប់តាំងពីពេលនោះមក គម្រោងអភិវឌ្ឍន៍ជាច្រើន ព្យាយាមដាក់បញ្ចូលនូវយុទ្ធសាស្ត្រ “**ការផ្សារភ្ជាប់កសិករទៅទីផ្សារ**” ក្នុងគម្រោងសំណើរបស់ខ្លួន។ ទោះយ៉ាងណា ដើម្បីផ្សារភ្ជាប់កសិករទៅកាន់ទីផ្សារ ប្រកបដោយជោគជ័យ តម្រូវឲ្យមានការរៀបចំជាយុទ្ធសាស្ត្រ។ ការជ្រើសរើសប្រភេទផលិតផល ដើម្បីដាក់ចូលទៅទីផ្សារ គឺជាតថភាពសំខាន់មួយ នៃយុទ្ធសាស្ត្រដើម្បីឈានទៅកាន់ទីផ្សារ។

នៅពេលទីផ្សារពាសពេញដោយផលិតផលកសិកម្ម សេដាកបានជ្រើសរើសផលិតផលធម្មជាតិ ជាទីផ្សារធម្មជាតិ ខណៈដែលអេសអិនវី ធ្វើការជាមួយដៃគូ ដើម្បីជ្រើសរើសនូវផលិតផលសុវត្ថិភាព[11] ក្នុងស្រុក ជាយុទ្ធសាស្ត្រឈានចូលទីផ្សារ។ ផលិតផលសរីរាង្គរបស់សហគ្រាសេដាក ត្រូវបានស្គាល់ដោយអ្នកប្រើប្រាស់នៅទីក្រុង។ លើសពីនេះ នៅកម្រិតសហគមន៍ កម្រិតស្រុក និងកម្រិតខេត្ត កសិករដែលផ្គត់ផ្គង់ផលិតផលសរីរាង្គទៅកាន់សហគ្រាសសេដាក ក៏ត្រូវបានស្គាល់ដោយអ្នកប្រើប្រាស់ក្នុងតំបន់។ ជាលទ្ធផល អ្នកប្រើប្រាស់ក្នុងតំបន់អាចទាក់ទងកសិករផលិតក្នុងស្រុក ដើម្បីទិញផលិតផលសរីរាង្គ។ ស្រដៀងគ្នានេះ កសិករផលិតបន្លែ របស់អង្គការដៃគូអេសអិនវី អាចលក់ផលិតផលរបស់ពួកគាត់ នៅទីផ្សារក្នុងតំបន់បានដោយងាយស្រួលផងដែរ។

### ៣.៥.៤. គុណសម្បត្តិ និងគុណវិបត្តិ នៃទស្សនអាជីវកម្មតាមបែបបរិយាប័ន្ន និងបែបពឹងអាស្រ័យលើខ្លួនឯង

ការសិក្សា បានរកឃើញនូវទស្សនៈអភិវឌ្ឍន៍ចំនួន២ ត្រូវបានអនុវត្ត ដោយអង្គការដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សា គឺទស្សនៈអភិវឌ្ឍន៍ បែបអាស្រ័យលើខ្លួនឯង ដែលអនុវត្តដោយអង្គការសេដាក និងអាជីវកម្មតាមបែបបរិយាប័ន្ន ដែលអនុវត្តដោយអង្គការអេសអិនវី។ ទស្សនៈទានទាំងពីរនេះ មានភាពសមស្រប តាមដំណាក់កាលផ្សេងៗនៃការអភិវឌ្ឍ។ ការអភិវឌ្ឍបែបអាស្រ័យលើខ្លួនឯង ជួយឲ្យកសិករអាចគ្រប់គ្រងចង្វាក់អាជីវកម្មរបស់ពួកគាត់ និងធានានូវការអនុវត្តទីផ្សារផលិតផលដោយខ្លួនឯង។ លើសពីនេះ វាពង្រឹងនូវភាពជាម្ចាស់របស់សហគមន៍ ដែលដឹកនាំទៅដល់ការគ្រប់គ្រងធនធាន និងការអភិវឌ្ឍផ្អែកលើការសម្រេចចិត្តរួមគ្នា។ ទោះយ៉ាងណា ទស្សនៈទានបែបអាស្រ័យលើខ្លួនឯងនេះ ត្រូវចំណាយពេលកសាងរចនាសម្ព័ន្ធមូលដ្ឋាន និងភាពជឿជាក់ក្នុងចំណោមក្រុមផលិត រួមនឹងការយល់ដឹងពីអាជីវកម្ម និងភាពជាអ្នកដឹកនាំក្នុងក្រុម។

យុទ្ធសាស្ត្រអាជីវកម្មបែបបរិយាប័ន្ន ជួយដល់កសិករដើម្បីលើកកម្ពស់រចនាសម្ព័ន្ធអាជីវកម្មមានស្រាប់ ក្នុងរយៈពេលខ្លី និងប្រើប្រាស់ធនធានតិច រួមមានពេលវេលា ហិរញ្ញវត្ថុ និងកិច្ចខិតខំប្រឹងប្រែង។ ទោះយ៉ាងណា អ្នកផលិតចាំបាច់ត្រូវធ្វើការជាមួយអ្នកពាក់ព័ន្ធជាច្រើនជារហូត ក្នុងកំឡុងពេលនៃវដ្តអាជីវកម្ម។ នេះដោយសារថា អ្នកផលិតត្រូវបានរៀបចំ សម្រាប់ការផ្គត់ផ្គង់ប៉ុណ្ណោះ ប៉ុន្តែមិនមែនដើម្បីគ្រប់គ្រងប្រព័ន្ធទេ។ នៅពេលដែលការផ្គត់ផ្គង់លើសពីតម្រូវការ អ្នកទិញមិនខ្វល់ជាមួយក្រុមផលិត ដោយសារថា ពួកគេនៅមានមធ្យោបាយផ្សេងទៀត ដើម្បីទទួលបានការផ្គត់ផ្គង់។

[11] ផលិតផលកសិកម្មសុវត្ថិភាព ត្រូវបានកំណត់ដោយផលិតកម្មកសិកម្ម ដែលអនុវត្តតាមស្តង់ដាការអនុវត្តកសិកម្មល្អ។ មកទល់ពេលនេះ ការអនុវត្តកសិកម្មល្អ ត្រូវបានទទួលស្គាល់ដោយប្រទេសក្នុងសហគមអាស៊ាន ដែលត្រូវបានគេស្គាល់ថា ជាការអនុវត្តកសិកម្មល្អអាស៊ាន។ ជាគោលការណ៍ ប្រទេសក្នុងសហគមអាស៊ាននីមួយៗ ត្រូវតែអនុវត្តតាមស្តង់ដានេះ ប្រសិនគេចង់ធ្វើការនាំចេញផលិតផលកសិកម្មទៅក្នុងបណ្តាប្រទេសក្នុងសហគមអាស៊ាន។ ទោះយ៉ាងណាការត្រួតពិនិត្យពីការអនុវត្តកសិកម្មល្អនៅមិនទាន់បានអនុវត្តនៅឡើយនៅកម្ពុជា។

**តារាងទី ៩: បញ្ហាប្រឈម និងភាពជោគជ័យ ក្នុងការតភ្ជាប់កសិករ ទៅកាន់ទីផ្សារនៅក្នុងប្រភេទ ផលិតផលដែលបានជ្រើសរើស**

| ផលិតផល | គោលដៅទីផ្សារ | ភាពជោគជ័យ និងកត្តាប្រឈមជាសារវន្ត |
|---|---|---|
| **បន្លែ** | ទីផ្សារក្នុងតំបន់ និងទីក្រុង | **គន្លឹះនៃភាពជោគជ័យ**<br>- មានការរួបរួមសាមគ្គីគ្នាបានល្អ ក្នុងចំណោមកសិករផលិតនៅក្នុងសហគមន៍មូលដ្ឋាន។ អ្នកផលិតបន្លែ មិនត្រឹមតែអាចផលិតបន្លែសម្រាប់ហូបក្នុងគ្រួសារប៉ុណ្ណោះទេ ថែមទាំងសម្រាប់ផ្គត់ផ្គង់នៅទីផ្សារផងដែរ។<br>- ផលិតកម្មបន្លែ ត្រូវបានណែនាំក្នុងទិសដៅបម្រើការហូបចុក និងជាប្រភពចំណូលបន្ទាប់បន្សំក្នុងគ្រួសារ ប៉ុន្តែបន្តិចម្តងៗ មុខរបរនេះ បានក្លាយជាមុខរបរសំខាន់ និងចូលរួមចំណែកក្នុងសេដ្ឋកិច្ចគ្រួសាររបស់គាត់។<br>- កសិករអាចពង្រីកទំហំផលិតកម្មរបស់ពួកគាត់ ហើយថែមទាំងទទួលបានតម្លៃលក់ច្រើនទ្វេដង បើធៀបនឹងប្រភេទផលិតផលធម្មតា។ |
| | | **បញ្ហាប្រឈមសំខាន់ៗ:**<br>- ផលិតកម្មមានការធ្លាក់ចុះ ក្នុងចន្លោះខែមីនា និងមេសា នៅពេលខ្វះប្រភពទឹកស្រោចស្រព។<br>- តម្រូវការទីផ្សារនៅមានកម្រិត ជាឧបសគ្គដល់កសិករ ដែលចង់ពង្រីកផលិតកម្មបន្លែរបស់ខ្លួន។<br>- លទ្ធភាពទទួលបានគ្រាប់ពូជដែលមានគុណភាពល្អ និងបច្ចេកវិទ្យាកសិកម្មឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ នៅមានកម្រិតនៅឡើយ នៅតាមសហគមន៍។ |
| **ស្រូវ** | ទីផ្សារក្នុងតំបន់ ទីផ្សារនៅទីក្រុង និងទីផ្សារនាំចេញ | **គន្លឹះនៃភាពជោគជ័យ:**<br>- កសិករក្នុងតំបន់ បានរៀនសូត្រនូវបច្ចេកទេសផលិតកម្មប្រសើរជាងមុន ជាពិសេស បច្ចេកទេសខាងប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ(ប.វ.ស) ដែលជួយបង្កើននូវផលិតភាព និងអាចអនុញ្ញាតិឲ្យពួកគាត់ ទទួលបានតម្លៃលក់ប្រសើរជាងមុន។<br>- កសិករក្នុងតំបន់ បានធ្វើការជាមួយគ្នាក្នុងក្រុម សមាគម សហគមន៍កសិកម្ម និងសហព័ន្ធ ហើយបានគៀរគរធនធានសម្រាប់ការអភិវឌ្ឍ និងពង្រីកអាជីវកម្ម ឆ្ពោះដល់ភាពអាស្រ័យលើខ្លួនឯង។<br>- យុទ្ធសាស្ត្រ ក្នុងការផ្តល់ហិរញ្ញវត្ថុ ដល់សហគមន៍រោង ម៉ាស៊ីនកិន |

| | | |
|---|---|---|
| | | ស្រូវ កំពុងទាក់ទាញការគាំទ្រពីតួអង្គអភិវឌ្ឍន៍ផ្សេងទៀត ពីម្ចាស់ជំនួយ និងពីរដ្ឋាភិបាលផងដែរ។<br>- ផលិតផលអង្ករសរីរាង្គ ត្រូវបានផ្សារភ្ជាប់ទៅកាន់ទីផ្សារជាតិ និងអន្តរជាតិ។ |
| | | **បញ្ហាប្រឈមសំខាន់ៗៈ**<br>- ការភ្ជាប់កសិករទៅទីផ្សារជាតិ និងទីផ្សារនាំចេញ ពិតជាទាមទារនូវពេលវេលា និងការវិនិយោគហិរញ្ញវត្ថុ រួមនឹងការពង្រឹងគោលនយោបាយ ពិសេស ការអនុវត្តកសិកម្មល្អ។<br>- សមត្ថភាពហិរញ្ញវត្ថុ ដើម្បីប្រមូលទិញស្រូវពីសមាជិក នៅរដូវប្រមូលផលស្រូវ រួមនឹងឧបករណ៍ចាំបាច់ សម្រាប់ការកែច្នៃស្រូវ នៅមានកម្រិតនៅឡើយ ទាំងនៅកម្រិតស្ថាប័នសេដាក និងសហគមន៍រោងម៉ាស៊ីនកិនស្រូវ។ |
| **ដំឡូងមី** | ទីផ្សារនាំចេញ និងសហគ្រាសកែច្នៃក្នុងស្រុក | **គន្លឹះនៃភាពជោគជ័យ**<br>- ជាលទ្ធផល តាមរយៈការបណ្តុះបណ្តាលបច្ចេកទេស ដែលផ្តល់ដោយគម្រោង កសិករផលិតក្នុងស្រុកជាក្រុម  បានរៀនសូត្រពីបច្ចេកទេសក្នុងការដាំដុះ បានល្អប្រសើរជាងមុន។ ទោះបីដំឡូងមីនៅមិនទាន់បានប្រមូលផលនៅឡើយ វាទំនងថា ដំណាំនេះ ដុះលូតលាស់បានល្អ បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ។<br>- តាមរយៈអន្តរាគមន៍គម្រោង បញ្ហាប្រឈមសំខាន់មួយចំនួនក្នុងការតភ្ជាប់កសិករទៅទីផ្សារ ត្រូវបានកាត់បន្ថយ។<br>ឧទាហរណ៍ កសិករជាអ្នកផលិតទទួលបានព័ត៌មានទូលំទូលាយជាងមុន ទាក់ទងនឹងតម្លៃលក់ពីប្រភពផ្សេងៗគ្នា។ វាអាចជួយពួកគាត់ ដើម្បីធ្វើការសម្រេចចិត្តលក់ផលិតផលរបស់ពួកគាត់ទៅកាន់ទីផ្សារខាងក្រៅ។ |
| | | **បញ្ហាប្រឈមសំខាន់ៗ**<br>- ដោយសារផលិតកម្ម លើសពីសមត្ថភាពកែច្នៃក្នុងស្រុក តម្លៃលក់នៅតែមានការប្រែប្រួលជាញឹកញយ។ តម្លៃអាស្រ័យលើសហគ្រាសកែច្នៃ និងឈ្មួញបរទេស ជាពិសេស ឈ្មួញវៀតណាម។<br>- តម្លៃផលិតកម្មខ្ពស់ និង ការចំណាយក្រៅទីផ្សារផ្សេងទៀត បង្កផលប៉ះពាល់ដល់កសិករខ្នាតតូច ដោយសារឈ្មួញប្រមូលទិញ ឬអ្នកកែច្នៃនឹងផ្តល់ដល់កសិករក្នុងតម្លៃទាប ដើម្បីទូទាត់នឹងការចំណាយទាំងឡាយនោះ។ |

ជារួម នៅពេលកសិករជាច្រើននិយាយពីឧបសគ្គ និងបញ្ហាលំបាកមួយចំនួនក្នុងការដាំបន្លែ ឧទាហរណ៍ បញ្ហាខ្វះទឹកស្រោចស្រព ដីមិនសូវមានជីជាតិ និងខ្វះទីផ្សារលក់ដូរ កសិករសហការជាមួយអង្គការសេដាក និង ដៃគូសហការរបស់អេសអិនវី អាចផលិតបន្លែ មិនត្រឹមសម្រាប់ការផ្គត់ផ្គង់ការហូបចុកក្នុងគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចផលិតសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងតំបន់ និងទីក្រុងថែមទៀតផង។ កសិករដាំបន្លែទាំងនោះមាន ទំនុកចិត្ត ជាមួយនឹងចំណេះដឹងដែលពួកគាត់មាន និងបន្តអភិវឌ្ឍន៍គំនិតថ្មីៗបន្ថែមទៀត។ បច្ចុប្បន្នកសិករមួយ ចំនួនដែលសហការជាមួយអង្គការសេដាក អាចផលិតគ្រាប់ពូជសម្រាប់ការដាំដុះនៅរដូវបន្ទាប់ ខណៈកសិករដែល សហការជាមួយអេសអិនវីអាចផលិតបន្លែដែលមានតម្លៃខ្ពស់ និងបន្លែខុសរដូវកាលបានទៀតផង។

ហេតុដូច្នេះ យើងអាចនិយាយបានថា ការច្នៃប្រឌិត ឬ របៀបនៃការប្រើបច្ចេកទេសគឺ មានដាក់ឲ្យប្រើ ប្រាស់នៅតាមតំបន់មូលដ្ឋាន ហើយត្រូវបានទទួលយកប្រកបដោយជោគជ័យ។ ការពង្រីក និងផ្សព្វផ្សាយនូវ បទពិសោធន៍ជោគជ័យទាំងនេះទៅដល់កសិករដទៃនៅតំបន់ផ្សេងទៀត គឺជាការចាំបាច់។

# ៤. សន្និដ្ឋាន និងអនុសាសន៍

### ៤.១. សន្និដ្ឋាន

ផ្តើមចេញពីការវិភាគខាងលើ យើងអាចទាញការសន្និដ្ឋានជារួមដូចតទៅៈ

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ពុំបានផ្តល់អាទិភាពលើសលប់ណាមួយ ទៅលើ កសិកម្មខ្នាតតូច ឬ ខ្នាតធំឡើយ ប៉ុន្តែបានផ្តល់នូវគំនិតផ្តួចផ្តើមថ្មីមួយចំនួន ដើម្បីធ្វើឲ្យប្រសើរឡើងនូវ វិស័យកសិកម្ម ដែលអាចផ្តល់អត្ថប្រយោជន៍ដល់កសិករតូចតាច និងអ្នកដែលមានដីធ្លីធំ។ គំនិតផ្តួចផ្តើមថ្មី នេះ ត្រូវបានជំរុញតាមរយៈការផ្តោតជាសំខាន់ លើការធ្វើទំនើបកម្ម ការចាកចេញពីកសិកម្មបែបប្រពៃណី ឆ្ពោះទៅកាន់បច្ចេកទេសទំនើប ពិពិធូបនីយកម្មដំណាំ ដែលមានតម្លៃទីផ្សារខ្ពស់ និងសម្រាប់ឆ្ពោះទៅការ នាំចេញ។ គំនិតផ្តួចផ្តើមចម្បងមានគោលដៅបង្កើននូវផលិតភាព តាមរយៈយន្តការ ការធ្វើឲ្យប្រសើរឡើង នូវប្រព័ន្ធស្រោចស្រព ការណែនាំនូវបច្ចេកវិទ្យាថ្មី ការជំរុញឲ្យមានពាណិជ្ជកម្ម និងការនាំចេញផលិតផល កសិកម្ម ការធ្វើពិពិធកម្ម ឆ្ពោះទៅរកផលិតផលទីផ្សារ និងមានតម្លៃខ្ពស់ ឬ ការធ្វើឲ្យប្រសើរឡើងនូវគុណ ភាពផលិតផលកសិកម្មជាដើម។
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ចាត់ទុកកសិករ ជាក្រុមដែលមានស្ថានភាពដូចគ្នា ដែលអាចចូលទៅ ក្នុងដំណើរការ និងទទួលអត្ថប្រយោជន៍នៃការធ្វើទំនើបកម្ម។ មានការគិតពិចារណាតិចតួច ពីការទទួល យកនូវយុទ្ធសាស្ត្រ ដែលតម្រូវសម្រាប់កសិករតាមប្រភេទផ្សេងៗ។ លើសពីនេះ មានការលម្អិតតិចតួច អំពីថាតើ ត្រូវផ្គូរផ្គងប្រភេទទីផ្សារផ្សេងៗ ដូចជា ទីផ្សារក្នុងតំបន់ ទីផ្សារកណ្តាល និងទីផ្សារនាំចេញ ឬ ទីផ្សារពិភពលោកជាមួយកសិករខ្នាតតូចយ៉ាងដូចម្តេច។ កិច្ចសហការ និងភាពជាដៃគូ រវាងកសិករខ្នាត តូច និង ខ្នាតធំ អាចធ្វើទៅបាន ប៉ុន្តែជាសំខាន់ តាមរយៈការដាំដុះតាមកិច្ចសន្យា ឬ លទ្ធភាពប្រសើរជាង មុន ក្នុងការទទួលបាននូវធាតុចូល និងបច្ចេកវិទ្យាកែលម្អ។ បើគ្មានយុទ្ធសាស្ត្រសម្របសម្រួល អ្នកដែល ទទួលបានអត្ថប្រយោជន៍ច្រើន ចេញពីនយោបាយជាអាទិភាព ដែលប្រកាសនៅក្នុងផែនការយុទ្ធសាស្ត្រ

អភិវឌ្ឍន៍ជាតិ គឺមានតែអ្នកផលិតក្នុងទ្រង់ទ្រាយធំ និងកសិករខ្នាតតូចដែលស្ថិតនៅក្នុងលំដាប់ខ្ពស់តែប៉ុណ្ណោះ។

- របកគំហើញចេញពីការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ បានបង្ហាញនូវភាពសាំញ៉ាំនៃយុទ្ធសាស្ត្រ និងគោលគំនិតដើម្បីគាំទ្រកសិករខ្នាតតូច។ ទោះយ៉ាងណា វាមានទាំងកត្តាប្រឈម និងក្តីសង្ឃឹមនៅក្នុងយុទ្ធសាស្ត្រទាំងនេះ។ តួអង្គផ្សេងៗក្នុងការសិក្សា មានជំនឿយ៉ាងមុតមាំ និងការតាំងចិត្តចំពោះគោលគំនិតរបស់ពួកគេៈ ការលើកកម្ពស់ស្ថានភាពកសិករតូចតាច តាមរយៈការធ្វើឲ្យប្រសើរឡើង នូវការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ ដើម្បីចូលរួមចំណែក ការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច (ភ្នាក់ងាររដ្ឋាភិបាល) ការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធដែលមានស្រាប់ ឆ្ពោះទៅកាន់ការលើកកម្ពស់អត្ថប្រយោជន៍នៃតួអង្គពាក់ព័ន្ធ (អេសអិនវី) និងការលើកកម្ពស់ស្ថានភាពរបស់កសិករខ្នាតតូចតាច តាមរយៈការពង្រឹងសមត្ថភាពនៃអ្នកផលិត និងភាពអាស្រ័យលើខ្លួនឯង (សេដាក)។ អង្គការទាំងពីរបានបង្ហាញនូវភាពជោគជ័យរបស់ខ្លួនក្នុងការគាំទ្រកសិករដែលមានដីធ្លីតូច ពីយុទ្ធសាស្ត្រពិសេសរបស់ពួកគេៈ យុទ្ធសាស្ត្រទីផ្សារ និងប្រភេទផលិតផលដែលត្រូវបានជ្រើសរើស។ ទោះយ៉ាងណា ឯកសារយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម) ស្តីពីវិស័យកសិកម្ម ពុំបានផ្តល់នូវចំណុចលម្អិត និងទិសដៅច្បាស់លាស់ទៅលើវិធីសាស្ត្រទាំងពីរនេះឡើយ។
- របកគំហើញចេញពីការធ្វើករណីសិក្សា បានបង្ហាញថា គោលគំនិត ពីកម្រិតស្ថាប័ន និងកម្រិតកម្មវិធី មានផលប៉ះពាល់ជាវិជ្ជមានទៅលើសហគមន៍។ យើងក៏បានរកឃើញថា មេរៀនដែលទទួលបានទាំង ៣ ដែលគួរត្រូវបានរាប់បញ្ចូលក្នុងឯកសារគោលនយោបាយគឺៈ១)ការអភិវឌ្ឍបែបពឹងអាស្រ័យលើខ្លួនឯងតាមរយៈយុទ្ធសាស្ត្រ ការប្រមូលផ្តុំពីថ្នាក់មូលដ្ឋាន ២)អាជីវកម្ម តាមបែបបរិយាប័ន្ន តាមរយៈចង្វាក់សាកល និង ៣) បច្ចេកវិទ្យាច្នៃប្រឌិតថ្មី សម្រាប់ការអភិវឌ្ឍកសិកម្មក្នុងលក្ខខណ្ឌមិនអំណោយផល។ មេរៀនទាំងនេះ គួរត្រូវបានអនុវត្តចំពោះប្រភេទផលិតផលផ្សេងៗ ក៏ដូចជាទៅតាមតំបន់គោលដៅផ្សេងទៀត។

ទោះយ៉ាងណា យើងអាចរំឭកមកវិញថា ការសន្និដ្ឋាន ដែលបានបង្ហាញនៅទីនេះ គឺទាញចេញពីការធ្វើករណីសិក្សាចំនួន៤ របស់អង្គការ ២ តែប៉ុណ្ណោះ។ ករណីសិក្សាបន្ថែមទៀត គួរត្រូវបានជ្រើសរើស ចងក្រងជាឯកសារ ធ្វើការវិភាគ និងធ្វើសំយោគបន្ថែមទៀត ដើម្បីពង្រឹងលទ្ធផលនៃការសិក្សានេះ។

## ៤.២. អនុសាសន៍

**ចំពោះរដ្ឋាភិបាលៈ**

